

global witness

# ការផ្ទេរខ្សាច់

## វិធីដែលតម្រូវការរបស់ប្រទេសសិង្ហបុរីចំពោះខ្សាច់របស់ប្រទេសកម្ពុជា គំរាមកំហែងដល់ប្រព័ន្ធអេកូឡូហ្ស៊ី និងធ្វើឱ្យអន្តរាយដល់ អភិបាលកិច្ចល្អ

**A Report by Global Witness May 2010**


Istock

# មាតិកា


**សេចក្តីសង្ខេប** 2

1. **ខ្សាច់ត្រូវបានធ្វើឱ្យវិនាសអន្តរាយ ៖**
   វិស័យខ្សាច់របស់ប្រទេសកម្ពុជាត្រូវបានថ្លែងដោយគួបលរីតណោសនៅក្នុង *ប្រទេសជាតិលក់* 5

2. **អាហារដែលទទួលទានធ្វើឱ្យមានជំងឺ ៖**
   អ្នកដើរតួនាទីសំខាន់នៅក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០១០ 7

3. **បូមខ្សាច់បង្កើនធូលី ៖**
   ផលប៉ះពាល់នៃវិស័យខ្សាច់ដែលមិនបានគ្រប់គ្រងរបស់ប្រទេសកម្ពុជា 18

4. **ការផ្ទេរខ្សាច់ ៖**
   បរាជ័យនៃក្របខណ្ឌច្បាប់ដើម្បីគ្រប់គ្រងវិស័យខ្សាច់របស់ប្រទេសកម្ពុជា 22

5. **តួនាទីប្រទេសសិង្ហបុរី ៖**
   អ្នកនាំចូលខ្សាច់របស់ប្រទេសកម្ពុជា 27

6. **ប្រធានខ្សាច់ ៖**
   ម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា - តើនេះជាជំនួយមានប្រសិទ្ធិភាពដែរឬទេ? 34

7. **អនុសាសន៍** 36



ឯកសារនេះ គឺជាសេចក្តីបកប្រែនៃរបាយការណ៍ច្បាប់ដើមជាភាសាអង់គ្លេស ។ ដើម្បីចៀសវាងចម្ងល់ ក្នុងករណីដែលមានភាពប្រទើស ដោយភាពមិនច្បាស់លាស់នៃអត្ថន័យ ឬអ្វីៗផ្សេងៗទៀត របាយការណ៍ជាភាសាអង់គ្លេស នឹងត្រូវបានយកជាឯកសារដើម ហើយចម្ងល់ នានាទាក់ទងនឹងការបកប្រែ គួរតែត្រូវបានកំណត់ដោយការយោងមកកាន់សំណៅជាភាសាអង់គ្លេសនេះប៉ុណ្ណោះ ។

# សេចក្តីសង្ខេប

ជាមួយនឹង GDP ក្នុងម្នាក់ៗចំនួន 50,000 ដុល្លារអាមេរិក ប្រទេសសិង្ហបុរី ស្ថិតនៅក្នុងចំណោមប្រជាជាតិមានជាងគេបំផុតនៅក្នុងពិភពលោក - ប៉ុន្តែបើតាមទីកដីវិញ ប្រទេសនេះខ្សត់ខ្សោយណាស់ ។ រដ្ឋរបស់ក្រុងនេះ មានទំហំបីដងកន្លះនៃក្រុងវ៉ាស៊ីងតោនឌីស៊ី ដែលមានប្រជាជនច្រើនស្ទើរតែ ប្រាំបីដង ។[1] ភាពខ្ពង់ខ្ពស់ដ៏តិចតួចស្តួចស្តើងរបស់ខ្លួន មិនទាន់បំពេញមហិច្ឆិតាផ្ទាល់ខ្លួននៅឡើយទេ ។ ដើម្បីរក្សាបាននូវស្ថានភាពរបស់ខ្លួនជា មជ្ឈមណ្ឌលហិរញ្ញវត្ថុសកលមួយ ប្រទេសសិង្ហបុរីបានពង្រីកផ្ទៃដីរបស់ខ្លួនចំនួន 22% ចាប់តាំងពីទសវត្សឆ្នាំ 1960 មក ដែលជាប្រតិបត្តិការមួយ ពាក់ព័ន្ធនឹងការរុករានដី និងការសាងសង់យ៉ាងធំទូលំទូលាយ - លើ ក្រោម និងទៅខាងក្រៅ ។

ដំណើរការនេះ តម្រូវឱ្យមានបរិមាណខ្សាច់ដ៏ច្រើនសំបើម ។ ប្រទេសសិង្ហបុរី ត្រូវការប្រភពធនធាននេះពីខាងក្រៅព្រំដែនប្រទេសរបស់ខ្លួន ហើយ តម្រូវការនេះសឱ្យឃើញថា កាន់តែលំបាកធ្វើឡើងៗ ។ ក្នុងចំណោមប្រទេសជិតខាងរបស់ខ្លួន រដ្ឋាភិបាលម្តងមួយៗបានកម្រិត ឬហាមការនាំចេញ ខ្សាច់ទៅកាន់ប្រទេសសិង្ហបុរី ដោយសារតែមានសញ្ញាអាសន្នផ្នែកបរិស្ថានធ្ងន់ធ្ងរដែលអាច មានរបស់ខ្លួន ។ ប្រទេសទាំងនេះរួមមាន ប្រទេស ឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី និងប្រទេសវៀតណាម ។ នៅពេលបញ្ឈប់និមួយៗ ប្រទេសផ្សេងទៀតចូលមកវិញម្តង ។ នាពេលថ្មីៗចុងក្រោយនេះ ប្រទេសកម្ពុជាបានក្លាយជាអ្នកផ្គត់ផ្គង់ខ្សាច់ដ៏ធំមួយឱ្យប្រទេសសិង្ហបុរី ។



Flickr / William Cho

ប្រទេសសិង្ហបុរី - ការកើនឡើងខ្សាច់នាំចូលពីក្រៅព្រំដែនប្រទេសរបស់ខ្លួន ។ ផ្ទៃដីរបស់ប្រទេសបានពង្រីក ច្រើនជាង 20% ចាប់តាំងពីទសវត្សឆ្នាំ 1960

ក្នុងឋានៈជាអង្គការក្រៅរដ្ឋាភិបាល (NGO) អន្តរជាតិមួយពាក់ព័ន្ធនឹងអភិបាលកិច្ចធនធានធម្មជាតិរបស់ប្រទេសកម្ពុជា គ្លូបលវីតណេសបាន ស៊ើបអង្កេតពីឧស្សាហកម្មខ្សាច់នៅក្នុងប្រទេសកម្ពុជាលើរវាងឆ្នាំ 2009 និង 2010 . ការងារនេះ បង្កើតឡើងផ្អែកតាមភស្តុតាងដែលបានបោះពុម្ពផ្សាយនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៩ ពីវិធីដែលគំរូនៃអំពើពុករលួយ និងការឧបត្ថម្ភ ត្រូវបានរកឃើញនៅក្នុងវិស័យព្រៃឈើរបស់ប្រទេសកម្ពុជា ហើយ ត្រូវបានកត់ត្រាទុកដោយគ្លូបលវីតណេសអស់ដប់បីឆ្នាំ ឥឡូវនេះកំពុងត្រូវបានចម្លងដូចគ្នានៅក្នុងឧស្សាហកម្មដកស្រង់ធនធានរបស់ប្រទេសនេះ ។ ឯកសារនេះ អធិប្បាយពីឥទ្ធិពលបង្ខិនបង្ខោច នៃពាណិជ្ជកម្មខ្សាច់ក្នុងតំបន់នេះទៅលើប្រទេសកម្ពុជា ព្រមទាំងតម្រូវការបន្ទាន់សម្រាប់រាល់ភាគី ពាក់ព័ន្ធទាំងអស់ឱ្យចាត់វិធានការណ៍បន្ទាន់ ដើម្បីសម្រាលផលប៉ះពាល់សង្គម បរិស្ថាន និងអភិបាលកិច្ច ។ លទ្ធផលរកឃើញចំបងៗនៃរបាយការណ៍ មានដូចខាងក្រោម :[i]

## តម្រូវការខ្សាច់របស់ប្រទេសសិង្ហបុរី កំពុងលើកទឹកចិត្តឱ្យមានឧស្សាហកម្មនេះនៅក្នុងប្រទេសកម្ពុជា ។

- រដ្ឋាភិបាលប្រទេសកម្ពុជាអះអាងថា បានចេញបទបញ្ញត្តិ រួមទាំង "បានហាម" ការនាំចេញខ្សាច់ផងដែរ ។ ទោះយ៉ាងណា ឧស្សាហកម្មខ្សាច់ របស់ប្រទេសនេះ នៅតែកំពុងកើនឡើន ហើយវិធានការណ៍របស់រដ្ឋាភិបាល ហាក់បីដូចជាបានសម្រួលសម្រួល ជាជាងបានកម្រិតប្រតិបត្តិការ បូមខ្សាច់ ។
- ប្រទេសសិង្ហបុរីគឺជាអ្នកប្រើប្រាស់ខ្សាច់ដែលបាននាំចេញពីប្រទេសកម្ពុជាចំបង ។
- អាជ្ញាប័ណ្ណធ្វើអាជីវកម្ម និងនាំចេញ ត្រូវបានចេញឱ្យតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ។ ប្រតិបត្តិការពីខេត្តតែមួយ ត្រូវបានប៉ាន់ស្មានថា មានតម្លៃប្រមាណ 248 លានដុល្លារអាមេរិកក្នុងមួយឆ្នាំ តាមតម្លៃលក់រាយនៅក្នុងប្រទេសសិង្ហបុរី ។
- ពាណិជ្ជកម្មនេះ ហាក់បីដូចជាស្ថិតនៅក្រៅពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម ធម្មតា - អាជ្ញាប័ណ្ណបូមខ្សាច់មួយចំនួនក្នុងចំណោមនេះដែលបានទទួល ដោយគ្លូបលវីតណេស មានត្រារបស់មន្ត្រីប្រទេសសិង្ហបុរីនៅក្នុងស្ថានទូត ប្រចាំទីក្រុង ។

## ឧស្សាហកម្មនេះនៅក្នុងប្រទេសកម្ពុជា ត្រូវបាន គ្រប់គ្រងដោយបុគ្គលពីររូបដែលជិតស្និទ្ធនឹងនាយករដ្ឋមន្ត្រី និងគណបក្សកាន់អំណាច CPP ។

- មហាសេដ្ឋីទាំងនេះ គឺជាព្រឹទ្ធសមាជិកទាំងពីរនៃគណបក្សប្រជាជនកម្ពុជាកាន់អំណាច (CPP) ហើយពីមុនបានទទួលប្រយោជន៍ពី កិច្ចព្រមព្រៀង និងសម្បទានរដ្ឋាភិបាលដែលបំផ្លិចបំផ្លាញធនធានធម្មជាតិផ្សេងទៀត ។ ពួកគេគឺ :
    - ឯកឧត្តម ម៉ុង ឬទ្ធី
    - ឯកឧត្តម លី យ៉ុងផាត់
- មានការខ្វះខាតតម្លាភាព និងការទទួលខុសត្រូវទាំងស្រុង ជុំវិញការផ្តល់ឱ្យ និងអ្នកទទួលប្រយោជន៍នៃអាជ្ញាប័ណ្ណខ្សាច់ទាំងនេះ ហើយ គ្លូបលវីតណេស បានរកឃើញភស្តុតាងពីការបង់ប្រាក់ចំណាយមិនធម្មតាជាច្រើន ។

i សេចក្តីយោងសម្រាប់បណ្តាចំណុចទាំងឡាយដែលបានរៀបរាប់ក្នុងផ្នែកនេះ អាចមើលឃើញបានក្នុងខ្លឹមសារខាងក្នុងនៃរបាយការណ៍ ។



គ្លូបលវិតណេស

ស្តុកខ្សាច់ដែលគ្រប់គ្រងដោយក្រុមហ៊ុន L.Y.P. Group កំពុងរង់ចាំការនាំចេញ ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ក្នុងខេត្តកោះកុង ប្រទេសកម្ពុជា ។

- បណ្តាក្រុមហ៊ុនដែលយកធនធានខ្សាច់ពីបុគ្គលទាំងនេះ គឺជាអ្នកផ្គត់ផ្គង់ខ្សាច់ដែលបានចុះបញ្ជីនៅរដ្ឋាភិបាលប្រទេសសិង្ហបុរី ។

## ប្រាក់រាប់លានដុល្លារអាមេរិក ប្តូរពីម្ចាស់មួយទៅមួយទៀត តែមិនមានវិធីតាមដានថាតើសួយសារ ពន្ធដារ និង ប្រាក់ចំណូលផ្សេងទៀតដែលរកបានពី ឧស្សាហកម្មបូម និងនាំចេញខ្សាច់ បានទៅដល់ដៃរតនាគារជាតិដែរឬអត់ ។

ដោយសារការខ្វះខាតតម្លាភាពនេះ អត្ថប្រយោជន៍សេដ្ឋកិច្ចជាតិពីការបូមធនធានធម្មជាតិដ៏មានតម្លៃនេះ ជាធម្មតាមិនមានភាពច្បាស់លាស់ ។

## បណ្តាក្រុមហ៊ុនដែលប្រតិបត្តិការនៅក្នុងវិស័យខ្សាច់ ក៏ដូចជាភ្នាក់ងារចេញបទបញ្ញត្តិរបស់ប្រទេសកម្ពុជា កំពុងព្រងើយកន្តើយថែរក្សាការពារ បរិស្ថាន និងសង្គមជាតិរបស់ខ្លួន និងការអនុវត្តប្រសើរបំផុតនៃឧស្សាហកម្មជាអន្តរជាតិ ។ ផលវិបាកនៃបរិស្ថាន កំពុងបំផ្លិចបំផ្លាញធំធេងណាស់ ។

- អាជ្ញាប័ណ្ណបូមខ្សាច់ កំពុងត្រូវបានផ្តល់ឱ្យនៅតាមបណ្តាទន្លេ និងមាត់សមុទ្រតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ។ សម្បទានជាច្រើន ត្រូវបាន ផ្តល់ឱ្យនៅក្នុងតំបន់ការពារ និងជិតបរិវេណប្រព័ន្ធអេកូឡូហ្ស៊ី និងលំនៅដែលមានសារៈសំខាន់ជាអន្តរជាតិរបស់ប្រភេទជលជាតិដែលរងគ្រោះថ្នាក់បំផុតមួយចំនួនរបស់ពិភពលោក ។ គ្រាន់តែមួយថ្ងៃ នាវាបូមខ្សាច់ចំនួនប្រាំបួន ត្រូវបានប្រទះឃើញដោយគ្លូបលវីតណេសនៅក្នុង តំបន់ការពារមួយ ។
- ស្របពេលជាមួយគ្នានេះដែរ ប្រជានេសាទក្នុងតំបន់ត្អូញត្អែរថា ជីវភាពរបស់ពួកគេត្រូវបានបំផ្លិចបំផ្លាញ ដោយសារការប្រមូលផលត្រី និងក្តាម បានធ្លាក់ចុះយ៉ាងរហ័ស ចាប់តាំងពីនាវាបូមខ្សាច់បានមកដល់ ។
- ការព្រងើយកន្តើយថែរក្សាការពារទាំងនេះ គឺជាការបំពានបញ្ញត្តិនៃច្បាប់ជាតិរបស់ប្រទេសកម្ពុជា ការប្តេជ្ញាចិត្តជាអន្តរជាតិក្នុងការការពារសិទ្ធិ មនុស្ស កាតព្វកិច្ចអភិរក្សជីវចំរុះ និងការអនុវត្តគ្រប់គ្រងបរិស្ថានប្រសើរបំផុតនៃឧស្សាហកម្មបូមខ្សាច់ ។

## ប្រទេសសិង្ហបុរី មិនកំពុងធ្វើបានគ្រប់គ្រាន់ដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់ខ្សាច់របស់ប្រទេសកម្ពុជា ហើយចំណុចនេះធ្វើឱ្យ អន្តរាយដល់តួនាទីរបស់ខ្លួនជា អ្នកនាំមុខផ្នែកបរិស្ថាននៅក្នុងតំបន់ ។

- ទោះបីជាមានគោលនយោបាយទំនើបបំផុតសម្រាប់ចេរភាពបរិស្ថាននៅក្នុងតំបន់ក៏ដោយ បណ្តាភ្នាក់ងាររដ្ឋាភិបាលរបស់ប្រទេសសិង្ហបុរី ហាក់ បីដូចជាយកធនធានខ្សាច់តាមរយៈ ក្រុមហ៊ុនដែលមានកិច្ចព្រមព្រៀងទិញខ្សាច់ពីបណ្តាក្រុមហ៊ុនរបស់ប្រទេសកម្ពុជា ដែលគ្រប់គ្រងដោយមន្ត្រី ថ្នាក់ខ្ពស់ៗ ហើយប្រតិបត្តិការរបស់ពួកគេ ហាក់បីដូចជាព្រងើយកន្តើយថែរក្សាការពារបរិស្ថាន និងសង្គម ។ ចំណុចនេះ :
  - ហាក់បីដូចជាមិនអនុវត្តតាមតម្រូវការដែលថា បណ្តាក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរីដែលប្រតិបត្តិការក្រៅប្រទេស ត្រូវអនុវត្តតាម ក្របខណ្ឌច្បាប់របស់ប្រទេសប្រភពដើម

    - មិនស្របតាមតម្រូវការលទ្ធកម្មរបស់រដ្ឋាភិបាលមួយចំនួន ក្នុងការដាក់ជូននូវការវាយតម្លៃបរិស្ថាននៃសម្បទានរ៉ែខ្សាច់ និង
    - ធ្វើឱ្យអន្តរាយដោយផ្ទាល់ដល់ការប្តេជ្ញាចិត្តចំពោះចេរភាពដែលបានរៀបរាប់របស់រដ្ឋាភិបាល ។
- ការយកធនធានខ្សាច់ប្រកបដោយចេរភាពពីតំបន់ (ដែលត្រូវបានបញ្ជាក់ដោយការវាយតម្លៃផលប៉ះពាល់បរិស្ថាន) ត្រូវបានស្នើឡើងនៅក្នុងសភារបស់ប្រទេសសិង្ហបុរី តែកិច្ចពិភាក្សាបានសន្និដ្ឋានថា រដ្ឋាភិបាលមិនបានពិចារណាសមរម្យ ដើម្បីដាក់បញ្ញត្តិពីតម្រូវការដល់បណ្តា អ្នកនាំចេញ ។
- គ្លូបលវីតណេស បានជួបប្រជុំជាមួយរដ្ឋាភិបាលប្រទេសសិង្ហបុរីនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ដើម្បីពិភាក្សាពីពាណិជ្ជកម្មខ្សាច់ ។ ពួកគេបានព្រមព្រៀងជួបប្រជុំម្តងទៀតនៅក្នុងខែ មិនា ឆ្នាំ 2010 ដើម្បីពិភាក្សាពីលទ្ធផលរកឃើញពីការស៊ើបអង្កេតនេះ តែបន្ទាប់មកបានសម្រេចថា កិច្ចប្រជុំតាមដានអាចមិនមានភាពចាំបាច់ ហើយបានឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះបណ្តាសំណួរទាំងឡាយ ។
- នៅក្នុងខែ មិថុនា ឆ្នាំ 2010 ប្រទេសសិង្ហបុរី នឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំបណ្តាទីក្រុងលើពិភពលោក ដើម្បីបង្ហាញពីភាពជាអ្នកនាំមុខផ្នែក បរិស្ថានរបស់ខ្លួន ។ គ្លូបលវីតណេស នឹងអំពាវនាវឱ្យប្រទេសសិង្ហបុរីបង្កើតតម្រូវការស៊ើបអង្កេតសម្រាប់បណ្តាក្រុមហ៊ុន និងភ្នាក់ងាររបស់ ប្រទេសសិង្ហបុរីសម្រាប់ការយកធនធានខ្សាច់ជាភស្តុតាងនៃភាពជាអ្នកនាំមុខនេះ ។

## ម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា មិនកំពុងធ្វើបានគ្រប់គ្រាន់ដើម្បីជម្រុញឱ្យមានអភិបាលកិច្ចធនធានធម្មជាតិរបស់ប្រទេសកាន់តែប្រសើរនោះទេ ។

- គ្លូបលវីតណេសជឿជាក់ថា បរាជ័យនៃអភិបាលកិច្ចនៅក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជា ប្រាប់ឱ្យដឹងពីបរាជ័យរបស់ម្ចាស់ជំនួយអន្តរជាតិកាន់តែខ្លាំងឡើង ក្នុងការប្រើប្រាស់អានុភាពរបស់ពួកគេដើម្បីធ្វើឱ្យប្រាកដថារដ្ឋាភិបាលប្រទេសកម្ពុជាគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពនូវទ្រព្យសម្បត្តិធម្មជាតិដ៏មានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍នេះ សម្រាប់គោលដៅកាត់បន្ថយភាពក្រីក្រ ។ ស្របពេលដែលរដ្ឋាភិបាល និងសហគមន៍ ម្ចាស់ជំនួយអន្តរជាតិ រៀបចំសំណើ និងកិច្ចសន្យាផ្តល់ជំនួយអភិវឌ្ឍន៍នៅឯវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍ប្រទេសកម្ពុជាដែលនឹងមកដល់នា ពេលខាងមុខ គ្លូបលវីតណេសសូមអំពាវនាវឱ្យម្ចាស់ជំនួយធ្វើឱ្យប្រាកដថា មូលនិធិត្រូវបានផ្តល់ជូនបន្ទាប់ពីរដ្ឋាភិបាលសម្រេចបានកំណែទម្រង់គ្រប់គ្រងធនធានធម្មជាតិ និងប្រាក់ចំណូលរបស់ពួកគេប្រកបដោយតម្លាភាព និងភាពទទួលខុសត្រូវតែប៉ុណ្ណោះ ។



គ្លូបលវីតណេស

ប្រតិបត្តិការបូមខ្សាច់ ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 នៅក្នុងតំបន់សម្បទានរបស់ក្រុមហ៊ុន L.Y.P. Group នៅស្ទឹងតាតៃ ខេត្តកោះកុង ។ ការបូមខ្សាច់ កើតឡើងនៅខាងស្តាំក្បែរព្រៃកោងកាងដែលត្រូវបានការពាររបស់ខេត្តកោះកុង និងនៅក្នុងជម្រកសត្វព្រៃពាមក្រសោប ។

# 1. ខ្សាច់ត្រូវបានធ្វើឱ្យវិនាសអន្តរាយ :

## វិស័យខ្សាច់របស់ប្រទេសកម្ពុជាត្រូវបានថ្លែងដោយគ្លូបលវីតណេសនៅក្នុង *ប្រទេសជាតិលក់*

នៅក្នុងខែ កុម្ភៈ ឆ្នាំ 2009 គ្លូបលវីតណេសបានចេញផ្សាយឯកសារ *ប្រទេសជាតិលក់ : របៀបដែលពួកវរជនកម្ពុជាបានចាប់ក្ដាប់ឧស្សាហកម្មដកស្រង់ធនធានរបស់ប្រទេស ។*[2] ដោយបានបង្កើតជោគវាសនារបស់ពួកគេពីការកាប់ឈើដ៏ច្រើននៃធនធានព្រៃឈើរបស់ប្រទេស របាយការណ៍នេះបានកត់ត្រាពីរបៀបដែលពួកវរជនកម្ពុជា បានពង្រីកផលប្រយោជន៍ពាណិជ្ជកម្មរបស់ពួកគេដើម្បីគ្របដណ្ដប់ទម្រង់ទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត - ដី ជលផល កោះត្រូពិច និងឆ្នេរសមុទ្រ រ៉ែ និងប្រេងឥន្ធនៈ ។ របាយការណ៍បានកត់ត្រាពីរបៀបដែលសិទ្ធិចំពោះធនធានទាំងនេះ ត្រូវបានផ្ដល់ជូនជា សម្ងាត់ និងក្នុងលក្ខណៈដែលគួរឱ្យសង្ស័យ ។ វាបានបង្ហាញភស្តុតាងថា ម្ចាស់ទទួលប្រយោជន៍ពីរ៉ែ និងក្រុមហ៊ុនដែលបានទទួលអណ្ដូងរ៉ែប្រេង មាន ទំនាក់ទំនងយ៉ាងរឹងមាំជាមួយយោធា និងរដ្ឋាភិបាល ។ រង្វាន់ផ្នែកហិរញ្ញវត្ថុដែលបានបង់ឱ្យរដ្ឋាភិបាលដើម្បីធានាឱ្យបានសម្បទានដែលមានទឹកប្រាក់ សរុបរាប់លានដុល្លារអាមេរិក ហាក់បីដូចជាមិនបានទៅដល់រតនាគារជាតិទេ ។[3ii] ដោយសារសេដ្ឋកិច្ចតូចរបស់ប្រទេសកម្ពុជា ប្រសិនបើមូលនិធិ ទាំងនេះបានទៅដល់រតនាគារជាតិ នោះពួកគេអាចរួមចំណែកបានយ៉ាងច្រើនដល់គោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រទេស ។



ព្រឹទ្ធសមាជិក លី យ៉ុង ផាត់ ដែលបានរាយការណ៍នៅក្នុងប្រទេសសម្រាប់លក់ថា គ្រប់គ្រងវិស័យខ្សាច់របស់ខេត្តកោះកុង តាមរយៈក្រុមហ៊ុនរបស់គាត់ឈ្មោះ L.Y.P. Group ។

ករណីមួយក្នុងចំណោមបណ្ដាករណីដែលបានស៊ើបអង្កេតនៅក្នុងឆ្នាំ 2008 គឺឧស្សាហកម្មរុករករ៉ែខ្សាច់របស់ខេត្តកោះកុង ។ ប្រតិបត្តិការ "វិស័យ ខ្សាច់"[iii] ទាំងមូល ហាក់បីដូចជាត្រូវបានគ្រប់គ្រងដោយព្រឹទ្ធសមាជិកគណបក្ស CPP ឈ្មោះ លី យ៉ុងផាត់ តាមរយៈក្រុមហ៊ុនរបស់គាត់ L.Y.P. Group Co Ltd ហើយហេតុនេះហើយ គឺជាឧទាហរណ៍ មួយផ្សេងទៀតរបស់វរជន ទាក់ទងនឹងឧស្សាហកម្មរុករករ៉ែរបស់ ប្រទេសកម្ពុជា ។[4] ភស្តុតាង បានបង្ហាញពីស្ថានភាពស៊ាំញ៉ាំមួយ ពាក់ព័ន្ធនឹងអ្នកទិញ និងអ្នកលក់ជាច្រើន ដែលបានប៉ាន់ស្មានថាមានតម្លៃប្រចាំឆ្នាំសរុបយ៉ាងហោចណាស់ 8.6 លានដុល្លារអាមេរិក នៅចំណុចដកស្រង់ធនធាន នៅក្នុងប្រទេសកម្ពុជា និង 35 លានដុល្លារអាមេរិកនៅក្នុង តម្លៃរាយក្នុងប្រទេសសិង្ហបុរី នៅក្នុង ឆ្នាំ 2008.[5 iv]




*ប្រទេសជាតិលក់* ក៏បានពិនិត្យផងដែរពីតួនាទីនៃម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជា នៅក្នុងឧស្សាហកម្មដកស្រង់ធនធានដែលមានការកើន ឡើងរបស់ប្រទេសនេះផងដែរ ។ ប្រទេសកម្ពុជា បន្តជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសក្រីក្របំផុតរបស់ពិភពលោក ហើយផ្អែកខ្លាំងទៅលើ ជំនួយបរទេស ដើម្បីបំពេញចន្លោះថវិកាជាតិ ។[6] ផលប៉ះពាល់ជាក់ស្ដែងពីជំនួយអភិវឌ្ឍន៍នេះ នៅតែត្រូវបានរារាំងដោយស្ថាប័នរដ្ឋាភិបាល និងអំពើ ពុករលួយកម្រិតខ្ពស់ ។ ការចរចារ និងការពិភាក្សាជាច្រើនឆ្នាំនៅឯកិច្ចប្រជុំម្ចាស់ជំនួយ-រដ្ឋាភិបាល មាននូវឥទ្ធិពលតិចតួចលើភាពមិនត្រឹមត្រូវនៃ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋាភិបាលប្រទេសកម្ពុជា ។ ចំណុចប្រសើរៗជាច្រើន បានរៀបចំឆ្ពោះទៅកាន់ការធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និង អភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា តែងតែត្រូវបានលុបចោល និងមិនបានបំពេញ តែជំនួយរបស់ម្ចាស់ជំនួយបានបន្តហូរចូលជានិច្ច ។[7] គ្លូបលវីតណេស បានសន្និដ្ឋានថា ប្រការនេះមិនបានឱ្យសញ្ញាល្អឡើយសម្រាប់លទ្ធភាពរបស់រដ្ឋាភិបាលប្រទេសកម្ពុជា ក្នុងការគ្រប់គ្រងធនធានធម្មជាតិរបស់ខ្លួន ឆ្ពោះ ទៅកាន់គោលដៅអភិវឌ្ឍន៍ជាតិ ។ ម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជា ត្រូវតែចាត់វិធានការណ៍ដើម្បីដោះស្រាយបញ្ហានេះ ឬបើពុំនោះទេនៅតែ ប្រឈមនឹងការបាត់បង់កាលានុវត្តភាពប្រសើរបំផុតមួយជំនាន់ ដើម្បីយកប្រទេសកម្ពុជាចេញពីភាពក្រីក្រ ។

ii ផ្អែកតាមរបាយការណ៍ចំណូលឆ្នាំ 2006 ឬឆ្នាំ 2007 ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ។
iii របាយការណ៍នេះប្រើប្រាស់ពាក្យ "វិស័យខ្សាច់" ដើម្បីពណ៌នាអំពីឧស្សាហកម្មរុករករ៉ែខ្សាច់នៅក្នុងប្រទេសកម្ពុជា ហើយបណ្ដាភ្នាក់ងាររបស់រដ្ឋាភិបាល និងក្រុមហ៊ុនជាច្រើនបានពាក់ព័ន្ធនឹង វិស័យនេះ ។
iv កម្មករនៅដេប៉ូមួយបានប្រាប់គ្លូបលវីតណេសថា ក្នុងបីថ្ងៃ ពួកគេអាចចាក់បំពេញនាវាចំណុះ 15,000 តោនមួយសម្រាប់ការនាំចេញ ។ អ្នកលក់ខ្សាច់ម្នាក់បានដាក់តម្លៃខ្សាច់នៅក្នុង ខេត្តកោះកុងឆ្នាំ 2008 ថាមានតម្លៃ 11 ដុល្លារអាមេរិកក្នុងមួយតោន ហើយដោយសន្មតថាជាអត្រាមធ្យមក្នុងមួយកប៉ាល់ទំហំនេះចេញពីប្រទេសកម្ពុជារៀងរាល់សប្ដាហ៍ នេះអាចមានន័យ ថា ប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់ឧស្សាហកម្មខ្សាច់របស់ខេត្តនឹងមានចំនួន 8.6 លានដុល្លារអាមេរិក ។ ពេលដែលនៅក្នុងប្រទេសសិង្ហបុរី តម្លៃខ្សាច់គុណនឹងបួន ដែលស្មើនឹង 45 ដុល្លារ អាមេរិកក្នុងមួយតោន នោះនាំឱ្យតម្លៃលក់រាយនៃការនាំចេញរបស់ខេត្តកោះកុងទៅកាន់ទីនោះមាន 35 លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ ។



នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសពី "ការហាមឃាត់" ការនាំខ្សាច់ចេញ នៅក្នុងខែ ឧសភា ឆ្នាំ 2009 ដោយមានគោលបំណងកែលំអបញ្ញត្តិនៃច្បាប់នៃវិស័យនេះ និងធានាឱ្យបានការការពារបរិស្ថាន

គ្លូបលវិតណេស

បីខែបន្ទាប់ពីការបោះពុម្ពផ្សាយ *ប្រទេសជាតិលក់* ហ៊ុន សែន នាយករដ្ឋមន្ត្រីប្រទេសកម្ពុជាបានប្រកាសហាមការនាំចេញខ្សាច់ ដែលត្រូវបានសន្មតថា ជាការឆ្លើយតបនឹងការតវ៉ាក្នុងតំបន់ ដោយមានគោលបំណងកែលំអបទបញ្ញត្តិនៃវិស័យនេះ និងធានាឱ្យបានការការពារបរិស្ថាន។[8] គ្លូបលវិតណេស បានស្វាគមន៍ចំពោះវិធានការណ៍នេះ តែប្តេជ្ញាចិត្តស៊ើបអង្កេតបន្ថែមទៀតពីបណ្តាលក្ខខណ្ឌនៃបទបញ្ញត្តិថ្មីនេះ និងការអនុវត្តរបស់វា។ អ្វីដែលយើង បានរកឃើញគឺថា ជាការពិតណាស់ខ្លឹមសារនៃច្បាប់គ្រាន់តែហាមការនាំចេញ*ខ្សាច់ទន្លេ* តែប៉ុណ្ណោះ មិនមែនខ្សាច់សមុទ្រនោះឡើយ។ ជាងនេះទៀត ភស្តុតាងដែលបានប្រមូលអំឡុងឆ្នាំ 2009 និង 2010 បង្ហាញថា គណៈកម្មការអន្តរក្រសួងដែលមានកាតព្វកិច្ចអនុវត្តបទបញ្ញត្តិនេះ បានបន្ធូរបន្ថយ ព្រមផ្តល់អាជ្ញាប័ណ្ណធ្វើអាជីវកម្មការនាំចេញខ្សាច់ប្រភេទ*ទាំងពីរ* ស្របជាមួយនឹងការបរាជ័យធានាឱ្យបានការអនុវត្តតាមក្របខណ្ឌច្បាប់បរិស្ថាន និង សេដ្ឋកិច្ចសង្គមផ្សេងទៀតរបស់ប្រទេសកម្ពុជាផងដែរ។

ផ្នែកដំបូងនៃរបាយការណ៍នេះ បង្ហាញភស្តុតាងពីការស៊ើបអង្កេតរបស់យើងលើវិស័យខ្សាច់របស់ប្រទេសកម្ពុជា។ ផ្នែកបន្ទាប់ៗ វាយតម្លៃ ផលប៉ះពាល់នៃពាណិជ្ជកម្មនេះលើបរិស្ថាន និងជីវភាពរស់នៅក្នុងតំបន់ ព្រមទាំងវិភាគក្របខណ្ឌច្បាប់របស់ប្រទេសកម្ពុជា និងបទបញ្ញត្តិថ្មីៗដែល ចេញដោយខុទ្ទកាល័យនាយករដ្ឋមន្ត្រីសំរាប់វិស័យនេះ។ ផ្នែកបន្ទាប់ បង្ហាញនូវតួនាទីដែលប្រទេសកម្ពុជាមានតួនាទីនៅក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជា។ ជាចុងក្រោយ តួនាទីនៃសហគមន៍ម្ចាស់ជំនួយអន្តរជាតិត្រូវបានវាយតម្លៃយោងតាមតម្រូវការកែលំអអភិបាលកិច្ចនៃធនធានធម្មជាតិរបស់ប្រទេសកម្ពុជា។ របាយការណ៍ បញ្ចប់ដោយការផ្តល់អនុសាសន៍សម្រាប់រាល់ភ្នាក់ងារទាំងអស់ដែលពាក់ព័ន្ធនៅក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជា។



គ្លូបលវិតណេស

ប្រតិបត្តិការបូមខ្សាច់ប្រមាណ 30km ពីឆ្នេរសមុទ្រខេត្តកោះកុង ប្រទេសកម្ពុជា។ គ្លូបលវិតណេសប៉ាន់ស្មានពីពាណិជ្ជកម្មខ្សាច់របស់ខេត្តកោះកង់ថាមាន 28.7 លានដុល្លារប្រចាំឆ្នាំនៅចំណុចស្រង់ធនធាននៅក្នុងឆ្នាំ 2009។

# 2. អាហារដែលទទួលទានធ្វើឱ្យមានជំងឺ :

## អ្នកដើរតួនាទីសំខាន់នៅក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ 2009 - 2010

ចាប់តាំងពីមានការប្រកាសដោយខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រីស្តីពីបញ្ញត្តិនៃច្បាប់សំរាប់វិស័យនេះ ជាការពិតណាស់ ការបូមខ្សាច់បានពង្រីកតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា។ ដូចដែលបានកត់ត្រាពីមុនដោយគ្លូបលវីតណេស ដោយសារការខ្វះខាតនូវតម្លាភាពនៅក្នុងការផ្តល់សម្បទាន វាមិនមានភាពច្បាស់លាស់ថាតើបណ្តាក្រុមហ៊ុនទទួលបានឱកាសដ៏សម្បើមនេះតាមរបៀបណានោះឡើយ។ ប្រតិបត្តិការបូមខ្សាច់មួយចំនួន ត្រូវបាន ផ្តល់ឱ្យនូវអាជ្ញាប័ណ្ណនៅក្នុងតំបន់ការពារ។ ជាងនេះទៀត ប្រភពពីឧស្សាហកម្មមួយបានប្រាប់គ្លូបលវីតណេសថា បណ្តាក្រុមហ៊ុនដែលនាំចេញខ្សាច់ពី ប្រទេសកម្ពុជា ត្រូវតែធ្វើការបង់ប្រាក់ចំណាយក្រៅផ្លូវការឱ្យអាជ្ញាធរទាំងឡាយរបស់រដ្ឋាភិបាលប្រទេសកម្ពុជា។[9] តួលេខពាណិជ្ជកម្មខ្សាច់ក្នុងតំបន់ និងការចុះទៅដល់មូលដ្ឋានដោយផ្ទាល់របស់គ្លូបលវីតណេសបង្ហាញថា ប្រទេសសិង្ហបុរីគឺជាគោលដៅចំបងនៃវិស័យខ្សាច់នាំចេញរបស់ប្រទេស កម្ពុជា។ តម្លៃប្រចាំឆ្នាំនៃពាណិជ្ជកម្មនេះ ត្រូវបានប៉ាន់ស្មានថាមាន 28.7 លានដុល្លារអាមេរិកនៅក្នុងប្រទេសកម្ពុជាពីខេត្តកោះកុងតែមួយគត់ និង 248 លានដុល្លារអាមេរិកនៅក្នុងតម្លៃលក់រាយក្នុងប្រទេសសិង្ហបុរី។

បណ្តាក្រុមហ៊ុនដែលត្រូវបានស៊ើបអង្កេតស្ទើរតែទាំងអស់ មានទំនាក់ទំនងជាមួយប្រទេសសិង្ហបុរី ហើយមួយចំនួនត្រូវបានចុះបញ្ជីជាមួយភ្នាក់ងាររដ្ឋាភិបាលរបស់ប្រទេសសិង្ហបុរី ដើម្បីផ្គត់ផ្គង់សម្ភារៈសំណង់ រួមទាំងខ្សាច់ផងដែរ។ ជាងនេះទៀត គ្លូបលវីតណេសបានឃើញអាជ្ញាប័ណ្ណបូម និងនាំចេញខ្សាច់របស់ប្រទេសកម្ពុជា ដែលមានត្រា និងហត្ថលេខារបស់តំណាងស្ថានទូតប្រទេសសិង្ហបុរីនៅក្នុងប្រទេសកម្ពុជា។[10] ផ្តោតទៅលើ ពាណិជ្ជកម្មខ្សាច់ខេត្តកោះកុង ហាក់បីដូចជាស្ថិតក្រោមការគ្រប់គ្រងរបស់មហាសេដ្ឋីល្បីឈ្មោះបំផុតរបស់ប្រទេសកម្ពុជាពីររូប - ព្រឹទ្ធសមាជិក លី យ៉ុងផាត់ និងព្រឹទ្ធសមាជិក ម៉ុង ឬទ្ធី។ ការពាក់ព័ន្ធរបស់ពួកគេត្រូវបានកត់ត្រានៅខាងក្រោម។ គ្លូបលវីតណេសបានសរសេរលិខិតទៅកាន់ក្រុមហ៊ុន និងបុគ្គលទាំងអស់ដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះ និងបានទទួលការឆ្លើយតបតែពីរគត់ ពីក្រុមហ៊ុន **Mong Reththy Group Co Ltd** និងមួយទៀតពីក្រសួងអភិវឌ្ឍន៍ជាតិនៃរដ្ឋាភិបាលប្រទេសសិង្ហបុរី។

### ក្រុមហ៊ុន L.Y.P. Group Co Ltd

ក្រុមហ៊ុន L.Y.P. Group Co Ltd (L.Y.P. Group) និងម្ចាស់របស់ក្រុមហ៊ុន ព្រឹទ្ធសមាជិកគណបក្ស CPP លី យ៉ុងផាត់ បានរក្សាការគ្រប់គ្រង លើសលុបលើវិស័យខ្សាច់របស់ខេត្តកោះកុង ដែលត្រូវបានបង្ហាញនៅក្នុងប្រទេសជាតិលក់។ នៅថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2009 ក្រុមហ៊ុនបានទទួល ការអនុញ្ញាតពី "គណៈកម្មការគ្រប់គ្រងធនធានខ្សាច់"[v] ("គណៈកម្មការខ្សាច់") ស្ថិតក្រោមក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ឱ្យបន្ត ប្រតិបត្តិការខ្សាច់របស់ខ្លួនសម្រាប់ការនាំចេញ។[11]



©គ្លូបលវីតណេស

ការបូមខ្សាច់ដែលបានថតចំនួន 02 របស់ក្រុមហ៊ុន Riverton ទៅក្នុងកប៉ាល់កាន់តែធំនៅខាងក្រោយវា នៅក្នុងខែ វិច្ឆិកា នៅតំបន់សម្បទានរបស់ក្រុមហ៊ុន L.Y.P. Group នៅលើទន្លេកោះពោធិ ខេត្តកោះកុង ប្រទេសកម្ពុជា។ ក្រុមហ៊ុន Riverton គឺជាក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរី ដែលបានស្គាល់ដោយគ្លូបលវីតណេសថានាំចេញខ្សាច់ពីប្រទេសកម្ពុជា។

v សំណៅបកប្រែក្រៅផ្លូវការនៃ "សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងធនធានខ្សាច់" ពីឆ្នាំ 2006 ប្រើប្រាស់ពាក្យថា "គណៈកម្មការ" ទោះយ៉ាងណាឯកសារពីក្រសួងធនធាន ទឹក និងឧតុនិយម ហៅអង្គភាពនេះថា "គណៈកម្មាធិការ" ដែលជាពាក្យត្រូវបានប្រើប្រាស់ទាំងស្រុងក្នុងរបាយការណ៍នេះ។

នេះហាក់បីដូចជាការពន្យាពេលមួយលើអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន L.Y.P. Group ពីឆ្នាំ 2007 និង 2008 ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ។ ការអនុញ្ញាតខែ កក្កដា ឆ្នាំ 2009 នេះ អនុញ្ញាតឱ្យក្រុមហ៊ុនបូមខ្សាច់ជម្រៅរវាង 0.5 ទៅ 6m នៅក្នុងស្ទឹងបី - ស្រែអំបិល តាតៃ និងកោះពោធិ (ត្រូវបានបង្ហាញលើផែនទី 1 និង 2 ខាងក្រោម) ។[13] ទោះយ៉ាងណា អាជ្ញាធរខេត្តបានប្រាប់គ្លូបលវីតណេសថា ការពិតក្រុមហ៊ុនគ្រប់គ្រងរាល់ទីតាំងបូមខ្សាច់របស់ខេត្តកោះកុង ទាំងអស់ ។[14] ក្រុមហ៊ុនក៏មានដេប៉ូខ្សាច់ធំៗពីរនៅម្ខាងស្ទឹងកោះពោធិ ឆ្លងពីក្រុងកោះកុង ។[15] លិខិតអនុញ្ញាតសម្រាប់ការបូមខ្សាច់នៅក្នុងបណ្ដាស្ទឹងទាំងបីនេះ គឺជាការបំពានដោយផ្ទាល់លើប្រការ 1.2 នៃ *សេចក្ដីសម្រេចពាក់ព័ន្ធនឹងការកម្រិតលើការធ្វើអាជីវកម្មខ្សាច់* ("សេចក្ដីសម្រេចពីការធ្វើ អាជីវកម្មខ្សាច់") ដែលបានហាមការបូមខ្សាច់ទន្លេសម្រាប់ការនាំចេញ ។[vi16] នេះនាំឱ្យមានចម្ងល់ពីយុត្ដាធិការ និងសមត្ថភាពរបស់គណៈកម្មការ ខ្សាច់ ដែលទទួលខុសត្រូវទាំងការអនុវត្តបំរាមដែលមាន និងការចេញលិខិតអនុញ្ញាតនាំចេញខ្សាច់ជាថ្មី ។

ក្រុមហ៊ុន L.Y.P. Group បានចុះកិច្ចសន្យាបន្តនូវសិទ្ធិបូម និងនាំចេញខ្សាច់ទាំងនេះទៅឱ្យក្រុមហ៊ុនជាច្រើន យោងតាមភស្ដុតាងដែលបានពិនិត្យដោយគ្លូបលវីតណេស ។ ក្រុមហ៊ុនមួយឈ្មោះថា Winton Enterprises Ltd (Winton) ប្រតិបត្តិការជាដៃគូជាមួយក្រុមហ៊ុន L.Y.P. Group ដើម្បីនាំចេញខ្សាច់ទៅកាន់ប្រទេសសិង្ហបុរី ហើយនាវារបស់ក្រុមហ៊ុនត្រូវបានថតដោយគ្លូបលវីតណេស ដោយមានផ្ទុកខ្សាច់នៅក្នុងតំបន់សម្បទាន ស្ទឹងតាតៃរបស់ក្រុមហ៊ុន L.Y.P. Group នៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ។[17] ក្រុមហ៊ុន Winton ត្រូវបានចុះបញ្ជីនៅទីក្រុងហុងកុង តែនាយកពីរក្នុងចំណោមនាយកជាច្រើនរបស់ក្រុមហ៊ុនគឺជាជនជាតិសិង្ហបុរី ។[18] ជនជាតិសិង្ហបុរីដែលមានឈ្មោះ និងអាសយដ្ឋានដូចគ្នានៅក្នុងប្រទេសសិង្ហបុរីដែលជានាយកម្នាក់ក្នុងចំណោមនាយកទាំងនេះ ក៏គឺជានាយកក្រុមហ៊ុនប្រទេសសិង្ហបុរីមួយឈ្មោះ




សេចក្ដីចំលងពីការយល់ព្រមជាគោលការណ៍របស់ក្រុមហ៊ុន LYP Group ដើម្បីបូមខ្សាច់នៅក្នុងស្រែអំបិល តាតៃ និងទន្លេកោះពោធិ ចេញដោយក្រសួងធនធានទឹក និងឧតុនិយម ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2009 ។

ថាក្រុមហ៊ុន Camb Resources PTE Ltd ដែលត្រូវបានចុះបញ្ជីនៅអាជ្ញាធរសាងសង់ និងសំណង់ (BCA) របស់ប្រទេសសិង្ហបុរី ដើម្បីផ្គត់ផ្គង់ *"សំភារៈសំណង់មូលដ្ឋាន"* ។[19] BCA ពណ៌នាខ្លួនឯងថាជា *"ភ្នាក់ងារស្ថិតក្រោមក្រសួងអភិវឌ្ឍន៍ជាតិ"* ទទួលខុសត្រូវគ្រប់គ្រងគម្រោងសាងសង់ ហើយ "បញ្ជីឈ្មោះអ្នកម៉ៅការ" របស់ខ្លួន គឺជាបញ្ជីឈ្មោះ ក្រុមហ៊ុនដែលបានចុះបញ្ជីជាមួយខ្លួន ដើម្បីបម្រើដល់តម្រូវការលទ្ធកម្មរបស់រដ្ឋាភិបាល ។[20] និយមន័យ *"សំភារៈសំណង់មូលដ្ឋាន"* របស់ BCA រួមមានខ្សាច់ផងដែរ ។[21]

ក្រុមហ៊ុនដែលបានចុះបញ្ជីនៅប្រទេសសិង្ហបុរី Riverton Group (S) PTE Ltd (Riverton) ក៏កំពុងបានធ្វើសកម្មភាពបូមខ្សាច់នៅក្នុងខេត្តកោះកុងផងដែរ ដែលប្រតិបត្តិការចេញពីការិយាល័យមួយនៅ Lam Dam ។[22] ប្រភពឧស្សាហកម្មមួយបានប្រាប់គ្លូបលវីតណេសថា Riverton បានចុះកិច្ចសន្យាបន្តដោយក្រុមហ៊ុន L.Y.P. Group ដើម្បីនាំចេញខ្សាច់ពីសម្បទានរបស់ខ្លួនទៅកាន់ប្រទេសសិង្ហបុរី




គ្លូបលវីតណេស

កប៉ាល់ Winton T188 ជាមួយនឹងកប៉ាល់បូមខ្សាច់ផ្សេងទៀតនៅខាងក្រោយ ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 នៅតំបន់សម្បទានរបស់ក្រុមហ៊ុន L.Y.P. Group នៅជ្រុងខាងត្បូងជម្រកសត្វព្រៃពាមក្រសោប និងតំបន់រុំាសារកោះកាពិ ខេត្តកោះកុង ប្រទេសកម្ពុជា ។ ក្រុមហ៊ុន Winton Enterprises ត្រូវបានរាយការណ៍faជាដៃគូជាមួយក្រុមហ៊ុន L.Y.P. Group ដើម្បីនាំចេញខ្សាច់ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសសិង្ហបុរី ។

vi អត្ថបទនេះ និងការវិភាគខ្លឹមសារនៃសេចក្ដីសម្រេចស្ដីពីការធ្វើអាជីវកម្មខ្សាច់ខាងក្រោមនេះ ផ្អែកទៅលើសំណៅបកប្រែពីភាសាខ្មែរទៅភាសាអង់គ្លេសក្រៅផ្លូវការ ។




រូបថត៖ គ្លូបលវីតណេស

នាវា Bina Sarana 68 នាវាសណ្តោង Bina Sarana 88 ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 នៅទន្លេកោះពោធិ ខេត្តកោះកុង ប្រទេសកម្ពុជា ។ ភ្លាមៗបន្ទាប់ពីនាវា Bina Sarana 88 បានចូលចតនៅក្នុងប្រទេសសិង្ហបុរី ។ ឯកសារជាច្រើនបានឱ្យដឹងថា នាវានេះ ត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុន L.Y.P. Group ដើម្បីដឹកខ្សាច់ចេញពីប្រទេសកម្ពុជា ទៅកាន់ប្រទេសសិង្ហបុរី ។

ហើយថាក្រុមហ៊ុនមាន កិច្ចសន្យាមួយដើម្បីផ្គត់ផ្គង់ក្រុមហ៊ុន Jurong Town Corporation (JTC) ។[23] ក្នុងការឆ្លើយឆ្លងជាមួយគ្លូបលវីតណេស រដ្ឋាភិបាលប្រទេស សិង្ហបុរីបានពណ៌នា JTC ថាជា *"ក្រុមប្រឹក្សាតាមច្បាប់ស្ថិតក្រោមក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មនៃរដ្ឋាភិបាលប្រទេសសិង្ហបុរី"* ។ គេហទំព័ររបស់ JTC ពណ៌នាខ្លួនឯងថាជា *"ភ្នាក់ងារពាក់កណ្តាលឯករាជ្យ"* ។[24] ក្រុមហ៊ុន Riverton ក៏ត្រូវបានចុះបញ្ជីនៅ ពជា របស់ប្រទេសសិង្ហបុរី ដើម្បីផ្គត់ផ្គង់សំភារៈសំណង់មូលដ្ឋានផងដែរ ។[25] នាវារបស់ក្រុមហ៊ុន Riverton ត្រូវបានថតដោយគ្លូបលវីតណេសថា កំពុងដឹកខ្សាច់នៅតំបន់សម្បទានរបស់ក្រុមហ៊ុន L.Y.P. Group នៅកោះពោធិ ។[26]

ភស្តុតាងបង្ហាញថា ក្រុមហ៊ុន L.Y.P. Group ក៏មានភាពជាដៃគូជាមួយក្រុមហ៊ុន Ta Chang Selindo Cambodia Co Ltd ជាក្រុមហ៊ុនមួយពាក់ព័ន្ធនឹងក្រុមហ៊ុន Selindo Global (S) PTE Ltd ដែលជាក្រុមហ៊ុនចុះបញ្ជីនៅប្រទេសសិង្ហបុរី ។[27] ក្រុមហ៊ុន Ta Chang Selindo Cambodia Co Ltd បញ្ជាក់ថាពីមុនបានផ្គត់ផ្គង់ខ្សាច់ឱ្យក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរី Song and Song ដែលគ្លូបលវីតណេសជឿជាក់ថាជា ក្រុមហ៊ុន Song and Song Resources PTE Ltd ។[28] ក្រុមហ៊ុននេះមានសញ្ជាតិខ្មែរ ដែលបានចុះឈ្មោះនាយកម្នាក់ក្នុងចំណោមនាយក ជាច្រើនរបស់ក្រុមហ៊ុន ហើយក៏ត្រូវបានចុះបញ្ជីនៅ BCA ដើម្បីផ្គត់ផ្គង់សំភារៈសំណង់មូលដ្ឋានផងដែរ ។[29]

គ្លូបលវីតណេសបានទទួលឯកសារជាច្រើនដែលបង្ហាញថា លើសពីប្រាំបីថ្ងៃនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ក្រុមហ៊ុន L.Y.P. Group ហាក់បីដូចជាបាននាំចេញខ្សាច់យ៉ាងហោចណាស់ 77,236 តោនទៅកាន់ប្រទេសសិង្ហបុរី តាមរយៈការដឹកជញ្ជូនប្រាំមួយលើក តាមក្រុមហ៊ុនដឹកជញ្ជូនបី ។[30] គ្លូបលវីតណេសជឿជាក់ថា មួយក្នុងចំណោមក្រុមហ៊ុនទាំងនេះគឺក្រុមហ៊ុន Teelek Resource Management ដែលជាក្រុមហ៊ុនមួយចុះបញ្ជីនៅក្នុងប្រទេសសិង្ហបុរីជាក្រុមហ៊ុនឥដ្ឋ និងខ្សាច់ ។[31]

មួយទៀតគឺក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរី Wan Qi PTE Ltd ដែលត្រូវបានចុះឈ្មោះនៅ BCA ដើម្បីផ្គត់ផ្គង់សំភារៈសំណង់មូលដ្ឋាន ។[32] គ្លូបលវីតណេស បានឃើញការចុះបញ្ជីទំនិញសម្រាប់នាវាដឹកទំនិញតាមសមុទ្រ Bina Sarana 88 ដែលធ្វើដំណើរពីកោះកុង ប្រទេសកម្ពុជា កាលពីថ្ងៃទី 17 ខែ វិច្ឆិកា ឆ្នាំ 2009 ដោយមានក្រុមហ៊ុន Wan Qi PTE ជាអ្នកទទួលបញ្ញើទុករបស់ខ្លួន ។[33][vii] ទំនិញរបស់ក្រុមហ៊ុនគឺខ្សាច់សមុទ្រ 3,200 តោន ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុន L.Y.P. Group ។ អំឡុងសប្តាហ៍ទីពីរនៃខែ វិច្ឆិកា

*...លើសពីប្រាំបីថ្ងៃនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ក្រុមហ៊ុន L.Y.P. Group ហាក់បីដូចជាបាននាំចេញខ្សាច់យ៉ាងហោចណាស់ 77,236 តោនទៅកាន់ប្រទេសសិង្ហបុរី តាមរយៈការដឹកជញ្ជូនប្រាំមួយលើក ...។*

vii និយមន័យនៃ អ្នកទទួលបញ្ញើទុក : "មនុស្ស ឬក្រុមហ៊ុន (ជាធម្មតា អ្នកទិញ)" ដែលត្រូវបានហៅដោយ អ្នកផ្ញើ (ជាធម្មតា អ្នកលក់) នៅក្នុងឯកសារដឹកជញ្ជូន (ដូចជា វិក្ក័យប័ត្រ airway bill ឬវិក្ក័យប័ត្រ bill of lading) ដែលជាភាគីមួយនៃការបញ្ជាទិញរបស់ខ្លួន បញ្ញើនឹងត្រូវបានដឹកជញ្ជូនដល់កំពង់ផែគោលដៅ ។ អ្នកទទួលបញ្ញើទុក ត្រូវបានចាត់ទុកថាជា ម្ចាស់នៃបញ្ញើសម្រាប់គោលបំណងដាក់ជូននូវប្រតិវេទន៍ពន្ធ និងសម្រាប់ការបង់ពន្ធ និងអាករ ។ ទោះយ៉ាងណាភាពជាម្ចាស់ (កម្មសិទ្ធិ) ផ្លូវការនៃបញ្ញើ ផ្ទេរទៅឱ្យអ្នកទទួលបញ្ញើទុកតែនៅ ពេលដែលការបង់ប្រាក់គ្រប់ក្នុងវិក្ក័យប័ត្ររបស់អ្នកលក់តែប៉ុណ្ណោះ ។ បញ្ជីវាយឈ្មោះ និងអាសយដ្ឋានអាជីវកម្ម (Business Directory) : http://www.businessdictionary.com/definition/consignee.html (ចូលមើលលើកចុងក្រោយថ្ងៃទី 22 ខែមិនា ឆ្នាំ 2010) ។

## ផែនទីទី 1: សម្បទានបូមខ្សាច់ដែលបានដឹង នៅក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ ប្រទេសកម្ពុជា




សម្បទានបូមខ្សាច់ដែលបានដឹង នៅតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា គ្រោងប្រើប្រាស់កូអរដោណេពីអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន។ ផែនទីទី 2 ផ្តោតទៅលើប្រតិបត្តិការបូមខ្សាច់នៅក្នុងខេត្តកោះកុង សំរាប់តំបន់ដែលបានបង្ហាញដោយស៊ុមនៅក្នុងផែនទីទី 1។

## ករណីទី 2: សម្បទាន និងប្រតិបត្តិការបូមខ្សាច់នៅជុំវិញជម្រកសត្វព្រៃពាមក្រសោបលំអិត




សម្បទានតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ត្រូវបានផ្តល់ឱ្យយ៉ាងច្បាស់សំរាប់ខ្សាច់ទន្លេ ទោះបីជាមានការហាមបូមខ្សាច់ទន្លេសំរាប់ការនាំចេញក៏ដោយ ក៏ដូចជាមាននៅក្នុង និងតាមព្រំដែនតំបន់ការពារផងដែរ ។ ចំណុចខ្មៅ បង្ហាញពីកន្លែងដែលគ្លូបលវីតណេស បានប្រទះឃើញការបូមខ្សាច់ដែលកើតឡើងនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ។ នៅមួយថ្ងៃ យ៉ាងហោចណាស់នាវាប្រាំបួន ត្រូវបានឃើញថាបូមខ្សាច់ និងផ្ទុកខ្សាច់ក្នុងនាវានៅខាងក្នុង ព្រំដែនជម្រកសត្វព្រៃពាមក្រសោប និងតំបន់រ៉ាំសារកោះកាពិ ។ នាវាបីក្នុងចំណោមទាំងនេះ មានអក្សរ “Singapore” នៅខាងលើគ្រោង ក្រោមឈ្មោះរបស់នាវា និងមួយមានទង់ជាតិប្រទេសសិង្ហបុរី ។

ឆ្នាំ 2009 នាវាត្រូវបានថតនៅលើទន្លេនៅ កោះពោធិ ដោយមានខ្សាច់កំពប់ពីគែមរបស់នាវា[34] ហើយនៅថ្ងៃទី 5 ខែ ធ្នូ នាវាបានចូលចតនៅកំពង់ផែប្រទេសសិង្ហបុរី ។[35] នៅថ្ងៃដដែល Bina Sarana 88 ត្រូវបានថតនៅក្នុងកោះពោធិ នាវាដឹកខ្សាច់ផ្សេងទៀតប្រាំមួយមានទំហំស្រដៀងគ្នា ក៏ត្រូវបានថតនៅតាមទន្លេ ដែលជាតំបន់ សម្បទានរបស់ក្រុមហ៊ុន L.Y.P. Group ។[36] រាល់នាវាដឹកទំនិញទាំងនេះ បានចូលចតនៅប្រទេសសិង្ហបុរីភ្លាមៗក្រោយមក ។[37]

គ្លូបលវីតណេសមានភស្តុតាងដែលបង្ហាញថា ការបង់ប្រាក់ចំណាយដ៏ច្រើន ត្រូវបានធ្វើឡើងដោយអ្នកម៉ៅការបន្តពីរ ដើម្បីធានាឱ្យបានសិទ្ធិរបស់ពួកគេដូចខាងក្រោម ។ ក្រុមហ៊ុនពីរបានបញ្ជាក់ថា ពួកគេត្រូវបានតម្រូវដោយក្រុមហ៊ុន L.Y.P. Group ឱ្យបង់ប្រាក់ 200,000 ដុល្លារអាមេរិកជា ប្រាក់តម្កល់ ដើម្បីធានាបាននូវកិច្ចសន្យាបន្តរបស់ពួកគេសម្រាប់ការលក់ខ្សាច់ពីសម្បទានបូមខ្សាច់របស់ក្រុមហ៊ុន L.Y.P. Group ។ គ្លូបលវីតណេសបានឃើញប័ណ្ណទទួលប្រាក់ដែលបញ្ជាក់ពីប្រតិបត្តិការនេះ ពីក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំងនេះ គឺក្រុមហ៊ុន Ta Chang Selindo Cambodia Co Ltd ។
ស្ថានភាពនៃការបង់ប្រាក់ចំណាយពីអាជីវកម្មទៅអាជីវកម្មទាំងនេះ គឺមិនមានភាពច្បាស់លាស់ឡើយ ។ ប្រាក់កម្រៃផ្លូវការដែលត្រូវបង់ឱ្យ បណ្តាអាជ្ញាធរសម្រាប់ការផ្ទេរអាជ្ញាប័ណ្ណធនធានរ៉ែដោយយោងតាម ប្រកាស គួរតែត្រឹមតែ 500 ដុល្លារអាមេរិក ក្នុងអាជ្ញាប័ណ្ណមួយតែប៉ុណ្ណោះ ។[39] គ្លូបលវីតណេស មិនអាចស្វែងរកបញ្ញត្តិនៃច្បាប់បន្ថែមទៀតណាមួយ ដែលរៀបរាប់លំអិតអំពីការបង់ប្រាក់ ចំណាយជាក់លាក់ទាំងនេះឡើយ ។ តម្រូវការដោយក្រុមហ៊ុន L.Y.P. Group និងម្ចាស់របស់ក្រុមហ៊ុន សម្រាប់ការបង់ប្រាក់ចំណាយដើម្បីធានាឱ្យ បានកិច្ចសន្យា ហាក់បីដូចជាធ្វើតាមនិន្នាការពីមុនដែលបានកំណត់ឃើញដោយគ្លូបលវីតណេស ។ របាយការណ៍ពីមុនបានកត់ត្រាពីវិធីដែលមន្ត្រីថ្នាក់ ខ្ពស់ម្នាក់ៗ - ដែលត្រូវបានផ្តល់ឱ្យនូវសម្បទានដ៏សម្បើមជាសម្ងាត់ - ត្រូវបានបង់ប្រាក់ឱ្យដោយអ្នកទាំងឡាយណា ដែលចង់ទទួលបានបណ្តាធនធាន ដែលគ្រប់គ្រងដោយរដ្ឋ ។[40] គ្លូបលវីតណេសបានសរសេរលិខិតទៅកាន់ក្រុមហ៊ុនពាក់ព័ន្ធទាំងពីរ តែមិនមានការឆ្លើយតបណាមួយ ត្រូវបានទទួលគិត មកទល់កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយនេះ ។

សំណុំអាជីវកម្មរបស់ព្រឹទ្ធសមាជិក លី យ៉ុងផាត់ និងក្រុមហ៊ុនរបស់គាត់មានវិសាលភាពដល់កាស៊ីណូ សណ្ឋាគារ និងសម្បទានដីសេដ្ឋកិច្ច ។ ការបណ្តេញចេញកសិករដោយបង្ខំប្រកបដោយហិង្សាដើម្បី ធ្វើផ្លូវសម្រាប់ការដាំអំពៅដោយក្រុមហ៊ុន បាននាំឱ្យមានការ រិះគន់ខ្លាំងពីក្រុមសិទ្ធិ មនុស្ស ។[41] នាពេលថ្មីៗនេះ ថ្ងៃទី 22 ខែ កុម្ភៈ ឆ្នាំនេះ




ប័ណ្ណទទួលប្រាក់ដែលបញ្ជាក់ពីការបង់ប្រាក់ចំណាយដែលបានធ្វើឡើងដោយក្រុមហ៊ុន Ta Chang Selindo Cambodia Co Ltd ទៅឱ្យក្រុមហ៊ុន L.Y.P. Group សំរាប់កក់ចំនួន US$200,000 ដើម្បីធានាឱ្យបានសិទ្ធិយកខ្សាច់ពីសម្បទានបូមខ្សាច់របស់ក្រុមហ៊ុន L.Y.P. Group ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា ក្រុមហ៊ុន L.Y.P. Group បានព្រមព្រៀងឧបត្ថម្ភ ដល់អង្គភាពចំនួនប្រាំមួយនៃកងយោធពលខេមរភូមិន្ទ ជា "ទំនាក់ទំនងឧបត្ថម្ភ" រវាងអង្គភាពទ័ព និងបណ្ដាក្រុមហ៊ុនឯកជន។ គ្លូបលវីតណេស បានបង្ហាញពីការបារម្ភយ៉ាងខ្លាំងអំពីការបង់ចំណាយប្រាក់នេះ ឱ្យយោធារបស់ប្រទេសកម្ពុជាដោយបណ្ដាអាជីវកម្មឯកជន នៅក្នុងការចេញផ្សាយព័ត៌មានកាលពីថ្ងៃទី 5 ខែ មិនា ឆ្នាំ 2010 ។[43] មួយខែបន្ទាប់ពីការជូនដំណឹងនេះ ក្រុមហ៊ុន L.Y.P. Group បានប្រើប្រាស់កងវរសេនាតូចលេខ 313 នៃកងយោធពលខេមរភូមិន្ទ ដែលខ្លួនកំពុងឧបត្ថម្ភតាមរយៈកិច្ចព្រមព្រៀងឧបត្ថម្ភ ឱ្យការពារដំណាំ ទប់ទល់នឹងបណ្ដាសហគមន៍ដែលតវ៉ាថា ដីគឺជារបស់ពួកគេស្របច្បាប់ ។[44]

គ្លូបលវីតណេសបានសរសេរលិខិតទៅកាន់ព្រឹទ្ធសមាជិក លី យ៉ុងផាត់ ក្នុងឋានៈជានាយកក្រុមហ៊ុន L.Y.P. Group នៅក្នុងខែ មិនា ឆ្នាំ 2010 ស្នើសុំយោបល់លើសេចក្ដីបញ្ជាក់អះអាងទាំងនេះ ។ មកទល់ពេលបោះពុម្ពផ្សាយនេះ មិនបានទទួលការឆ្លើយតបណាមួយឡើយ ។

ផែនទី 1 និង 2 បង្ហាញពីសម្បទានបូមខ្សាច់ដែលបានដឹងដោយគ្លូបលវីតណេសគិតត្រឹមខែ មិនា ឆ្នាំ 2010 ។ ដោយការមាននូវព័ត៌មានមិន គ្រប់គ្រាន់ក្នុងវិស័យសាធារណៈ គ្លូបលវីតណេសជឿជាក់ថា ផែនទីនេះមិនមានលក្ខណៈពេញលេញ ទោះបីយ៉ាងណាវាបង្ហាញពីវិសាលភាពនៃ សកម្មភាពបូមខ្សាច់នៅក្នុងខេត្តកោះកុង ហើយនិងតំបន់ជិតខាងនឹងប្រព័ន្ធអេកូឡូហ្ស៊ីសំខាន់ៗជាអន្តរជាតិ ។ សម្បទានរបស់ក្រុមហ៊ុន L.Y.P. Group ពង្រីកទាន់តែឆ្ងាយខ្សែទឹកខាងលើ និងមានទីតាំងនៅខាងក្នុងជម្រកសត្វព្រៃពាមក្រសោប និងតំបន់រ៉ាំសារកោះកាពិ ។ នៅមួយថ្ងៃយ៉ាង ហោចណាស់នាវាប្រាំបួន ត្រូវបានអង្កេតឃើញបូមខ្សាច់ និងផ្ទុកខ្សាច់ទៅលើនាវាខាងក្នុងព្រំដែនតំបន់ការពារទាំងនេះ ។[viii] នាវាបីក្នុងចំណោមនាវាទាំងនេះមានអក្សរ "Singapore" នៅលើសំបក ក្រោមឈ្មោះរបស់នាវា និងនាវាមួយមានទង់ជាតិប្រទេសសិង្ហបុរី ។[45]

## ក្រុមហ៊ុន Mong Reththy Group Co Ltd

ក្រុមហ៊ុន Mong Reththy Group Co Ltd (Mong Reththy Group) ត្រូវបាចេញអាជ្ញាប័ណ្ណឱ្យដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2009 សំរាប់ការធ្វើអាជីវកម្មខ្សាច់សំរាប់ការនាំចេញនៅក្នុងតំបន់ព្រែកថ្មរាងនៃស្រុកស្រែអំបិល ខេត្តកោះកុង ។[46] អាជ្ញាប័ណ្ណនេះ បានធ្វើតាមការយល់ព្រមជាគោលការណ៍ដែលថា ក្រុមហ៊ុន Mong Reththy Group អាចបូមខ្សាច់សំរាប់ការនាំចេញ ដែលចេញ ដោយគណៈកម្មការខ្សាច់នៅថ្ងៃទី 28 ខែ សីហា ឆ្នាំ 2009 ។[47] អាជ្ញាធររដ្ឋាភិបាលបានប្រាប់គ្លូបលវីតណេសថា ក្រុមហ៊ុនពីរផ្សេងទៀត (ក្រៅពីក្រុមហ៊ុន L.Y.P. Group) បានអាជ្ញាប័ណ្ណសំរាប់ការធ្វើអាជីវកម្ម និងនាំចេញខ្សាច់នៅក្នុងខេត្តកោះកុង គួរឱ្យចាប់អារម្មណ៍នោះគឺក្រុមហ៊ុន Mong Reththy Group មិនមែនជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដែលមានរាយឈ្មោះនោះ ។[48] តំបន់សម្បទាន ត្រូវបានគូសនៅលើផែនទី ខាងលើ ។ ជាថ្មីម្ដងទៀត សម្បទាននេះ គឺ សំរាប់*ខ្សាច់ទន្លេ* ដែលផ្ទុយនឹងប្រការនៃសេចក្ដីសម្រេចស្ដីពីការធ្វើអាជីវកម្មខ្សាច់ ។ ក្រុមហ៊ុន Mong Reththy Group និងផលប្រយោជន៍អាជីវកម្មរបស់ព្រឹទ្ធសមាជិកគណបក្ស CPP ឧកញ៉ា ម៉ុង ឫទ្ធី[49] ដែលជាម្ចាស់ក្រុមហ៊ុន ល្បីឈ្មោះចំពោះ គ្លូបលវីតណេស ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ឆ្នាំ 2007 របស់យើងស្ដីពី *ស្រឡាយអ្នកលក់ជាតិខ្មែរ* ។[50] សំណុំអាជីវកម្មរបស់គាត់រួម មាន ការដាំដំណាំ ពាណិជ្ជកម្មទំនិញ សំណង់ និង អចលនទ្រព្យ ។[51] ប្រជាជនក្នុងតំបន់ ត្រូវបានបណ្ដេញចេញដោយបង្ខំពីដីនៅក្នុងទីក្រុងភ្នំពេញ ដើម្បីធ្វើផ្លូវទៅកាន់គម្រោងអភិវឌ្ឍន៍ ទីក្រុងដែលគ្រប់គ្រងដោយក្រុមហ៊ុន[52] ហើយសម្បទានដីសេដ្ឋកិច្ចរបស់គាត់នៅក្នុងខេត្តស្ទឹងត្រែង គឺធំជាងដប់ដង ទំហំដែលបានអនុញ្ញាតដោយច្បាប់ភូមិបាលរបស់ប្រទេសកម្ពុជា ។[53] ក្រុមហ៊ុន Mong Reththy Group ក៏បានព្រមព្រៀងឧបត្ថម្ភអង្គភាពពីរ នៃកងយោធពលខេមរភូមិន្ទតាមការប្រកាសដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងខែ កុម្ភៈ ឆ្នាំនេះផងដែរ ។[54]



ព្រឹទ្ធសមាជិក ម៉ុង ឫទ្ធី ម្ចាស់ក្រុមហ៊ុន Mong Reththy Group ជាមួយព្រឹទ្ធសមាជិក លី យ៉ុងផាត់ ដែលគ្រប់គ្រងវិស័យខ្សាច់របស់ខេត្តកោះកុង ។



អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន Mong Reththy Group ដើម្បីយកខ្សាច់ចាប់ពីថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2009 ចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយដែលមានត្រា និងហត្ថលេខារបស់លោក Milton KS Goh ក្រោយមកជាលេខាធិការទីមួយរបស់ស្ថានទូតប្រទេសសិង្ហបុរីប្រចាំរាជធានីភ្នំពេញ ។

viii "តំបន់រ៉ាំសារ" គឺជាតំបន់ដីសើមដែលត្រូវបានកំណត់ទុកការពារបរិស្ថានពិសេស ដោយស្ថិតក្រោមអនុសញ្ញាស្ដីពីដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាសន្ធិសញ្ញាអន្តររដ្ឋាភិបាលដែលផ្ដល់ក្របខណ្ឌសម្រាប់វិធានការណ៍ថ្នាក់ជាតិ និងសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិរក្ស និងការប្រើប្រាស់ប្រកបដោយភាពវៃឆ្លាតនូវដីសើម និងធនធានរបស់ដីសើម : http://www.ramsar.org/cda/en/ramsar-home/main/ramsar/1%5E7715_4000_0__ (ចូលមើលលើកចុងក្រោយថ្ងៃទី 12 ខែមេសា ឆ្នាំ 2010) ។ កោះកាពិ និងបរិវារកោះ ត្រូវបានទទួលស្គាល់ដោយស្ថិតក្រោមអនុសញ្ញារ៉ាំសារនៅក្នុងឆ្នាំ 1999 : http://www.ramsar.org/pdf/sitelist.pdf (ចូលមើលលើកចុងក្រោយថ្ងៃទី 12 ខែមេសា ឆ្នាំ 2010) ។





សេចក្ដីចំលងឯកសារដែលបង្ហាញថា ឧត្ដមសេនីយត្រី នឹម ម៉េង ជា "ទីប្រឹក្សាឯកឧត្ដម ហ៊ីង ប៊ុនហៀង" និងត្រូវបានផ្ដល់ងារកិត្តិយសថ្នាក់ "មហាសេនា" ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី 28 ខែ មិថុនា ឆ្នាំ 2008 ។

ភស្តុតាងបង្ហាញថា ខ្សាច់ពីសម្បទានរបស់ក្រុមហ៊ុន Mong Reththy Group កំពុងត្រូវបាននាំចេញទៅកាន់ប្រទេសសិង្ហបុរី ។ គ្លូបលវិតណេស ត្រូវបានជូនដំណឹងដោយអាជ្ញាធរខេត្តថា ក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរីមួយ ត្រៀមខ្លួនជាស្រេចទិញខ្សាច់សំរាប់នាំចេញពីក្រុមហ៊ុន ។[55] អាជ្ញាប័ណ្ណ របស់ក្រុមហ៊ុន Mong Reththy Group ពីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងការយល់ព្រមជាគោលការណ៍ពីក្រសួងធនធានទឹក និង ឧតុនិយម ទាំងពីរត្រូវបានចុះហត្ថលេខាដោយតំណាងរបស់ស្ថានទូតសាធារណរដ្ឋសិង្ហបុរីប្រចាំទីក្រុងភ្នំពេញ : Milton KS Goh លេខាធិការទីមួយ នាពេលបន្ទាប់ នៅថ្ងៃទី 4 ខែ កញ្ញា ឆ្នាំ 2009 ។[56] មូលហេតុសំរាប់ការចុះហត្ថលេខានេះ មិនមានភាពច្បាស់លាស់ឡើយ ។ គ្លូបលវិតណេសបាន សរសេរលិខិតទៅកាន់លោក Goh និងក្រសួងកិច្ចការបរទេសរបស់ប្រទេសសិង្ហបុរី ស្នើសុំការបញ្ជាក់ ។ មកទល់ពេលការបោះពុម្ពផ្សាយ លោក Goh បានឆ្លើយតបទេ តែការឆ្លើយតបមួយពីរដ្ឋាភិបាលប្រទេសសិង្ហបុរីបានឱ្យដឹងថា *"អ្នកបានសាកសួរអំពីតួនាទីរបស់លេខាធិការទីមួយ ... នៅក្នុង ស្ថានទូតប្រទេសសិង្ហបុរីប្រចាំក្រុងភ្នំពេញ ។ កាតព្វកិច្ចរបស់អ្នកកាន់ ឱ្យតំណែងជាលេខាធិការទីមួយខុ រួមមានផ្ដល់សេវាសារការីដូចជា ការបញ្ជាក់ថា ឯកសារពិតជាដើម"* ។[57] ទោះយ៉ាងណា ដោយមើលលើអាជ្ញាប័ណ្ណផ្ទាល់ (ទំព័រ 12 ដែលបានបញ្ចូលក្នុងនេះ) មិនមានទ្រង់អិតត្រូវបានផ្ដល់ឱ្យថាតើ សេវាសារការីមួយណាដែលលោក Goh កំពុងបំពេញ (ដូចជាការបញ្ជាក់ឯកសារ) ដោយការចុះហត្ថលេខាលើកិច្ចសន្យាមួយរវាងក្រុមហ៊ុននៅ ប្រទេសកម្ពុជាមួយ និងអាជ្ញាធររដ្ឋាភិបាលប្រទេសកម្ពុជា ។

ជាងនេះទៀត គ្លូបលវិតណេសបានឃើញសំណៅចំលងរបាយការណ៍ គុណភាពខ្សាច់ពីក្រុមហ៊ុនពីរ ដែលក្រុមហ៊ុនទាំងពីរអះអាងថាមាន កិច្ចព្រមព្រៀង ជាមួយក្រុមហ៊ុន Mong Reththy Group ដើម្បីនាំចេញ ខ្សាច់ទៅកាន់ប្រទេសសិង្ហបុរី ពីសម្បទានរបស់ពួកគេ ។[58] របាយការណ៍មួយក្នុង ចំណោមនោះចុះកាលបរិច្ឆេទខែ កញ្ញា ឆាំ 2009 ពីក្រុមហ៊ុនខ្មែរមួយឈ្មោះក្រុមហ៊ុន Nim Meng Import and Export Development Co Ltd (Nim Meng) បញ្ជាក់ថា ប្រភពនៃខ្សាច់គឺជា *"តំបន់សមុទ្ររបស់កំពង់ផែម៉ុង ឫទ្ធី"* និង *"ក្រុមហ៊ុន Mong Rethythy Group Co Ltd"* ។[59] វាក៏បញ្ជាក់ផងដែរថា វាគឺជាខ្សាច់សំរាប់គោលបំណងរុករានដី ហើយបានជាប់ឆ្នូតកាត់បទដ្ឋានតេស្ដិ៍ JTC ហើយ ។ គ្លូបលវិតណេស បានឃើញកិច្ចព្រមព្រៀងដែលបានទាញមក អនុញ្ញាតឱ្យក្រុមហ៊ុន Nim Meng បូម និងនាំចេញខ្សាច់ពីតំបន់ដែលមានអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន Mong Reththy Group ។[60] យោងតាមគេហទំព័ររបស់ពាណិជ្ជករវៀតណាមដ៏ល្បីម្នាក់បានឱ្យដឹងថា មនុស្សដែលមានឈ្មោះដូចគ្នានេះគឺ លោក នឹម ម៉េង គឺជាឧត្ដមសេនីយ៍ត្រីខ្មែរម្នាក់ ហើយពាក់ព័ន្ធនឹងឧស្សាហកម្មសំណង់របស់ប្រទេសកម្ពុជា ។[61] នេះមិនមែនជាភស្តុតាងដែលថា ឧត្ដមសេនីយ៍ត្រី នឹម ម៉េង គឺជាម្ចាស់ក្រុមហ៊ុន នឹម ម៉េង នោះឡើយ ។ តែប្រសិនបើលោក នឹម ម៉េង នៃក្រុមហ៊ុន Nim Meng Import Export Development Co Ltd ការពិតគឺជាឧត្ដមសេនីយ៍ត្រី នឹម ម៉េង ប្រាកដមែន នោះប្រការនេះនឹងលើកជាចម្ងល់អំពីការពាក់ព័ន្ធដ៏សំខាន់របស់ ក្រុមហ៊ុនជាមួយនឹងយោធា ដែលសកម្មភាពត្រូវបានកត់ត្រាពីមុនដោយគ្លូបលវិតណេស ។ ឯកសារដែលបានពិនិត្យដោយគ្លូបលវិតណេសមានរាយ នាមឧត្ដមសេនីយ៍ត្រី នឹម ម៉េង ជា "ទីប្រឹក្សាឯកឧត្ដម ហ៊ីង ប៊ុនហៀង" មេបញ្ជាការកងអង្គរក្ស ដែលពីមុនត្រូវបានរាយការណ៍ដោយ គ្លូបលវិតណេសនៅក្នុង *ស្រឡាញ់អ្នកលក់ជាតិខ្មែរ* ថាមានការពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ ព្រមទាំងការរត់ពន្ធឈើចេញពីកំពង់ផែឧកញ៉ាម៉ុង ដែលគ្រប់គ្រងដោយក្រុមហ៊ុន Mong Reththy Group ផងដែរ ។[62] ឧត្ដមសេនីយ៍ត្រី នឹម ម៉េង ហាក់បីដូចជាមានលំដាប់ថ្កាយពីរនៅកង យោពលខេមរភូមិន្ទ ហើយត្រូវបានផ្ដល់ងារកិត្តិយស "មហាសេនា" ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី 28 ខែ មិថុនា ឆ្នាំ 2008 ។[63]

*សំណុំអាជីវកម្មរបស់ព្រឹទ្ធសមាជិក លី យ៉ុងផាត់ និងក្រុមហ៊ុនរបស់គាត់មានវិសាលភាពដល់កាស៊ីណូ សណ្ឋាគារ និងសម្បទានដីសេដ្ឋកិច្ច ។ ការបណ្ដេញចេញកសិករដោយបង្ខំប្រកបដោយហិង្សាដើម្បីធ្វើផ្លូវ សម្រាប់ការដាំដុះដោយក្រុមហ៊ុន បាននាំឱ្យមានការរិះគន់ខ្លាំងពីក្រុមសិទ្ធិ មនុស្ស ។*

គ្លូបលវិតណេសបានសរសេរលិខិតទៅកាន់ព្រឹទ្ធសមាជិក ម៉ុង ឫទ្ធី ជានាយកក្រុមហ៊ុន Mong Reththy Group Co Ltd នៅក្នុងខែ មិនា ឆ្នាំ 2010 ដើម្បីស្នើសុំយោបល់លើការបញ្ជាក់អះអាងទាំងនេះ ។ អ៊ីម៉ែលមួយត្រូវបានទទួលពីការិយាល័យរបស់គាត់នៅថ្ងៃទី 2 ខែ មេសា ឆ្នាំ 2010 ដោយអញ្ជើញគ្លូបលវិតណេសឱ្យជួបប្រជុំជាមួយក្រុមហ៊ុននៅក្នុងទីក្រុងភ្នំពេញ ។ គ្លូបលវិតណេសបានឆ្លើយតបថា ការធ្វើដំណើរទៅកាន់ប្រទេស កម្ពុជា មិនអាចធ្វើទៅបានទេ ដោយសារការបារម្ភពីសន្តិសុខសំរាប់បុគ្គលិក ប៉ុន្តែថាការជួបប្រជុំតាមទូរស័ព្ទអាចរៀបចំបាន ។[64] មិនមានការឆ្លើយតប បន្ថែម ត្រូវបានទទួលពីក្រុមហ៊ុនគិតមកទល់ពេលបោះពុម្ពផ្សាយ ។ គ្លូបលវិតណេស ក៏បានព្យាយាមទាក់ទងលោក នឹម ម៉េង នៅក្នុងខែ មិនា ឆ្នាំ 2010 ស្នើសុំយោបល់ផងដែរ ។ ទាំងអ៊ីម៉ែល ឬលេខទូរសាររបស់ក្រុមហ៊ុនមិនដំណើរការ ហើយបុគ្គលិកនៅការិយាល័យបដិសេធទទួលសំបុត្រដែល ផ្ញើជូនដោយអ្នកនាំសំបុត្រ ។ គ្លូបលវិតណេស ក៏បានផ្ញើលិខិតមួយទៅកាន់ក្រុមហ៊ុនតាមរយៈ ស្ថានទូតខ្មែរប្រចាំប្រទេសអង់គ្លេស ។ គ្មានការឆ្លើយតប ត្រូវបានទទួល គិតមកទល់ពេលបោះពុម្ពផ្សាយ ។ គ្លូបលវិតណេសរង់ចាំលោក នឹម ម៉េង បញ្ជាក់ពីបញ្ហាទាំងនេះ ។



គ្លូបលវីតណេស

ផ្លាកសញ្ញាការិយាល័យរបស់ក្រុមហ៊ុន Udom Seima នៅក្នុងខេត្តកោះកុង ប្រទេសកម្ពុជា ជាប់នឹងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត

## ក្រុមហ៊ុន Udom Seima Peanikch Industry and Mine Co Ltd

ក្រុមហ៊ុនទីបីដែលមានអាជ្ញាប័ណ្ណសំរាប់ការធ្វើអាជីវកម្មបូម និងនាំចេញខ្សាច់នៅក្នុងខេត្តកោះកុង គឺក្រុមហ៊ុន Udom Seima Peanikch Industry and Mine Co Ltd (Udom Seima) ។ ដោយមានស្រដៀងគ្នានៃឈ្មោះ និងចំនួនក្រុមហ៊ុនមានកម្រិតនៅក្នុងខេត្តកោះកុង គ្លូបលវីតណេសជឿជាក់ថា ក្រុមហ៊ុននេះគឺជាក្រុមហ៊ុន "Odom Cement Co Ltd" ដែលមានឈ្មោះនៅក្នុង*ប្រទេសជាតិលក់* ដែលជាតួអង្គសំខាន់មួយនៅក្នុងវិស័យខ្សាច់របស់ខេត្តកោះកុង ។ យោងតាមឯកសារអាជ្ញាប័ណ្ណដែលបានពិនិត្យដោយគ្លូបលវីតណេសបានឱ្យដឹងថា ក្រុមហ៊ុនបាន ការអនុញ្ញាតឱ្យបូមខ្សាច់នៅក្នុងមាត់សមុទ្រកោះពោធិចាប់តាំងពីឆ្នាំ 2007 ហើយនៅក្នុងទន្លេត្រពាំងរូងចាប់តាំងពីឆ្នាំ 2008 ។[65] តំបន់សម្បទានទាំងនេះ ត្រូវបានបញ្ចូលនៅក្នុងផែនទីខាងលើ សំរាប់ការបូមខ្សាច់ជម្រៅរវាងពី 0.5 ទៅ 8m ។[66] នៅថ្ងៃទី 31 ខែ កក្កដា ឆ្នាំ 2009 គណៈកម្មការខ្សាច់បានផ្តល់ការយល់ព្រមជាគោលការណ៍ឱ្យក្រុមហ៊ុន Udom Seima បន្តប្រតិបត្តិការខ្សាច់របស់ខ្លួននៅក្នុងទន្លេត្រពាំងរូងសំរាប់ ការនាំចេញ ទោះបីជាការបូមខ្សាច់*ទន្លេ*សំរាប់ការនាំចេញ ត្រូវបានហាមដោយគណៈកម្មការដូចគ្នានេះ ត្រឹមតែដប់សប្តាហ៍មុនក៏ដោយ ។[67] គ្លូបលវីតណេស



សេចក្តីចំលងពីការយល់ព្រមជាគោលការណ៍របស់ក្រុមហ៊ុន Udom Seima ឱ្យបន្តប្រតិបត្តិការខ្សាច់នៅក្នុងទន្លេត្រពាំងរូងសំរាប់ការនាំចេញដោយក្រសួងធនធានទឹក និងឧតុនិយម

មិនអាចស្វែងរកឃើញភស្តុតាងដែលថាក្រុមហ៊ុន Udom Seima ត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ទេ ។[68] ទោះយ៉ាងណា ក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅក្នុងប្រទេស សិង្ហបុរី ហើយពីរនាក់ក្នុងចំណោមនាយកទាំងបួនរបស់ក្រុមហ៊ុនគឺជាជនជាតិខ្មែរ : លោក អ៊ាត សីមា និងលោក អ៊ាត ប៊ុនថុល ។[69] នៅក្នុងខែ មេសា ឆ្នាំ 2009 នាយកទាំងពីរត្រូវបានផ្តល់ងារកិត្តិយសជា "ឧកញ៉ា" ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ។[70]

## ការពង្រីកការរុករករ៉ែខ្សាច់តាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា

ទូទាំងឆ្នាំ 2009 និង 2010 ការរុករករ៉ែខ្សាច់បានពង្រីកតាមជួរមាត់សមុទ្ររបស់ប្រទេសកម្ពុជា ។ នៅក្នុងខែ តុលា ឆ្នាំ 2009 ក្រសួងធនធានទឹក និងឧតុនិយាមបានថ្លែងជាសាធារណៈថា ក្រុមហ៊ុន 14 ត្រូវបានផ្តល់ឱ្យនូវសម្បទាននៅក្នុងខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត ។[71] ក្រុមហ៊ុនមួយឈ្មោះថា InterTrans Co Ltd ដែលមានមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ត្រូវបានចេញអាជ្ញាប័ណ្ណឱ្យបូមខ្សាច់សំរាប់ការនាំចេញដោយក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល នៅថ្ងៃទី 10 ខែ កញ្ញា ឆ្នាំ 2009 ។[72] ដូចអាចមើលឃើញបានក្នុងផែនទី 1 សម្បទានដែលត្រូវបានយល់ព្រមឱ្យដោយ គណៈកម្មការខ្សាច់ មានទីតាំងនៅក្នុងឧទ្យានជាតិរាម ដែលជាតំបន់មួយរក្សាទុកសំរាប់អភិរក្សជីវចម្រុះដោយរាជក្រឹត្យ ។ គ្លូបលវីតណេសបានទទួលភស្តុតាងជាឯកសារដែលក្រុមហ៊ុនមួយផ្សេងទៀតក្នុងចំណោមនេះ គឺក្រុមហ៊ុន K.T.A. Import Export & Development Co Ltd (K.T.A.) ដែលមានសម្បទានឱ្យបូម និងនាំចេញខ្សាច់នៅក្នុងមាត់សមុទ្រខេត្តកំពត[73] ហើយបានចុះកិច្ចសន្យាបន្តឱ្យនាំចេញខ្សាច់ទៅឱ្យក្រុមហ៊ុនវៀតណាម មួយ ។[74]

K.T.A. ត្រូវបានគ្រប់គ្រងដោយលោក កែវ ថា និងត្រូវបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា ។[75] គ្លូបលវីតណេសត្រូវបានប្រាប់ឱ្យដឹងថា ក្រុមហ៊ុនរបស់ លោក កែវ ថា បានកំពុងនាំចេញខ្សាច់ទៅកាន់ប្រទេសសិង្ហបុរី ហើយជាមួយនឹងក្រុមហ៊ុន Mong Reththy Group អាជ្ញាប័ណ្ណសំរាប់សម្បទាន របស់ក្រុមហ៊ុន K.T.A. ត្រូវបានចុះហត្ថលេខា និងវាយត្រាដោយលោក Milton KS Goh ពេលនោះ លេខាធិការទីមួយនៃស្ថានទូតសិង្ហបុរីប្រចាំ ទីក្រុងភ្នំពេញ នៅថ្ងៃទី 4 ខែ កញ្ញា ឆ្នាំ 2009 ដែលជាកាលបរិច្ឆេទតែមួយជាមួយនឹងការវាយត្រារបស់អាជ្ញាប័ណ្ណក្រុមហ៊ុន Mong Reththy Group ។[76] ជាថ្មីម្តងទៀត មូលហេតុសំរាប់ការវាយត្រាផ្លូវការរបស់ស្ថានទូតលើឯកសារនេះ មិនមានភាពច្បាស់លាស់ទេ ។ គ្លូបលវីតណេស ក៏បាន សរសេរលិខិតទៅកាន់លោក Goh ដើម្បីសួរថាតើហេតុអ្វីគាត់បានវាយត្រាលើសម្បទាននាំចេញខ្សាច់នេះ ហើយទៅកាន់ក្រសួងកិច្ចការបរទេស ផងដែរ ។ មកទល់ពេលនៃការបោះពុម្ពផ្សាយនេះ មានតែរដ្ឋាភិបាលប្រទេសសិង្ហបុរីប៉ុណ្ណោះបានឆ្លើយតប ដូចបានរៀបរាប់នៅលើទំព័រ 13 ។

## ជំនួយខ្សាច់ – ទំហំ និងតម្លៃនៃវិស័យខ្សាច់របស់ប្រទេសកម្ពុជា

គេហទំព័ររបស់ប្រទេសកម្ពុជាមួយប៉ាន់ស្មានថា ខ្សាច់រវាងពី 40,000 ទៅ 60,000 "តោន"[ix] ត្រូវបានបូមជារៀងរាល់ខែពីទឹកនៃខេត្តកោះកុង ទោះបីជាគេហទំព័រមិនបាននិយាយថាតើចំនួនប៉ុន្មានក្នុងចំណោមនេះ មានបំណងសំរាប់ការនាំចេញក៏ដោយ ។[77] គេហទំព័របង្ហាញថា រដ្ឋាភិបាលបានដាក់កម្រិតតឹងតែងលើចំនួនខ្សាច់ដែលអាចបូម និងថាពេលដែលប្រតិបត្តិការរុករករ៉ែខ្សាច់នៅមានទំហំតូច នោះប្រតិបត្តិការទាំងនោះ

ix វាមិនច្បាស់ពីគេហទំព័រនេះថាតើ តួលេខយោងទៅលើ imperial tons (ស្មើនឹង 1016kg), short tons (907kg) ឬ metric tons/tonnes (1000kg) ។ ហេតុនេះ បរិមាណប៉ាន់ស្មាន អាចមានអតិបរមាដល់ 60,000 imperial tons ស្មើនឹង 60,960 metric tons/tonnes.ចាប់ពីពេលនេះតទៅ រាល់ទម្ងន់តោនទាំងអស់ គិតជា metric tons/tonnes ហើយនឹងត្រូវបានសំដៅថាជា "តោន" ធម្មតា ។



សេចក្តីចំលងពីការយល់ព្រមជាគោលការណ៍របស់ក្រុមហ៊ុន KTA ឱ្យបូមខ្សាច់ចាប់ពីខែ កញ្ញា ឆ្នាំ 2009 ចេញដោយក្រសួងធនធានទឹក និងឧតុនិយម ហើយដែលមានត្រា និងហត្ថលេខារបស់លោក Milton KS Goh ក្រោយមកជាលេខាធិការទីមួយរបស់ស្ថានទូតប្រទេសសិង្ហបុរី ប្រចាំរាជធានីភ្នំពេញ ។

ត្រូវបានរំពឹង ទុកថា មានផលប៉ះពាល់តិចតួចលើបរិស្ថានក្នុងតំបន់ ។[78] ស្របពេលជាមួយគ្នានេះដែរ រដ្ឋាភិបាលប្រទេសសិង្ហបុរីបានរាយការណ៍ទៅកាន់ប្រព័ន្ធទិន្នន័យរបស់ United Nations Statistics Division Commodity Trade Statistics Database (UN Comtrade) ថា ខ្លួនបាន នាំចូលខ្សាច់ 3.8 លានតោនពីប្រទេសកម្ពុជានៅក្នុងឆ្នាំ 2008 ដែលស្មើនឹងស្ថិតិពីប្រទេសកម្ពុជាសម្រាប់ការនាំចេញខ្សាច់ពីរាល់ខេត្តទាំងអស់ ដែលមិនអាចទទួលបាននៅលើគេហទំព័ររបស់ UN Comtrade ។

ទោះយ៉ាងណា ភស្តុតាងបង្ហាញថា ទំហំពិតប្រាកដនៃពាណិជ្ជកម្មខ្សាច់រវាងខេត្តកោះកុង និងប្រទេសសិង្ហបុរី អាចក្រាស់ក្រែលច្រើនជាងនេះ ។ ការគណនាទាំងនេះ គឺជាការប៉ាន់ស្មានដែលបានធ្វើដោយគ្លូបលវីតណេស ផ្អែកតាមប្រភពដែលបានទទួលប្រសើរបំផុត ដោយសារការខ្វះខាតព័ត៌មាន ជាសាធារណៈអំពីពាណិជ្ជកម្មពិតប្រាកដ ។ ប្រភពឧស្សាហកម្មមួយក្នុងមុខងារដែលបានដឹង បានប៉ាន់ស្មានពីអត្រាបូមប្រចាំខែសម្រាប់តំបន់សម្បទាន របស់ក្រុមហ៊ុន L.Y.P. Group មានប្រមាណ 300,000 តោន ។[80] តួលេខនេះ ត្រូវបានគាំទ្រដោយភស្តុតាងពីឯកសារដឹកជញ្ជូនដែលបានពិនិត្យ ដោយគ្លូបលវីតណេស ដែលកត់ត្រាពីការផ្ទេរខ្សាច់ 77,236 តោនទៅកាន់កំពង់ផែប្រទេសសិង្ហបុរីរវាងពីថ្ងៃទី 15 ដល់ថ្ងៃទី 22 ខែ វិច្ឆិកា ឆ្នាំ 2009 ។[81] ប្រសិនបើចំនួននៃពាណិជ្ជកម្មនេះ បង្ហាញពីអាជីវកម្មជាធម្មតាលើរយៈពេលប្រាំបីថ្ងៃ នោះវានឹងស្មើសរុបប្រចាំខែប្រមាណ 289,000 តោន ។ អាជ្ញាប័ណ្ណមួយ ដែលបានពិនិត្យដោយគ្លូបលវីតណេស និងមានត្រារបស់ក្រសួងមហាផ្ទៃរបស់រាជរដ្ឋាភិបាលកម្ពុជា កំណត់អត្រាអប្បបរមានៃការបូមខ្សាច់ 10,000 ម៉ែត្រគ្រីគុណជារៀងរាល់ថ្ងៃសំរាប់តំបន់សម្បទានដែល គ្លូបលវីតណេសជឿជាក់ថាជារបស់ក្រុមហ៊ុន Mong Reththy Group ។[82] តួលេខនេះ ស្មើប្រមាណ 379,000 តោនក្នុងមួយខែ ។[x83] ឯកសារអាជ្ញាប័ណ្ណដែលបានពិនិត្យដោយគ្លូបលវីតណេសបង្ហាញថា សម្បទានក្រុមហ៊ុន Mong Reththy Group មាន $54.85km^2$ [84] ហើយសម្បទានក្រុមហ៊ុន Udom Seima មាន 17 $km^2$ ។[85] ហេតុនេះ តាមសមាមាត្រ តំបន់របស់ក្រុមហ៊ុន Udom Seima អាចត្រូវបានប៉ាន់ស្មានថាផលិតបានខ្សាច់ប្រមាណ 117,000 ក្នុងមួយខែ ។ ដោយ ប្រើប្រាស់ការប៉ាន់ស្មានទាំងនេះ




គ្លូបលវីតណេស

នាវារបស់ក្រុមហ៊ុន Winton និងត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ខេត្តកោះកុង ប្រទេសកម្ពុជា ។ គ្លូបលវីតណេសប៉ាន់ស្មានថា បរិមាណខ្សាច់ដែលត្រូវបាននាំចេញពីម្ចាស់សម្បទានបូមខ្សាច់ធំៗទាំងបីនៅក្នុងខេត្តកោះកុង អាចច្រើនដល់ 796,000 តោនក្នុងមួយខែ ។

x របាយការណ៍ធ្វើតេស្តមួយស្តីពីខ្សាច់ដែលបានបូមចេញពីតំបន់សម្បទានរបស់ក្រុមហ៊ុន Mong Reththy Group ដែលបានធ្វើឡើងដោយមន្ទីរពិសោធន៍មានមូលដ្ឋាននៅប្រទេសសិង្ហបុរី មួយបានឱ្យដឹងថាមានដង់ស៊ីតេខ្សាច់ 1.263 តោនក្នុងមួយម៉ែត្រគ្រីគុណ ។ បរិមាណបូមប្រចាំថ្ងៃ $10,000m^3$ ឬបរិមាណប្រចាំខែ $300,000m^3$ ហេតុនេះស្មើនឹង 379,000 តោន ត្រូវ បានបូមចេញជារៀងរាល់ខែពីតំបន់សម្បទានរបស់ Mong Reththy .



គ្លូបលវីតណេស

ស្តុកខ្សាច់ដែលគ្រប់គ្រងដោយក្រុមហ៊ុន L.Y.P. Group រង់ចាំការនាំចេញ ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 នៅត្រើយម្ខាងកោះពោធិ ពីទីរួមខេត្តកោះកុង ខេត្តកោះកុង ប្រទេសកម្ពុជា។

សម្រាប់សម្បទានទាំងបី (ចំនួន 300,000 តោនសម្រាប់ក្រុមហ៊ុន L.Y.P. Group ចំនួន 379,000 តោន សម្រាប់ក្រុមហ៊ុន Mong Reththy Group និងចំនួន 117,000 សម្រាប់ក្រុមហ៊ុន Udom Seima) បរិមាណខ្សាច់សរុបដែលបានបូម និងនាំចេញពីខេត្តកោះកុងរៀងរាល់ខែនាពេល បច្ចុប្បន្នអាចមានប្រមាណ 796,000 តោន។

អ្នកបូមខ្សាច់របស់ប្រទេសកម្ពុជា លក់ខ្សាច់របស់ពួកគេប្រមាណ 3 ដុល្លារអាមេរិកក្នុងមួយតោននៅកន្លែងបូម។ ដូចនេះ នៅចំនួន 796,000 តោន ជារៀងរាល់ខែ វិស័យខ្សាច់របស់ខេត្តកោះកុង អាចមានតម្លៃរហូតដល់ 28.7 លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំ។[86] ការទិញខ្សាច់នៅកំពង់ផែខេត្ត កោះកុង រៀបចំដឹកជញ្ជូនរួចជាស្រេចថ្លៃប្រមាណ 5.60 ដុល្លារអាមេរិកក្នុងមួយតោន។[xii] នៅក្នុងប្រទេសសិង្ហបុរី ភ្នាក់ងាររដ្ឋាភិបាល JTC ទិញខ្សាច់ សមុទ្រពីក្រុមហ៊ុនជាអន្តរការីក្នុងតម្លៃប្រមាណ 26 ដុល្លារអាមេរិកក្នុងមួយតោន ដែលមានកំណើនថ្លៃចំនួនប្រាំបួនដង។[xiii] ដោយប្រើប្រាស់តួលេខ ទាំងនេះ និងសន្មតថាការនាំចូលប្រចាំខែពីប្រទេសកម្ពុជាចំនួន 796,000 ដូចបានគណនាខាងលើ នោះពាណិជ្ជកម្មខ្សាច់ពីខេត្តកោះកុង នឹងមានតម្លៃនៅប្រទេសសិង្ហបុរីប្រមាណ 20 លានដុល្លារអាមេរិកជារៀងរាល់ខែ។ ចំនួននេះស្មើនឹង 248 លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។[87] ចំនួនសរុបនេះគឺជាការប៉ាន់ស្មានសម្រាប់ពាណិជ្ជកម្មពីសម្បទានទាំងបីនៅក្នុងខេត្តកោះកុងតែមួយប៉ុណ្ណោះ ចំណែកចំនួន និងតម្លៃរបស់កន្លែងចំនួន 11 ផ្សេងទៀតតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា មិនត្រូវបានដឹងឡើយ។

*...ចាប់ពីខែ មេសា ដល់ខែ ធ្នូ ឆ្នាំ 2009 ពាណិជ្ជកម្មខ្សាច់ខេត្តកោះកុង អាចត្រូវបានរំពឹងថាផ្តល់ឱ្យរដ្ឋាភិបាលនូវប្រាក់ចំណូល 10.7 លានដុល្លារអាមេរិក ...*

xi តំបន់សម្បទានរបស់ក្រុមហ៊ុន Udom Seima ត្រូវបានជឿជាក់ថាមាន 31% នៃទំហំតំបន់របស់ Mong Reththy ហេតុនេះអាចប៉ាន់ស្មានថាផលិតបានប្រមាណ 31% នៃបរិមាណ ខ្សាច់ ឬ 117,000 រៀងរាល់ខែ។
xii តួលេខនេះ ត្រូវបានគណនាដោយប្រើប្រាស់តម្លៃមធ្យមលើការផ្សាយពាណិជ្ជកម្មខ្សាច់ប្រទេសកម្ពុជា ដែលបានដាក់ផ្សាយនៅលើវេបសាយពាណិជ្ជកម្មពិភពលោក Alibaba ។ គ្លូបលវីតណេស បានរកឃើញការផ្សាយពាណិជ្ជកម្មខ្សាច់ប្រទេសកម្ពុជា 19 ដែលបានកំណត់ជាក់លាក់នូវតម្លៃ ឬលំដាប់តម្លៃ ហើយលំដាប់បីក្នុងចំណោមលំដាប់ថ្លៃទាំងនេះគឺច្រើនជាង 1 ដុល្លារអាមេរិក។ ដោយសារការផ្សាយពាណិជ្ជកម្មទាំងបីនេះ ត្រូវបានជឿជាក់ថាមិនមានភាពពិតប្រាកដ តម្លៃមិនត្រូវបានទទួលស្គាល់។ នៅក្នុងចំណោមតម្លៃ 'Free on Board' ចំនួន 16 នៅសល់ដែលបានផ្សាយពាណិជ្ជកម្ម តម្លៃមធ្យមគឺ 5.60 ដុល្លារអាមេរិកក្នុងមួយតោន ដោយមាន standard deviation KW 0.53 ដុល្លារអាមេរិក។ http://www.alibaba.com/trade/search?SearchText=cambodia+sand&Country=&IndexArea=product_en&ssk=y (ចូលមើលលើកចុងក្រោយ ថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2010)។
xiii កិច្ចសន្យា JTC មួយពាក់ព័ន្ធនឹង "ការផ្គត់ផ្គង់ និងការដឹកជញ្ជូនខ្សាច់សមុទ្រ" ជាមួយក្រុមហ៊ុនប្រទេសសិង្ហបុរីមួយ ចុះថ្ងៃទី 21 ខែ ឧសភា ឆ្នាំ 2008 កំណត់តម្លៃ ទិញ 45 ដុល្លារ សិង្ហបុរីក្នុងមួយម៉ែត្រគ្រីគុណ។ ដោយប្រើប្រាស់ដង់ស៊ីតេខ្សាច់ដែលបានរៀបរាប់ពីមុនចំនួន 1.263 តោនក្នុងមួយម៉ែត្រគ្រីគុណ ហើយអត្រាប្តូរប្រាក់នាពេលបច្ចុប្បន្នKW 0,74 ដុល្លារអាមេរិក ក្នុង 1 ដុល្លារសិង្ហបុរី តម្លៃនេះស្មើនឹង 26 ដុល្លារអាមេរិកក្នុងមួយតោន។

### បរិមាណពាណិជ្ជកម្មខ្សាច់របស់ប្រទេសកម្ពុជា ឆ្នាំ 2009 ត្រូវបានប៉ាន់ស្មានដោយគ្លូបលវីតណេស




### តម្លៃពាណិជ្ជកម្មខ្សាច់របស់ប្រទេសកម្ពុជា 2009 ត្រូវបានប៉ាន់ស្មានដោយគ្លូបលវីតណេស




យោងតាម*ប្រកាស* ដែលចេញនៅក្នុងខែ មិនា ឆ្នាំ 2009 រដ្ឋាភិបាលប្រទេសកម្ពុជា កំណត់សួយសារលើខ្សាច់ដែលបានរុករកចំនួនមួយតោនចំនួន 1.50 ដុល្លារអាមេរិក ។[88] ស្របជាមួយគ្នានេះចាប់ពីខែ មេសា ដល់ខែ ធ្នូ ឆ្នាំ 2009 ពាណិជ្ជកម្មខ្សាច់ខេត្តកោះកុង អាចត្រូវបានរំពឹងថាផ្តល់ឱ្យរដ្ឋាភិបាលនូវប្រាក់ចំណូល 10.7 លានដុល្លារអាមេរិក ដោយសន្មតថាខ្សាច់ 796,000 ត្រូវវបាននាំចេញក្នុងមួយខែតាមដែលត្រូវបានគណនាពី ខាងលើ ។[xiv] ទោះយ៉ាងណា ដោយសារការខ្វះខាតព័ត៌មានថវិកាឱ្យសាធារណៈជនដោយរដ្ឋាភិបាលប្រទេសកម្ពុជា យើងមិនអាចដឹងថាតើរបៀបណា - ចំនួនប៉ុន្មាន - ដែលប្រាក់ចំណូលនេះចូលទៅក្នុងរតនាគារជាតិបានឡើយ ឬមិនមានវិធីណាដែលបង្ហាញថា តួលេខនេះកំពុងត្រូវបានផ្តល់ជូនដល់អាទិភាពចំណាយថ្នាក់ជាតិឡើយ ។ ហេតុនេះ អត្ថប្រយោជន៍សេដ្ឋកិច្ចនៃពាណិជ្ជកម្មនេះចំពោះប្រជាជនកម្ពុជា មិនអាចដឹងចំនួនបានឡើយ ។



"ប្រកាសអន្តរក្រសួង" ពីខែ មិនា ឆ្នាំ 2009 ដែលកំណត់កម្រៃពីការចុះឈ្មោះការប្តូរថ្មី និងការផ្ទេរសម្បទានរុករករ៉ែ ។ ផ្នែកដែលបានគូសសំគាល់បង្ហាញថាសួយសារត្រូវទទួលសំរាប់ខ្សាច់ដែលមិនទាន់កែច្នៃគឺ 1.50 ដុល្លារក្នុងមួយតោន ។

xiv 796,000 តោន នៅកម្រៃសួយសារ 1.50 ដុល្លារអាមេរិកក្នុងមួយតោន រយៈពេល 9 ខែ (មេសា ដល់ ធ្នូ ឆ្នាំ 2009) សរុបចំនួន 10.7 លានដុល្លារអាមេរិក ។

# 3. បូមខ្សាច់បង្កើនធូលី

## ផលប៉ះពាល់នៃវិស័យខ្សាច់ដែលមិនបានគ្រប់គ្រងរបស់ប្រទេសកម្ពុជា

**ភស្តុតាងដែលឃើញដោយគ្លូបលវីតណេសបង្ហាញថា អ្នកទាំងឡាយពាក់ព័ន្ធនឹងវិស័យខ្សាច់របស់ប្រទេសកម្ពុជា កំពុងធ្វើឱ្យអន្តរាយដល់ប្រព័ន្ធអេកូឡូហ្សីរបស់ផលជាតិដែលមានសារៈសំខាន់ផ្នែកបរិស្ថាន ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីបំពេញតាមតម្រូវការខ្សាច់របស់ប្រទេសសិង្ហបុរី ។ ពួកគេក៏ហាក់បីដូចជាមិនយកចិត្តទុកដោក់នឹងបណ្ដឹងដែលថា ផលផលក្នុងតំបន់កំពុងត្រូវបានបំផ្លិចបំផ្លាញផងដែរ ។ នេះគឺជាការបន្តនូវនិន្នាការដែលបានកំណត់ឃើញពីមុនដោយគ្លូបលវីតណេសថា ធនធានធម្មជាតិដែលមានសារៈសំខាន់ផ្នែកបរិស្ថានរបស់ប្រទេសកម្ពុជា ត្រូវបានចាប់យកដោយពួកវរជនរបស់ប្រទេស ហើយត្រូវបានបូមយកដោយពិចារណាតែបន្តិចបន្តួចចំពោះផលប៉ះពាល់បរិស្ថាន ឬសង្គម ។**

### ផលប៉ះពាល់លើលំនៅដែលមានសារៈសំខាន់ៗជាសកល

ជួរច្រាំងសមុទ្រប្រវែង 435km របស់ប្រទេសកម្ពុជា មាននូវលំនៅដែលមានសារៈសំខាន់ជាសកល ដែលផ្ដល់នូវសេវាប្រព័ន្ធអេកូឡូហ្សីសំខាន់ៗ ហើយមិនមានការខូចខាត ប្រៀបទៅនឹងជួរច្រាំងទាំងឡាយរបស់ប្រទេសជិតខាង ។[89] ទាំងបីក្នុងចំណោមនេះ ស្ថិតនៅក្នុង ឬនៅក្បែរប្រតិបត្តិការ បូមខ្សាច់ - ជ្រលងស្មៅសមុទ្រ កោងកាង និងផ្កាថ្មប៉ប្រះទឹក ។

ជ្រលងស្មៅសមុទ្រ នាពេលមួយត្រូវបានរកឃើញមាននៅតាមឆ្នេរសមុទ្រទាំងមូល កំពុងស្ថិតក្រោមការគំរាមកំហែងពីការនេសាទដ៏សម្បើម ហើយ ការបូមខ្សាច់ឥឡូវនេះនឹងបង្កើនល្បឿនដំណើរការនេះកាន់តែខ្លាំង ។[90] ជ្រលងស្មៅសមុទ្រក្នុងខេត្តកំពតត្រូវបានប៉ាន់ស្មានគ្របដណ្ដប់ប្រមាណ 25,240ha (ច្រើនជាងដប់ដងទំហំជ្រលងផ្សេងទៀតនៅសមុទ្រចិនភាគខាងត្បូង)[91] ហើយគឺជាលំនៅប្រភេទពូជទឹកប្រៃរងគ្រោះជាច្រើន ដែលរួមមាន អ៊ីរ៉ាវ៉ាឌី និងស្ពីនន័រដូហ្វីន ឌូហ្គុង និងសេះសមុទ្រ ។[92xv] ជ្រលងស្មៅសមុទ្រក៏ត្រូវបានរកឃើញនៅឆកសមុទ្រជ្រោះប្រុសនៅចន្លោះ កោះកុង និងដីគោកប្រទេសកម្ពុជា ។[93] ទោះបីជាមានការខ្វះខាតការទទួលស្គាល់ជាអន្តរជាតិថាជាលមនៅដ៏មានតម្លៃក៏ដោយ ក៏ជ្រលងស្មៅសមុទ្រ ផ្ដល់នូវសេវាប្រព័ន្ធអេកូឡូហ្សីដ៏សំខាន់ផងដែរ ។ ជាសកល ពួកវារួមចំណែកស្រូបជាតិកាបោនពីសមុទ្រចំនួន 12%[94] ហើយមុខងារវិលចុះឡើងផ្ដល់ អាហារូបត្ថម្ភរបស់ពួកវាបានធ្វើឱ្យជ្រលងស្មៅសមុទ្រមានតម្លៃក្នុងមួយហិកតាខ្ពស់បំផុតនៃប្រព័ន្ធអេកូឡូហ្សីជាសកលទាំងអស់ ពីទស្សនទាន សេដ្ឋកិច្ចអេកូឡូហ្សី ។[95] ជាងនេះទៀត តាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ពួកវារក្សាគុណភាពទឹក ព្រមទាំងការពារប្រឆាំងភាពសឹករេចរឹល ។[96]



Rutger Geerling / Fotograseren.net

ឌូហ្គុង ប្រភេទពូជរងគ្រោះថ្នាក់មួយក្នុងចំណោមប្រភេទពូជជាច្រើន ស្ថិតក្រោមការគំរាមកំហែងពីឧស្សាហកម្មរុករកខ្សាច់របស់ប្រទេសកម្ពុជា

xv ជាភាសាឡាតាំង - *Dugong dugong* (ឌូហ្គុង); *Stenella longirostris* (ស្ពីននីដូហ្វីន); *(Hippocampus spp)* សេះសមុទ្រ និង *(Orcaella brevirostris)* អ៊ីរ៉ាវ៉ាឌីដូហ្វីន ។



Istock

ផ្កាថ្មប៉ប្រះទឹកនៅក្នុងឈូងសមុទ្រថៃ។ ផ្កាថ្ម ងាយរងផលប៉ះពាល់ជាពិសេសពីសកម្មភាពបូមខ្សាច់ ហើយការអនុវត្តប្រសើរបំផុតក្នុងការបូមខ្សាច់ជាអន្តរជាតិ ទទួលស្គាល់ពីចំងាយរងផលប៉ះពាល់ 70km ដែលអាចមានលើប្រព័ន្ធអេកូឡូហ្ស៊ីដែលងាយរងផលប៉ះពាល់ពីប្រតិបត្តិការបូមខ្សាច់។

ព្រៃកោងកាងរបស់ខេត្តកោះកុង ត្រូវបានចាត់ទុកថាជាដីសើមមានសារៈសំខាន់ជាអន្តរជាតិ ហើយត្រូវបានការពារស្ថិតក្រោមស្ថានភាពរបស់ពួកវាជាតំបន់រ៉ាំសារកោះកាពិ និងបរិវារកោះ ព្រមទាំងជម្រកសត្វព្រៃពាមក្រសោប (សូមមើលផែនទីខាងលើ)។ ពួកវាត្រូវបានចាត់ទុកថាជាព្រៃកោងកាងពីបុរាណមួយចំនួនក្នុងចំណោមព្រៃជាច្រើននៅអាស៊ី និងមានតួនាទីសំខាន់ក្នុងការផ្តល់ប្រភពអាហារូបត្ថម្ភសម្រាប់ជលផលតាមឆ្នេរសមុទ្រជា មូលដ្ឋានថែទាំ និងចិញ្ចឹមសំរាប់ប្រភេទពូជបាណកជាតិ និងការពារច្រាំងសមុទ្រពីសឹករិចរិល និងការខូចខាតពីព្យុះ។[97]

ព្រៃកោងកាងរបស់ខេត្ត កោះកុង ជួយដល់ប្រភពពូជបក្សី និងល្មូនរងគ្រោះជាច្រើន ដោយរួមទាំង អ៊ីរ៉ាវ៉ាឌី និងស្ពីន័រដូហ្វីន ព្រមទាំងអណ្តើកបៃតងផងដែរ។[98xvi] តំបន់នេះក៏ ជាលំនៅប្រភេទពូជភេរងគ្រោះ និងកម្រពីរ - ភេរោមរលោង និងភេមានច្រមុះរោមច្រើន ដែលប្រភេទមួយខាងក្រោយនេះរហូតមកទល់ពេលថ្មីៗនេះ ត្រូវបានចាត់ទុកថាផុតពូជទៅហើយ។[99xvii] រដ្ឋាភិបាលកម្ពុជាប៉ាន់ស្មានថា ផ្កាថ្មប៉ប្រះទឹកមាននៅតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ដែល មានផ្ទៃសរុប ២៨កម២ តែមានផ្កាថ្មមានជីវិតជាមធ្យមប្រមាណ 23% ទៅ 58% ប៉ុណ្ណោះ ដោយពួកវាត្រូវបានចាត់ទុកថាមានសុខភាពមិនល្អ។[100]

ដូចដែលផែនទី 1 និង 2 បង្ហាញ ការរុករករ៉ែខ្សាច់ កំពុងកើតឡើងច្បាស់ណាស់នៅក្បែរបរិវេណលំនៅងាយរងគ្រោះផ្នែកបរិស្ថានទាំងបីក្នុងចំណោម លំនៅទាំងនេះ។ គ្លូបលវីតណេសបានអង្កេតឃើញថាការបូមខ្សាច់កើតឡើងនៅក្នុងជម្រកសត្វព្រៃពាមក្រសោប និងតំបន់រ៉ាំសារកោះកាពិ និងបរិវារ កោះ ដូចដែលត្រូវបានរាយការណ៍ដោយសារព័ត៌មាននៅដើមឆ្នាំ 2009 ។[101] សម្បទានបូមខ្សាច់ ត្រូវបានផ្តល់ឱ្យនៅក្នុងឧទ្យានជាតិរាម ក្នុងខេត្ត ព្រះសីហនុ ហើយការបូមខ្សាច់ត្រូវបានអង្កេតឃើញក្នុងជ្រលងស្មៅសមុទ្រតាមឆ្នេរសមុទ្រខេត្តកំពត។[102] ទោះបីជាការបូមខ្សាច់កំពុងកើតឡើងនៅ ចម្ងាយឆ្ងាយពីផ្កាថ្មប៉ប្រះទឹករបស់ប្រទេសកម្ពុជាក៏ដោយ ក៏លំនៅទាំងនេះជាពិសេសងាយរងគ្រោះពីការបំពុលពីការបូមខ្សាច់ដែលអាចសម្លាប់ ផ្កាថ្មបាន។ [103]

ភាពស្ទាត់ជំនាញ និងការយល់ដឹងពីប្រព័ន្ធអេកូឡូហ្ស៊ីដ៏មានសារៈសំខាន់ទាំងនេះ ត្រូវបានសិក្សា ឬយល់ដឹងតិចតួច[104] ហើយដោយមិនមានមូលដ្ឋាន វិទ្យាសាស្ត្រនេះ វាគឺជាការពិបាកណាស់ដើម្បីវាស់បរិមាណផលប៉ះពាល់ដែលប្រតិបត្តិការបូមខ្សាច់ ផ្ទុក និងដឹកជញ្ជូននឹងមាន។ ឧទាហរណ៍ សេចក្តីណែនាំពីការអនុវត្តប្រសើរបំផុតក្នុងការបូមខ្សាច់ជាអន្តរជាតិ កំណត់ការគ្រប់គ្រងបរិស្ថានសម្រាប់ផលប៉ះពាល់ពីប្រតិបត្តិការ ដោយប្រើប្រាស់លំដាប់ដែលអាចមានចម្ងាយ 70km សម្រាប់ផលប៉ះពាល់ដោយផ្ទាល់ (សូមមើលខាងក្រោមសំរាប់ព័ត៌មានលំអិត)។ ផ្អែកលើការទទួលយក *"គោលការណ៍ប្រុងប្រយ័ត្នជាមុន"* [105] ជាមូលដ្ឋានអន្តរជាតិសំរាប់ការគ្រប់គ្រងបរិស្ថានការបូមខ្សាច់នៅក្នុងប្រព័ន្ធអេកូឡូហ្ស៊ីដ៏មានសារៈសំខាន់ជា សកលទាំងនេះ ហាក់បីដូចជាមិនមានការទទួលខុសត្រូវទាល់តែសោះ។ ស្នូលនៃគោលការណ៍ប្រុងប្រយ័ត្ននេះ (គោលការណ៍ទី 15 នៃសេចក្តីប្រកាសនៅទីក្រុងរីអូឆ្នាំ 1992) ចែងថា *"កន្លែងណាដែលមានការគំរាមកំហែងពីការខូចខាតធ្ងន់ធ្ងរ ឬមិនអាចកែប្រែវិញបាន ការខ្វះខាតភាពច្បាស់លាស់ ផ្នែកវិទ្យាសាស្ត្រ*

xvi ជាភាសាឡាតាំង - *Chelonia mydas.*

xvii ជាភាសាឡាតាំង - *Lutra sumatrana* (ភេច្រមុះមានរោមច្រើន) និង *Lutrogale perspicillata* (ភេរោមរលោង)។



Flickr / Zoe Tucker

អ្នកនេសាទក្តាមនៅឧទ្យានជាតិរាម ខេត្តព្រះសីហនុ ប្រទេសកម្ពុជា
ជាកន្លែងដែលក្រុមហ៊ុនមួយត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យបូមខ្សាច់ដោយរដ្ឋាភិបាលប្រទេសកម្ពុជា
នៅក្នុងខែ កក្កដា ឆ្នាំ 2009 ។

*ពេញលេញ នឹងមិនត្រូវបានប្រើប្រាស់ជាមូលហេតុមួយសំរាប់ការផ្អាកវិធានការណ៍ដែលមានប្រសិទ្ធិភាពចំណាយ ដើម្បីទប់ស្កាត់ការ ខូចខាតបរិស្ថានបានឡើយ ។"*

## ផលប៉ះពាល់លើជីវភាពរស់នៅពឹងលើផលផលតាមឆ្នេរសមុទ្រ

ការបូមខ្សាច់ដោយគ្មានការការពារសុវត្ថិភាពគ្រប់គ្រាន់ ក៏ប្រថុយនឹងការបំផ្លិចបំផ្លាញជីវភាពរស់នៅក្នុងតំបន់ផងដែរ ។ បណ្តាសហគន៍នៅក្នុងខេត្ត កោះកុង និងខេត្តកំពតបានរាយការណ៍ថា ការបូម និងការដឹកជញ្ជូនខ្សាច់ បានកាត់បន្ថយពូជត្រី និងបានបំផ្លិចបំផ្លាញទិន្នផលក្តាមផងដែរ ។[xviii][106] ពួកគេក៏បានរាយការណ៍ផងដែរថា ការកំពប់ប្រេងពីនាវាបូមខ្សាច់បានបំពុលទឹក ហើយថានាវាចរណ៍របស់ទូកនេសាទនៅក្នុងតំបន់ បានប្រែទៅជា មានគ្រោះថ្នាក់ ។[107] នៅក្នុងខេត្តកោះកុង គ្រួបលវិតណេសត្រូវបានរាយការណ៍ប្រាប់ថា *"ការចាប់ត្រីបានធ្លាក់ចុះ 50% ការធ្លាក់ចុះនេះខ្លាំងណាស់ ។ ការធ្លាក់ចុះនេះបានចាប់ផ្តើមនៅពេលដែលនាវា ឱ្យបូមខ្សាច់ បានមកដល់... នាថ្ងៃណាមួយ យើងនឹងមិនចាប់បានត្រីទាល់តែសោះ ។*[108] ប្រជា នេសាទផ្សេងទៀតបានពន្យល់ថា *"អាជីវកម្មនៅទីនេះមានតែការនេសាទប៉ុណ្ណោះ"* តែចាប់តាំងពីការបូមខ្សាច់បានចាប់ផ្តើម *"ក្តាមអស់ ប្រជាជននៅ ទីនេះបានពឹងផ្អែកលើពួកវា តែឥឡូវនេះពួកវាគ្មានទេ"* ។[109] បណ្តាសហគមន៍បានពន្យល់ថា ពួកគេមិនបានទទួលផលប្រយោជន៍ពីការបូមខ្សាច់ក្នុងទម្រង់ណាមួយឡើយ ពិតណាស់ *"ប្រជាជននឹងអត់ឃ្លាន... ប៉ុន្មានថ្ងៃនេះ ប្រជាជននៅខេត្តកោះកុងកំពុងស្រែកឃ្លាន"* ។[110] ពួកគេមិនត្រូវបានប្រឹក្សាដោយក្រុមហ៊ុន មុនពេលពួកគេបានចាប់ផ្តើមប្រតិបត្តិការទេ ឬពួកគេមិនបានទទួលដំណឹងពីអាជ្ញាធរមូលដ្ឋានថា អាជ្ញាប័ណ្ណបូមខ្សាច់ត្រូវបានចេញឱ្យនោះឡើយ ។[111]

នៅក្នុងខែ តុលា ឆ្នាំ 2009 តំណាងសហគមន៍ប្រមាណ 300 នាក់មកពីបណ្តាភូមិរងផលប៉ះពាល់ បានធ្វើដំណើរមកកាន់សាលាខេត្តដោយមានបណ្តឹងជាលាយលក្ខណ៍អក្សរមួយ និងបណ្តឹងដែលមានហត្ថលេខាជាង 1,000 ស្នើសុំឱ្យបញ្ឈប់ការបូមខ្សាច់ ។ នៅថ្ងៃទី 5 ខែ វិច្ឆិកា សមាជិកសភាជាតិបានសរសេរលិខិតទៅកាន់ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម តំណាងឱ្យ 1,229 គ្រួសារនៅក្នុងតំបន់ដូចគ្នានេះ ស្នើសុំឱ្យឯកឧត្តមអន្តរាគមន៍ដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃការបូមខ្សាច់ ។[112] អាជ្ញាធរខេត្តបានសន្យាថា ពួកគេនឹងដោះស្រាយបញ្ហាទាំងនេះ តែមកដល់ពាក់កណ្តាលខែ មករា ឆ្នាំ 2010 អត្ថបទជាច្រើនរបស់ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថា គ្មានអ្វីបានកែលំអនោះឡើយ ។[113]

ជាថ្មីម្តងទៀត បើគ្មានទិន្នន័យមូលដ្ឋានគ្រប់គ្រាន់ទេ យើងមិនអាចដឹងពីវិសាលភាពដែលការធ្លាក់ចុះទិន្នផលយ៉ាងខ្លាំងទាំងនេះត្រូវបានបណ្តាលមកពី ប្រតិបត្តិការបូមខ្សាច់ឡើយ ទោះបីជាពួកវាបានកើតឡើងដំណាលគ្នាក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយវាមានភាពជាក់ច្បាស់ថា រដ្ឋាភិបាលកំពុងព្រងើយកន្តើយនឹងបទដ្ឋានអន្តរជាតិ ជាពិសេស គោលការណ៍ប្រុងប្រយ័ត្នជាមួយដោយការមិនបានចាត់វិធានការណ៍ពេញលេញលើរបាយការណ៍ពីបណ្តាសហគមន៍តាមឆ្នេរសមុទ្រ ចំពោះបញ្ហាដែលមានជាបន្តបន្ទាប់ចាប់តាំងពីការបូមខ្សាច់បានចាប់ផ្តើមមក ទោះបីជាសេចក្តីសម្រេចស្តីពីការធ្វើ អាជីវកម្មហាក់បីដូចជាកំពុងចេញផ្សាយគ្រាន់តែដើម្បីដោះស្រាយការបារម្ភនេះក៏ដោយ ។

វាក៏ហាក់បីដូចជាថា តំណាងរដ្ឋាភិបាលខ្លួនឯង មានព័ត៌មានផ្ទុយគ្នាចំពោះវិស័យខ្សាច់របស់ប្រទេសកម្ពុជា និងក្របខណ្ឌច្បាប់របស់ខ្លួន។ តំណាងក្រសួងធនធានទឹក និងឧតុនិយមបានប្រាប់សារព័ត៌មាននៅក្នុងខែ តុលា ឆ្នាំ 2009 ថា ពួកគេកំពុងស៊ើបអង្កេតបញ្ហា តែថាការចោទប្រកាន់ពីបណ្តា សហគមន៍មិនត្រូវបានរកឃើញថាការបូមខ្សាច់បានកំពុងកើតឡើងរហូតដល់ 17km ពីឆ្នេរសមុទ្រ នៅក្នុងតំបន់ដែលមិនមានកន្លែងបង្កើតកូន

*"ប្រជាជននឹងអត់ឃ្លាន... ប៉ុន្មានថ្ងៃនេះ ប្រជាជននៅខេត្តកោះកុងកំពុងស្រែកឃ្លាន"* ។

ប្រជានេសាទនៅក្នុងខេត្តកោះកុង ប្តឹងគ្រួបលវិតណេសអំពីផលប៉ះពាល់ពីការបូមខ្សាច់លើជីវភាពរស់នៅរបស់ពួកគេ

ស្នូលនៃគោលការណ៍ប្រុងប្រយ័ត្ននេះ (គោលការណ៍ទី 15 នៃសេចក្តីប្រកាស នៅទីក្រុងរីអូឆ្នាំ 1992) ចែងថា

*"កន្លែងណាដែលមានការគំរាមកំហែងពីការខូចខាតធ្ងន់ធ្ងរ ឬមិនអាចកែប្រែវិញបាន ការខ្វះខាតភាពច្បាស់លាស់ផ្នែកវិទ្យាសាស្ត្រពេញលេញ នឹងមិនត្រូវបានប្រើប្រាស់ជាមូលហេតុមួយសំរាប់ការផ្អាកវិធានការណ៍ដែលមានប្រសិទ្ធិភាពចំណាយ ដើម្បីទប់ស្កាត់ការខូចខាតបរិស្ថានបានឡើយ ។"*

សេចក្តីប្រកាសនៅទីក្រុងរីអូស្តីពីបរិស្ថាន
និងការអភិវឌ្ឍន៍ សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន
និងការអភិវឌ្ឍន៍ ខែ មិថុនា ឆ្នាំ 1992

xviii ជាភាសាឡាតាំង - *Portunidae callinectes* ។

*និន្នាការនេះ ដែលក្នុងនេះប្រជាជនមូលដ្ឋាន និងបរិស្ថានប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងបង់ប្រាក់ចំណាយចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស ស្របពេលដែលវរជនមានអំណាចមួយចំនួនតូចទទួលបានអត្ថប្រយោជន៍ ត្រូវបានកត់ត្រាទុកដោយគ្លូបលវីតណេសតាំងពីឆ្នាំ 1995 ។*



Amnesty International

ប្រជានេសាទក្នុងតំបន់នៅក្នុងខេត្តកោះកុង បានតវ៉ាថា ពូជត្រី និងទិន្នផលក្តាមរបស់ពួកគេត្រូវបានបំផ្លិចបំផ្លាញបន្ទាប់ពីនាវាបូមខ្សាច់បានមកដល់

ហើយថាការតវ៉ារបស់សហគមន៍ត្រូវបានបញ្ឆេះដោយ "អ្នកញុះញង់" ។[114] ស្របពេលជាមួយគ្នានេះដែរ ការសម្ភាសន៍តាមទូរទស្សន៍នៅក្នុងខែ តុលា ឆ្នាំ 2009 ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយមបាននិយាយថា "*មកទល់ពេលនេះ រដ្ឋាភិបាលមិនបានអនុញ្ញាតឱ្យក្រុមហ៊ុនណាមួយបូមខ្សាច់នៅក្នុងសមុទ្រឡើយ*" ហើយបានរៀបរាប់ពីរបៀបថាតើការបូមខ្សាច់កំពុងកើតឡើងនៅក្នុងតែតំបន់ទន្លេមានយ៉ាង ដូចម្តេច ដែលតម្រូវឱ្យមានការបូមខ្សាច់ដើម្បីសំរាលទឹកជំនន់ ។[115]
បន្ទាប់ពីការទៅកាន់តំបន់នោះនៅក្នុងខែ តុលា ឆ្នាំ 2009 ឯកឧត្តម លឹម គានហោ បានរាយការណ៍ថាការកំពប់ប្រេងមិនបានកំពុងកើតឡើងឡើយ ហើយថារាល់ប្រតិបត្តិការបូមខ្សាច់ទាំងអស់ កំពុងប្រតិបត្តិការបន្ទាប់ពីមាន "*ការធ្វើអធិការកិច្ចពេញលេញ*" ដោយគណៈកម្មការ ។[116] ស្របពេលនេះដែរ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកោះកុងបានឱ្យដឹងថា បណ្តាសហគមន៍មូលដ្ឋាន ត្រូវតែប្រឈមមុខនឹងការខាតបង់រយៈពេលខ្លីសម្រាប់ផលប្រយោជន៍ជាតិទាំងមូល ។[117] និន្នាការនេះ ដែលក្នុងនេះប្រជាជនមូលដ្ឋាន និងបរិស្ថានប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងបង់ប្រាក់ចំណាយចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស ស្របពេលដែលវរជនមានអំណាចមួយចំនួនតូចទទួលបានអត្ថប្រយោជន៍ ត្រូវបានកត់ត្រាទុកដោយគ្លូបលវីតណេសតាំងពីឆ្នាំ 1995 .



Istock

អណ្តើកបៃតង ប្រភេទពូជរងគ្រោះថ្នាក់មួយក្នុងចំណោមប្រភេទពូជជាច្រើន ស្ថិតក្រោមការគំរាមកំហែងពីឧស្សាហកម្មរុករកខ្សាច់របស់ប្រទេសកម្ពុជា

# 4. ការផ្ទេរខ្សាច់

## បរាជ័យនៃក្របខណ្ឌច្បាប់ដើម្បីគ្រប់គ្រងវិស័យខ្សាច់របស់ប្រទេសកម្ពុជា

**ដោយការការពារបរិស្ថាន និងសង្គមដែលមានស្រាប់នៅក្នុងកាតព្វកិច្ចច្បាប់ជាតិ និងអន្តរជាតិរបស់ប្រទេសកម្ពុជា មិនត្រូវបានអនុវត្ត នោះការសន្យា ពីរដ្ឋាភិបាលថា បំរាមខ្សាច់នេះ (សេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្ម) នឹងដោះស្រាយបញ្ហាទាំងនេះ នៅតែគួរឱ្យសង្ស័យ ។ ជំនួសឱ្យការគ្រប់គ្រង វិស័យនេះ សេចក្តីសម្រេចនេះ បានសំរបសំរួលយ៉ាងធំធេង នូវការពង្រីកការបូមខ្សាច់សំរាប់ការនាំចេញតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា ។ គ្លូបលវីតណេសជឿជាក់ថា នេះគឺជាផ្នែកមួយនៃនិន្នាការកាន់តែទូលំទូលាយនៃការបង្កើតច្បាប់នៅក្នុងប្រទេសកម្ពុជា ដែលរចនាសម្ព័ន្ធស្របគ្នានេះ ត្រូវបានបង្កើតឡើងសំរាប់គ្រប់គ្រងប្រភពធនធានដែលមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ចនេះ ដែលផ្តល់ឱ្យនូវការគ្រប់គ្រងប្រតិបត្តិមិនទាន់ដល់កម្រិត ដល់រដ្ឋាភិបាលកណ្តាល ហើយធ្វើឱ្យអន្តរាយដល់ការការពារដែលមានស្រាប់ ។ ចាប់តាំងពីមានទស្សនទានឧស្សាហកម្មនេះមក សេចក្តីណែនាំពីការ អនុវត្តប្រសើរបំផុតជាអន្តរជាតិសំរាប់ក្រុមហ៊ុនដលពាក់ព័ន្ធនឹងការបូមខ្សាច់ ក៏ហាក់បីដូចជាមិនត្រូវបានយកចិត្តទុកដាក់ផងដែរ ។**

ច្បាប់ប្រទេសកម្ពុជាចែងថា នៅពេលគម្រោងប្រថុយនឹងផលប៉ះពាល់បរិស្ថានសំខាន់ៗ ដូចដែលត្រូវបានរំពឹងទុកពីការបូមខ្សាច់នៅក្នុងបណ្តាលំនៅដែលមានសារៈសំខាន់ជាអន្តរជាតិ នោះការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ត្រូវតែបំពេញមុនការអនុម័តគម្រោង ។[118] ការវាយតម្លៃនេះ ត្រូវ រួមមានផែនការគ្រប់គ្រងបរិស្ថាន និងជម្រុញឱ្យមានការចូលរួមជាសាធារណៈ ។[119] ជាពិសេស អនុក្រិត្យស្តីពី EIAs ចែងថា សកម្មភាពបូមខ្សាច់ លើសពី 50,000$m^3$ តម្រូវឱ្យមានការវាយតម្លៃផលប៉ះពាល់បរិស្ថានបឋម និងពេញលេញ ។[120]

ចាប់តាំងពីការអនុម័តច្បាប់ស្តីពីតំបន់ការពារនៅក្នុងឆ្នាំ 2008 ការរុករករ៉ែ ត្រូវបានអនុញ្ញាតឱ្យមាននៅក្នុងផ្នែកជាក់លាក់មួយចំនួននៃតំបន់ ការពារ ។[121]



អនុក្រិត្យរបស់រដ្ឋាភិបាលប្រទេសកម្ពុជាស្តីពីដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន មានបំណងទប់ស្កាត់ការខូចខាតបរិស្ថាន ។

ច្បាប់ស្តីពីតំបន់ការពារបញ្ជាក់ជាថ្មីពីសិទ្ធិអំណាចនៃក្រសួងបរិស្ថានដើម្បីគ្រប់គ្រងតំបន់ការពារដែលរួមទាំង *"ការកំណត់តំបន់"* នៃតំបន់ការពារដែលមានស្រាប់ផងដែរ ។[122] ក្នុងចំណោមតំបន់ទាំងបួន សកម្មភាពអភិវឌ្ឍន៍ អាចត្រូវបានធ្វើឡើងតែនៅក្នុង "តំបន់ប្រើប្រាស់ប្រកបដោយចីរភាព" នៃតំបន់ការពារតែប៉ុណ្ណោះ ។ សកម្មភាពអភិវឌ្ឍន៍ អាចត្រូវបានអនុញ្ញាតឱ្យនៅក្នុងតំបន់ទាំងនេះ តែបន្ទាប់ពីមានការប្រឹក្សាជាមួយបណ្តាក្រសួង អាជ្ញាធរ និងសហគមន៍ពាក់ព័ន្ធ និងយោងតាមសំណើពីក្រសួងបរិស្ថានតែប៉ុណ្ណោះ ។[123] ការបូមខ្សាច់នៅក្នុងតំបន់ទាំងនេះ ត្រូវអនុវត្តតាមច្បាប់ផ្សេងទៀតទាំងអស់ ហើយត្រូវស្ថិតក្រោម EIA ជាមុន ។ ការស៊ើបអង្កេតរបស់គ្លូបលវីតណេស មិនអាចស្វែងរកភស្តុតាងណាមួយថា EIAs



ព្រៃកោងកាងរបស់ខេត្តកោះកុង ដែលត្រូវបានការពារដោយអនុសញ្ញារ៉ាំសារសំរាប់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ កំពុងស្ថិតក្រោមការគំរាមកំហែងពីប្រតិបត្តិការបូមខ្សាច់



គ្លូបលវីតណេស

នាវាក្រុមហ៊ុន Winton ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 កំពុងផ្ទុកខ្សាច់នៅក្នុងជម្រកសត្វព្រៃពាមក្រសោប និងតំបន់រុំាសារកោះកាពិ ខេត្តកោះកុង ប្រទេសកម្ពុជា។ ក្រុមហ៊ុន Winton Enterprises ត្រូវបានរាយការណ៍ថាជាដៃគូក្រុមហ៊ុន L.Y.P. Group ដើម្បីនាំចេញខ្សាច់ពីប្រទេសកម្ពុជា ទៅកាន់ប្រទេសសិង្ហបុរី។

ឬការប្រឹក្សាណាមួយ ត្រូវបានធ្វើឡើងនៅក្នុងតំបន់ដែលបានផ្តល់អាជ្ញាប័ណ្ណសំរាប់ការបូមខ្សាច់នៅក្នុងខេត្តកោះកុង ហើយប្រជានេសាទដែលបានសំភាសន៍បាននិយាយថា ពួកគេមិនបានពាក់ព័ន្ធនឹងការវាយតម្លៃណាមួយ មុនពេលការចាប់ផ្តើមសកម្មភាពបូមខ្សាច់ឡើយ ។[124] បញ្ជីរាយឯកសារដែលយោងនៅក្នុងអាជ្ញាប័ណ្ណដែលបានពិនិត្យដោយគ្លូបលវីតណេស មិនមាននូវ EIAs ឬផែនការគ្រប់គ្រងបរិស្ថាន ឬឯកសារនេះមិនសំដៅទៅលើការយល់ព្រមដែលត្រូវបានផ្តល់ឱ្យជាផ្លូវការ ដោយក្រសួងបរិស្ថាន សំរាប់ការបូមខ្សាច់ឱ្យកើតឡើងនៅក្នុងតំបន់ការពារឡើយ ។ តាមការពិត តម្រូវការសំរាប់ការវាយតម្លៃបរិស្ថាន ឬជលផលនៅក្នុងឯកសារលិខិតយល់ព្រមដែលបានទទួលបានដោយគ្លូបលវីតណេសសំរាប់សម្បទានបូមខ្សាច់របស់ក្រុមហ៊ុន L.Y.P. Group ក្រុមហ៊ុន Mong Reththy Group និងក្រុមហ៊ុន Udom Seima គឺសំរាប់ធ្វើរបាយការណ៍ពីពីរទៅប្រាំខែ *បន្ទាប់ពី* ចុះហត្ថលេខាកិច្ចសន្យារួច ។[125] គ្លូបលវីតណេសបានសរសេរលិខិតទៅកាន់រដ្ឋាភិបាលប្រទេសកម្ពុជា និងក្រុមហ៊ុនដែលបានរៀបរាប់នៅក្នុងរបាយការណ៍ សាកសួរអំពីស្ថានភាព EIAs ។ មកទល់ពេលនៃ ការបោះពុម្ពផ្សាយ មានតែក្រុមហ៊ុន Mong Reththy Group បានឆ្លើយតបដូចបានរៀបរាប់លើទំព័រ 13 ។

ការការពារ អាចត្រូវបានផ្តល់ឱ្យលំនៅក្នុងសមុទ្រដែលងាយរងគ្រោះរបស់ប្រទេសកម្ពុជា តាមរយៈផែនការសកម្មភាពថ្នាក់ជាតិសំរាប់ការគ្រប់គ្រង ផ្កាថ្មប៉ប្រះទឹក និងស្មៅសមុទ្រនៅក្នុងប្រទេសកម្ពុជា (2006 - 2015) និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ ។ គួរឱ្យសោកស្តាយ មិនមានគោលនយោបាយណាមួយក្នុងចំណោមនេះ ទទួលស្គាល់ការបូមខ្សាច់ថាជាការគំរាមកំហែងទៅកាន់លំនៅក្នុងសមុទ្រ ឬឯកសារទាំងនេះមិនបញ្ជាក់ ច្បាស់លាស់ពីយន្តការសំរាប់ដោះស្រាយជម្លោះជាមួយនឹងបណ្តាក្រសួងពាក់ព័ន្ធនឹងឧស្សាហកម្មដកស្រង់ធនធានឡើយ ។[xix]

គ្លូបលវីតណេសជឿជាក់ថា ការផ្តល់ការអនុញ្ញាតឱ្យបូមខ្សាច់នៅក្នុងតំបន់ការពារ និងក្បែរបរិវេណប្រព័ន្ធអេកូឡូហ្ស៊ីដែលមានសារៈសំខាន់ជាអន្តរជាតិ គឺជាភស្តុតាងថា រដ្ឋាភិបាលប្រទេសកម្ពុជា ក៏កំពុងព្រងើយកន្តើយចំពោះកាតព្វកិច្ចរបស់ខ្លួនស្ថិតក្រោមក្របខណ្ឌជាអន្តរជាតិ ។ ប្រទេស កម្ពុជា គឺជាភាគីមួយនៃអនុសញ្ញាជីវចំរុះជីវសាស្ត្រ (CBD) ហើយគឺជាហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) ។[xx] ទាំងនេះ បង្កើតឱ្យមានកាតព្វកិច្ចលើបណ្តាភាគីដើម្បីការពារ និងរក្សាបរិស្ថានសមុទ្រ ព្រមទាំងទប់ស្កាត់ការបំពុលបរិស្ថាន ។[126] ចាប់តាំងពីឆ្នាំ 1992 គោលការណ៍ប្រុងប្រយ័ត្នជាមុន ត្រូវបានរួមបញ្ចូលក្នុងក្របខណ្ឌ UNCLOS ជាពិសេសពាក់ព័ន§នឹងការកំណត់និយមន័យពី ការបំពុល (មាត្រា 1) ព្រមទាំងកាតព្វកិច្ចអនុវត្ត EIAs (មាត្រា 206) ។[127] គ្លូបលវីតណេសមិនអាចរកឃើញភស្តុតាងថាតើ CBD ឬ UNCLOS កំពុងត្រូវបានអនុវត្ត តាមរយៈការដាក់បញ្ចូលជាផ្លូវការក្នុងច្បាប់ប្រទេសកម្ពុជាដែរឬអត់ ។ ទោះយ៉ាងណា រហូតមកទល់ថ្ងៃចូលជាធរមាននេះមាន ឡើង រដ្ឋាភិបាលប្រទេសកម្ពុជា នៅតែមានកាតព្វកិច្ចទប់ស្កាត់សកម្មភាពដែលនឹងប៉ះពាល់ដល់គោលបំណងនៃសន្ធិសញ្ញាទាំងពីរ ។ [128]

នៅក្នុងឆ្នាំ 1999 ប្រទេសកម្ពុជាបានក្លាយជាភាគីមួយនៃអនុសញ្ញារុំាសារស្តីពីដីសើម និងបានកំណត់កោះកាពិ និងបរិវារកោះជាតំបន់រុំាសារ ។[xxi] ស្ថិត ក្រោមអនុសញ្ញានេះ ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តរក្សាលក្ខណៈអេកូឡូហ្ស៊ីនៃដីសើម និងធានាឱ្យបាននូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និង ចេរភាពរបស់ពួកគេ ។[129] ជាងនេះទៀត ភាពខ្វះខាតនៃជីវភាពរស់នៅដែលបណ្តាលមកពីទិន្នផល និងក្តាមត្រូវបានបំផ្លិចបំផ្លាញ - ប្រសិនបើបណ្តាល មកពីការបូមខ្សាច់ - នោះនឹងបំពានលើមាត្រា 1 (គ្មាននរណាម្នាក់មានភាពខ្វះខាតលើមធ្យោបាយចិញ្ចឹមជីវិតឡើយ) និងមាត្រា 11 (សិទ្ធិទទួល បានកម្រិតជីវភាពរស់នៅសមរម្យ) របស់អនុសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធមិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ 1992 ។

xix គ្លូបលវីតណេស បានកំពុងពិនិត្យព័ត៌មានចុងក្រោយអំពីផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិរបស់ប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ 2009 និង 2010 ។ ពង្រាងចុងក្រោយបំផុតដែលបាន ចេញផ្សាយ (ថ្ងៃទី 17 ខែ ធ្នូ ឆ្នាំ 2009) មិនបានបញ្ចូលសេចក្តីយោងណាមួយទៅកាន់ការបូមខ្សាច់នៅក្នុងផ្នែកដែលពណ៌នាអំពីគោលដៅថ្នាក់ជាតិសម្រាប់វិស័យនេសាទ។

xx ប្រទេសកម្ពុជាបានយល់ព្រមចំពោះ CBD នៅក្នុងឆ្នាំ 1995 ។ ប្រទេសកម្ពុជា គឺជាហត្ថលេខីចំពោះ UNCLOS (1993) តែបានផ្តល់សច្ចាប័នឱ្យ។

xxi កោះកាពិ និងបរិវារកោះ បានក្លាយជាតំបន់រុំាសារនៅក្នុងឆ្នាំ 1999 ហើយប្រទេសកម្ពុជាបានក្លាយជាភាគីចុះកិច្ចសន្យានៃអនុសញ្ញារុំាសារស្តីពីដីសើមផងដែរនៅក្នុងឆ្នាំ 1999 ។



សេចក្តីសំរេចពាក់ព័ន្ធនឹងការកម្រិត និងការធ្វើអាជីវកម្មខ្សាច់ ចេញដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី 8 ខែ ឧសភា ឆ្នាំ 2009 ។

## ការប្រកាសរបស់នាយករដ្ឋមន្ត្រី៖ ការបរាជ័យគ្រប់គ្រងវិស័យខ្សាច់

បីខែបន្ទាប់ពី *ប្រទេសជាតិលក់* ត្រូវបានបោះពុម្ពផ្សាយ នៅថ្ងៃទី 8 ខែ ឧសភា ឆ្នាំ 2009 នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសកែលំអអភិបាលកិច្ចនៃវិស័យរុករករ៉ែរបស់ប្រទេសកម្ពុជា តាមរយៈសេចក្តីសម្រេចពាក់ព័ន្ធនឹងការកម្រិតលើការធ្វើអាជីវកម្មខ្សាច់ ។[130] សេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់នេះ ត្រូវបានប្រកាសជា *"ការបញ្ចប់ប្រតិបត្តិការបូមខ្សាច់ រហូតទាល់តែការវាយតម្លៃបរិស្ថានទូទាំងឧស្សាហកម្ម និងការពិនិត្យដំណើរការផ្តល់អាជ្ញាប័ណ្ណឡើងវិញអាចបំពេញរួចសព្វគ្រប់"* ។[131] នាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀតបានពន្យល់ថា បំរាមនាំចេញខ្សាច់នេះ ត្រូវបានចេញ ឆ្លើយតបនឹងការតវ៉ាក្នុងតំបន់ ហើយនឹងធានាឱ្យបានការការពារបរិស្ថាន ។ ទោះយ៉ាងណា ក្រុមហ៊ុនមួយចំនួននឹងត្រូវបានអនុញ្ញាត ឱ្យបន្ត ប្រសិនបើសកម្មភាពរបស់ពួកគេមិនប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជន ។[132] ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍យ៉ាងទូលំទូលាយពី វិធានការណ៍ទាំងនេះថាជាបំរាមពេញលេញលើការនាំចេញខ្សាច់ដោយរដ្ឋាភិបាលប្រទេសកម្ពុជា ហើយនៅពេលនោះអាជ្ញាធរសាងសង់ និងសំណង់របស់ប្រទេសសិង្ហបុរីបានឆ្លើយតបដោយនិយាយថា ដោយមានការផ្លាស់ប្តូរប្រភពធនធានរបស់ខ្លួន បំរាមខ្សាច់របស់ប្រទេសកម្ពុជា ហាក់បីដូចជាមិនប៉ះពាល់ដល់គម្រោងដែលមានស្រាប់ឡើយ ។[133]

ទោះយ៉ាងណាក៏ដោយ សេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ មាននូវភាពខុសគ្នាជាច្រើន ហើយមិនមែនជាបំរាម*ពិសេស* លើការនាំចេញទេ ។ គ្លូបលវីតណេសជឿជាក់ថា ការភ័ន្តច្រឡំពីគោលបំណងនៃសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ ប្រហែលជាកើតចេញពីភាពខ្លីនៃសេចក្តី សម្រេច ។ ពាក្យសំខាន់ៗ មិនត្រូវបានកំណត់និយមន័យច្បាស់លាស់ ដែលធ្វើឱ្យមានបញ្ហាដល់ការបកស្រាយ និងការអនុវត្ត ។ ប្រការ 1.1 ហាមយ៉ាង ច្បាស់ពី ការនាំចេញ*ខ្សាច់ទន្លេ* រីឯប្រការ 1.2 អនុញ្ញាតឱ្យមានការធ្វើអាជីវកម្មជាបន្តលើ*ខ្សាច់សមុទ្រ* សំរាប់ទីផ្សារនាំចេញ ប្រសិនបើវាមកពីតំបន់ រាក់ៗដែលខ្សាច់អាចបំពេញបានវិញជាធម្មតា ។[134] ចាប់តាំងពីសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ត្រូវបានប្រកាសមក សម្បទានបូមខ្សាច់ឱ្យ ក្រុមហ៊ុន L.Y.P. Group ក្រុមហ៊ុន Udom Seima និងក្រុមហ៊ុន Mong Reththy Group សំរាប់ខ្សាច់*ទន្លេ* ត្រូវបានផ្តល់អាជ្ញាប័ណ្ណជាថ្មី ដោយមាន ការបំពានដោយផ្ទាល់លើប្រការ 1.1 ដែលបង្ហាញថា អាជ្ញាធរគ្រប់គ្រងមិនបកស្រាយ ឬអនុវត្តដូចគ្នាទាំងអស់លើបញ្ញត្តិនៃច្បាប់នេះ ។ ភាពផ្ទុយគ្នាក្នុងការយល់ដឹងពីបញ្ញត្តិនៃច្បាប់ និងប្រតិបត្តិការបូមខ្សាច់ពីមន្ត្រីនៅក្នុងក្រសួងធនធានទឹក និងឧតុនិយមដែលបានរៀបរាប់ជាសង្ខេប នៅទំព័រ 21 ខាងលើ បង្ហាញពីបញ្ហាដែលអាចមានសំរាប់ការអនុវត្តសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ ។

ដំណើរការដែលបានរៀបរាប់នៅក្នុងសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ ក៏មិនមានភាពច្បាស់លាស់ដែរ ។ វាចូលជាធរមាននៅថ្ងៃទី 8 ខែ ឧសភា ឆ្នាំ 2009 ហើយប្រគល់កាតព្វកិច្ចឱ្យ *"គណៈកម្មការគ្រប់គ្រងធនធានខ្សាច់"* ធ្វើអធិការកិច្ចឡើងវិញនូវប្រតិបត្តិការបូមខ្សាច់ និង រាយការណ៍ជូននាយករដ្ឋមន្ត្រីសំរាប់សេចក្តីសម្រេចប្រតិបត្តិនាពេលចេញអាជ្ញាប័ណ្ណជាថ្មីនាពេលអនាគត ។[xxii][135] ដោយត្រូវបានបង្កើតនៅក្នុងឆ្នាំ 2006 គណៈកម្មការខ្សាច់នេះ ត្រូវបានបង្កើតឡើងដោយតំណាងមកពីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងបរិស្ថាន និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។[136] វាគឺជាគណៈកម្មការដែលទទួលខុសត្រូវចេញអាជ្ញាប័ណ្ណជាថ្មីសំរាប់ការធ្វើអាជីវកម្មខ្សាច់ដូចបានរៀបរាប់ខាងលើ ។ គួរឱ្យចាប់អារម្មណ៍ ការបាត់វត្តមានរដ្ឋបាលជលផលដែលទទួលខុសត្រូវចំពោះការអនុវត្ត យន្តការការពារផ្កាថ្មប៉ប្រះទឹក និងជ្រលងស្មៅសមុទ្រ ។ ទោះយ៉ាងណា សេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ មិនពន្យល់ពីដំណើរការអនុវត្ត សេចក្តីសម្រេច ឬមិនបានបង្ហាញពីតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារអនុវត្ត ឬមិនបានបង្ហាញថាតើអ្វីដែលក្រុមហ៊ុនមានអាជ្ញាប័ណ្ណបូមខ្សាច់ ដែលមានស្រាប់គួរអនុវត្តអំឡុងពេលធ្វើអធិការកិច្ចជាថ្មី ។ ជាងនេះទៀត សេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ មិនយោង ឬហាក់បីដូចជាមិនត្រូវបានធ្វើឱ្យត្រូវគ្នាជាមួយនឹងច្បាប់ដែលមានស្រាប់ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់ និងការផ្តល់អាជ្ញាប័ណ្ណនាំចេញ ដោយស្ថិតក្រោមក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពលឡើយ ។ ប្រសិនបើសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ ដាក់ការទទួលខុសត្រូវពិនិត្យឡើងវិញនូវប្រតិបត្តិការ បូមខ្សាច់ និងការនាំចេញនៅក្នុងដៃរបស់គណៈកម្មការខ្សាច់ ហើយចុងក្រោយបំផុតគឺនាយករដ្ឋមន្ត្រី នេះនឹងលើកឡើងជាចម្ងល់ជាច្រើនពាក់ព័ន្ធនឹង ការពិនិត្យមើលនាពេលអនាគតរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងភ្នាក់ងារផ្សេងទៀតដូចជា ក្រសួងបរិស្ថានជាដើម ។

សេចក្តីសម្រេចស្តីពីការអាជីវកម្មខ្សាច់ ទុកជាមោឃៈ ប្រការណាមួយផ្ទុយនឹងសេចក្តីសម្រេចដូចជា ប្រការទាំងឡាយដែលមាននៅក្នុងច្បាប់ស្តីពីការ រុករករ៉ែ និងបរិស្ថាន ។[137][xxiii] ចុងបញ្ចប់ សេចក្តីសម្រេចក៏បង្កើតបំរាមរបស់នាយករដ្ឋមន្ត្រីមួយលើសកម្មភាពជាក់លាក់មួយ ។ នេះគឺជាការចេញ ដំណើរដែលអាចមានពីគោលការណ៍នៃការបែងចែកអំណាច ហើយបំរាមនេះ គួរតម្រូវឱ្យមានយ៉ាងហោចណាស់អនុក្រិត្យមួយ (ស្ថិតក្រោមការ ពិនិត្យមើលពីសភាជាតិ) ។ ទោះយ៉ាងណា សេចក្តីសម្រេចនេះអាចត្រូវបានចេញជាបណ្តោះអាសន្ន រហូតទាល់តែមានបញ្ញត្តិនៃច្បាប់ត្រឹមត្រូវ ត្រូវបានអនុម័ត ឬធ្វើវិសោធនកម្ម ។ វាហាក់បីដូចជាមិនមានបញ្ញត្តិនៃច្បាប់បន្ថែមទៀត នឹងកើតមានឡើងឡើយ ។

*សេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់នេះ ត្រូវបានប្រកាសជា "ការបញ្ចប់ប្រតិបត្តិការបូមខ្សាច់ រហូតទាល់តែការវាយតម្លៃបរិស្ថានទូទាំងឧស្សាហកម្ម និងការពិនិត្យ ដំណើរការផ្តល់អាជ្ញាប័ណ្ណឡើងវិញ អាចបំពេញរួចសព្វគ្រប់" ។*

xxii សំណៅភាសាអង់គ្លេសនៃសេចក្តីសម្រេច ហៅអង្គភាពដែលបានបង្កើតនេះថា "គណៈកម្មការ" តែដោយសារពាក្យដែលបានប្រើប្រាស់នៅក្នុងអាជ្ញាប័ណ្ណជាភាសាអង់គ្លេសដែលបានពិនិត្យ ដោយគ្លូបលវីតណេសគឺ "គណៈកម្មាធិការ" ហេតុនេះ-ពាក្យថា គណៈកម្មាធិការ ត្រូវបានប្រើប្រាស់ទាំងស្រុងក្នុងឯកសារនេះ ។

xxiii ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (2001) និងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (1996) ។

## ការអនុវត្តប្រសើរបំផុតផ្នែកបរិស្ថាន និងសង្គមជាអន្តរជាតិសំរាប់ការបូមខ្សាច់

ផលប៉ះពាល់ដែលការបូមខ្សាច់ត្រូវបានចោទប្រកាន់ថាមានទៅលើបណ្តាសហគមន៍នេសាទ និងលំនៅងាយរងផលប៉ះពាល់ក្នុងតំបន់នៅក្នុងប្រទេស កម្ពុជា មិនមែនមានតែមួយនោះទេ។ ផលប៉ះពាល់ខូចខាតដែលការបូមខ្សាច់អាចមានលើប្រព័ន្ធអេកូឡូហ្ស៊ីដែលងាយរងផលប៉ះពាល់ ពូជត្រី និងជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋានដែលផ្អែកលើពួកវា ត្រូវបានទទួលស្គាល់ជាយូរមកហើយ។[138] បញ្ហានេះបណ្តាលយ៉ាងខ្លាំងមកពីការធ្លាក់ចុះ គុណភាពទឹក ឧទាហរណ៍ តាមរយៈភាពល្អក់ តែការបូមខ្សាច់ក្បែរឆ្នេរសមុទ្រក៏ផ្លាស់ប្តូរដល់ដំណើរការជលសាស្ត្រផងដែរ។[139] ទាំងនេះរួមមាន ការបង្អាក់ដល់របបកំទេចកំទីធម្មជាតិដូចជា ការបង្កើនសំណឹកច្រាំងក្នុងតំបន់ដែលបានបូម ការកើនឡើងកម្រិតទឹកសមុទ្រនៅក្នុងមាត់សមុទ្រ និង កំណើនជាតិប្រៃនៅទូទាំងប្រព័ន្ធដីសណ្តរ ព្រមទាំងការកើនឡើងគ្រោះថ្នាក់ពីទឹកជំនន់ផងដែរ។[140]

ក្នុងការទទួលស្គាល់គ្រោះថ្នាក់ទាំងនេះ បទដ្ឋានជាច្រើនត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល សមាគមឧស្សាហកម្មបូមខ្សាច់អន្តរជាតិ[xxiv] និងគណៈគ្រប់គ្រង។ ប្រទេសហូឡង់ អនុញ្ញាតឱ្យមានការបូមខ្សាច់តែក្នុងទឹកជម្រៅជ្រៅជាង 20m តែប៉ុណ្ណោះ រីឯប្រទេសអ៊ីតាលី អនុញ្ញាតឱ្យមានការបូមខ្សាច់តែក្នុងទឹកជម្រៅជ្រៅជាង 50m តែប៉ុណ្ណោះ ហើយឆ្ងាយជាង 3 ម៉ាយល៍ពីឆ្នេរសមុទ្រ។[141] សេចក្តីណែនាំពីការអនុវត្តប្រសើរបំផុតផ្នែកបរិស្ថាន ត្រូវបានបង្កើតឡើងដោយឧស្សាហកម្មបូមខ្សាច់ ដើម្បីសម្រាលផលប៉ះពាល់លើលំនៅដែលងាយរងផលប៉ះពាល់ផ្នែកបរិស្ថាន ហើយអាចត្រូវបានសង្ខេបដូចខាងក្រោម ៖

### 1) ដំណាក់កាលរៀបចំ

- ការបង្កើតគម្រោង ចាប់ផ្តើមនៅរយៈពេលវាយតម្លៃយ៉ាងតិចបំផុត 18 ខែ ដើម្បីវាយតម្លៃរាល់ជម្រើសទាំងអស់ បញ្ហាដែលអាចមានយុទ្ធសាស្ត្រសម្រាល និងប្រឹក្សាជាមួយភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសបណ្តាសហគមន៍ក្នុងតំបន់។[142] កន្លែងណាដែលមានកម្រិតព័តិមាន មូលដ្ឋាននោះគោលការណ៍ប្រុងប្រយ័ត្នជាមុន ត្រូវតែទទួលបាននូវការទទួលយកជា "ការអនុវត្តការគ្រប់គ្រងប្រសើរបំផុត" ហើយការវាយតម្លៃអាចពឹងផ្អែកកាន់តែខ្លាំងលើចំណេះដឹងក្នុងតំបន់។ [143]

### 2) អំឡុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន

- ធ្វើ EIA ពេញលេញ មុនពេលចាប់ផ្តើម ដើម្បីកំណត់រកផលប៉ះពាល់ វាយតម្លៃជម្រើស និងរៀបចំវិធានការណ៍សម្រាល។ ការអនុវត្តប្រសើរបំផុតរួមមាន ការគ្រប់គ្រងភាគីពាក់ព័ន្ធឱ្យពេញលេញនៅទូទាំងដំណើរការ EIA ។[144]

- ចៀសវាងការបូមខ្សាច់ក្នុង និងជុំវិញតំបន់ឆ្នេរសមុទ្ររាក់ៗ ឬប្រព័ន្ធអេកូឡូហ្ស៊ីប្រណិតៗ (ឧទាហរណ៍ ផ្កាថ្មប៉ប្រះទឹក ជ្រលងស្មៅសមុទ្រ និងព្រៃកោងកាង)។[145] វិសាលភាពនៃផលប៉ះពាល់ផ្អែកលើកត្តាជាច្រើន ហើយត្រូវបានកត់ត្រាទុកថាមានចម្ងាយ 70km ពីកន្លែង ប្រតិបត្តិការ។[146] តំបន់ទ្រនាប់ដែលគ្មានការបូមខ្សាច់ អាចសម្រាលគ្រោះថ្នាក់បាន។[147]

### 3) ការបង្កើតផែនការគ្រប់គ្រង និងត្រួតពិនិត្យ

- បង្កើតផែនការគ្រប់គ្រងបរិស្ថាន ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងផលប៉ះពាល់ យោងតាមវិធានការណ៍សម្រាល និងផែនការផ្តល់សំណងនៅពេលចាំបាច់។[148]

- វិធានការណ៍សម្រាលដែលបានស្នើឡើង គឺជាការបិទបាំងល្បាប់ភក់ ការកម្រិតផលិតកម្ម ការរឹតបន្តឹងការហៀរចេញខ្សាច់ និងកំទេចកំទីពីម៉ាស៊ីនបូម និងការកំណត់ពេលវេលាប្រតិបត្តិបូមខ្សាច់តាមរដូវ/ងាយរងផលប៉ះពាល់បរិស្ថាន។ [149]

គ្លូបលវីតណេសមិនអាចស្វែងរកពីការវាយតម្លៃណាមួយលើផលប៉ះពាល់នៃការបូមខ្សាច់តាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជាបានទេ ហេតុនេះវានៅតែត្រូវបានមើលឃើញដដែល ប្រសិនបើបទពិសោធន៍នៃប្រព័ន្ធអេកូឡូហ្ស៊ីដែលងាយរងផលប៉ះពាល់ផ្សេងទៀត នឹងត្រូវបានធ្វើឡើងដដែលៗនៅក្នុងខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត។ ទោះយ៉ាងណា នៅពេលដែលត្រូវបានប្រៀបធៀបទៅនឹងសេចក្តីណែនាំទាំងនេះ ប្រតិបត្តិការបូមខ្សាច់នៅក្នុងប្រទេសកម្ពុជា ហាក់បីដូចជាមិនស្របគ្នាទាល់តែសោះ។ ការបូមខ្សាច់កំពុងកើតឡើងនៅក្នុងទឹករាក់ខ្លាំង ដែលមួយចំនួននៅក្នុងតំបន់ការពារទៀតផង។ EIAs និងផែនការគ្រប់គ្រងបរិស្ថាន ហាក់បីដូចជាមិនត្រូវបានធ្វើ ហើយតំណាងនៃភ្នាក់ងារគ្រប់គ្រងរបស់ប្រទេសកម្ពុជា មិនបានដឹងពីកម្រិតនៃផលប៉ះពាល់ដែលអាចមានចម្ងាយ 70km ពីប្រតិបត្តិការបូមខ្សាច់ទេ។

xxiv មានសមាគម International Association of Dredging Companies (IADC) សមាគម World Association for Waterborne Transport Infrastructure, Central Dredging Association (CEDA) និង World Association for Waterborne Transport Infrastructure (PIANC) ។

នៅពេលដែលត្រូវបានបង្ហាញនូវករណីនេះ អ្នកជំនាញផ្នែកបូមខ្សាច់ជាអន្តរជាតិ Tim Deere-Jones ដែលមានមូលដ្ឋាននៅប្រទេសអង់គ្លេសបាន និយាយថា *"ពាក់ព័ន្ធនឹងភស្តុតាងដែលបានបង្ហាញដោយរបាយការណ៍នេះ វាហាក់បីដូចជាច្បាស់ថា ការខូចខាតធ្ងន់ធ្ងរ និងជាប់ជានិច្ច នឹងមានទៅលើ លំនៅ និងអេកូឡូហ្ស៊ីនៃស្មៅសមុទ្រ ផ្កាថ្ម និងកោងកាងតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា"។ កម្មវិធីបូមខ្សាច់ដ៏ធំនេះ ត្រូវបានធ្វើឡើងដោយគ្មាន អត្ថប្រយោជន៍នៃ EIAs ហើយបញ្ញត្តិនៃច្បាប់ជាក់លាក់ដែលបានអនុវត្តដើម្បីទទួលស្គាល់បទដ្ឋានជាអន្តរជាតិ បង្ហាញមិនបានល្អទាល់តែសោះពី ក្រុមហ៊ុនបូមខ្សាច់ រដ្ឋាភិបាលប្រទេសកម្ពុជា និងអតិថិជនចុងក្រោយនៃខ្សាច់របស់ប្រទេសកម្ពុជា"* ។[150]

វាគឺជាការបារម្ភពិសេស ដែលរដ្ឋាភិបាលប្រទេសកម្ពុជា កំពុងអនុញ្ញាតឱ្យមានការបូមខ្សាច់ ដើម្បីបន្តទទួលបានភាពកម្រនៃព័ត៌មានស្តីពីស្ថានភាពរបស់លំនៅក្នុងសមុទ្ររបស់ប្រទេសកម្ពុជា។[151] វាគឺជាការបារម្ភដូចគ្នា ដែលបណ្តាក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរី កំពុងបន្តរកប្រភពធនធានខ្សាច់ ដែលបូមចេញស្ថិតក្រោមលក្ខខណ្ឌទាំងនេះ។
ដោយមិនមានការអង្កេតស្រាវជ្រាវមូលដ្ឋាន យើងមិនអាចយល់បានពីនិន្នាការកាលពីមុន ឬនាពេល បច្ចុប្បន្ន ឬការប៉ាន់ស្មានពីលទ្ធផលនៃប្រតិបត្តិការបូមខ្សាច់ឡើយ។ ហេតុនេះ វាហាក់បីដូចជាថា ការបូមខ្សាច់នៅតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា នឹងបានចាប់ផ្តើមដោយមិនមានការយល់ដឹងបានគ្រប់គ្រាន់ពីផលប៉ះពាល់ និងដោយមិនមានយុទ្ធសាស្ត្រសម្រាលផលប៉ះពាល់។ ទោះបីជាការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូហ្ស៊ីសមុទ្រ គឺជាជម្រើសមួយក៏ដោយ ក៏ជាញឹកញាប់វាមិនទទួលបានជោគជ័យ ចំណាយច្រើនជាងការថែរក្សាមុខងាររបស់ប្រព័ន្ធអេកូឡូហ្ស៊ីដើម ហើយមិនអាចធ្វើបានដោយគ្មានចំណេះដឹងមូលដ្ឋានទូលំទូលាយអំពីការផ្លាស់ប្តូរជាប់ជានិច្ច មុខងារដ៏ច្រើន និងការទំនាក់ទំនងគ្នាទៅវិញទៅមកនៃប្រព័ន្ធអេកូឡូហ្ស៊ីដែលមានបញ្ហាឡើយ។[152]
ការសិក្សាពីទីតាំងនៅអឺរ៉ុបដែលការបូមខ្សាច់បានកំពុងកើតឡើងចាប់តាំងពីដើមទសវត្សឆ្នាំ 1980 *បានកត់ត្រាពីភាពមុនក្រោយគ្នារយៈពេល 2-3 ឆ្នាំរវាងផលប៉ះពាល់ និងឥទ្ធិពលនៃការបូមខ្សាច់ ហេតុនេះគ្លូបលវីតណេសមានចម្ងល់ថាតើមូលដ្ឋានអ្វីដែលរដ្ឋាភិបាលប្រទេសកម្ពុជាអាចបញ្ជាក់ថា ការបូមខ្សាច់នឹងមិនមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូហ្ស៊ីក្នុងតំបន់*។[153]

*"...វាហាក់បីដូចជាច្បាស់ថា ការខូចខាតធ្ងន់ធ្ងរ និងជាប់ជានិច្ច នឹងមានទៅលើលំនៅ និងអេកូឡូហ្ស៊ីនៃស្មៅសមុទ្រ ផ្កាថ្ម និងកោងកាងតាមឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជា"*។

ការនាំខ្សាច់ខ្សាច់បូមជាអន្តរជាតិ Tim Deere-Jones នៅក្នុងឆ្នាំ 2010 នៅពេលបានធ្វើបទបង្ហាញករណីនេះ

គ្មានក្រុមហ៊ុនដែលសកម្មនៅក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជា ត្រូវបានរាយឈ្មោះជាសមាជិកសមាគមក្រុមហ៊ុនបូមខ្សាច់អន្តរជាតិទេ។ ក្រុមហ៊ុនបួនមានមូលដ្ឋាននៅប្រទេសសិង្ហបុរី ស្ថិតនៅលើបញ្ជីសមាជិកភាព តែគ្លូបលវីតណេសមិនដឹងថាតើ ពួកគេចូលរួមក្នុងប្រតិបត្តិការពាក់ព័ន្ធនឹងប្រទេសកម្ពុជាដែរឬអត់។[154] ការបង្ហាញនូវឥរិយាបថរបស់ក្រុមហ៊ុន ស្តែងតាមការសំភាសន៍ជាមួយតំណាងក្រុមហ៊ុននៅក្នុងខែ ឧសភា ឆ្នាំ 2009 ដែលក្នុង នោះគាត់បានសារភាពថា ពួកគេមិនបានធ្វើការអង្កេតស្រាវជ្រាវមុនការចាប់ផ្តើម ហើយមិនមានទស្សនៈណាមួយអំពីបរិមាណខ្សាច់ ដែលពួកគេកំពុង បូមឡើយ *"ប្រសិនបើនេះគឺជាគម្រោងរបស់ប្រទេសអាមេរិក នោះវានឹងមិនដំណើរការបែបនេះទេ"*។[155] គ្លូបលវីតណេសបានសរសេរលិខិតទៅកាន់ បណ្តាក្រុមហ៊ុនដែលមានឈ្មោះក្នុងរបាយការណ៍នេះ ដើម្បីសួរពួកគេអំពីការអនុវត្តបទដ្ឋានប្រសើរបំផុតជាអន្តរជាតិរបស់ពួកគេ។ មកទល់ពេលនៃ ការបោះពុម្ពផ្សាយ មានតែក្រុមហ៊ុន Mong Reththy Group បានឆ្លើយតបដូចបានរៀបរាប់លើទំព័រ 13។

*"...ប្រសិនបើនេះគឺជាគម្រោងរបស់ប្រទេសអាមេរិក នោះវានឹងមិនដំណើរការបែបនេះទេ"*។

តំណាងរបស់ក្រុមហ៊ុនម្នាក់ នៅពេលដែលត្រូវបានសំភាសន៍ដោយសារព័ត៌មានអំពីប្រតិបត្តិការបូមខ្សាច់នៅក្នុងប្រទេសកម្ពុជានៅខែ ឧសភា ឆ្នាំ 2009



គ្លូបលវីតណេស

នាវារបស់ក្រុមហ៊ុន L.Y.P. Group ដែលផ្ទុកខ្សាច់នៅលើនាវាធំពីរ ត្រូវបានថតកំពុងបូមខ្សាច់នៅទន្លេកោះពោធិ នៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ខេត្តកោះកុង ប្រទេសកម្ពុជា។ ក្រុមហ៊ុន L.Y.P. Group ដែលគ្រប់គ្រងដោយព្រឹទ្ធសមាជិក លី យ៉ុង ផាត់ ត្រូវបានស្គាល់ដោយគ្លូបលវីតណេសថាជា ក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនពីរដែលគ្រប់គ្រងវិស័យខ្សាច់របស់ខេត្តកោះកុង។

# 5. តួនាទីប្រទេសសិង្ហបុរី

## អ្នកនាំចូលខ្សាច់របស់ប្រទេសកម្ពុជា

ការសាងសង់ពង្រីករបស់ប្រទេសសិង្ហបុរី និងកម្មវិធីរុករានដីតម្រូវឱ្យប្រទេសនេះយកប្រភពធនធានខ្សាច់ពីក្រៅព្រំដែនប្រទេសរបស់ខ្លួន។ ហេតុនេះ នៅក្នុង ឆ្នាំ 2008 វាគឺជាអ្នកនាំចូលខ្សាច់ដ៏ធំបំផុតរបស់ពិភពលោក។ បន្ទាប់ពីការកម្រិតត្រូវបានដាក់លើការនាំចេញខ្សាច់ដោយប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី និងប្រទេសវៀតណាម ឥឡូវនេះប្រទេសសិង្ហបុរីយកប្រភពធនធានពីប្រទេសកម្ពុជាវិញ។ ស្របពេលនេះដែរ ប្រទេសនេះបាន កំណត់តួនាទីខ្លួនឯងជាអ្នកនាំមុខក្នុងតំបន់សំរាប់ចេរភាពបរិស្ថាន។



គ្លូបលវីតណេស

ពិពណ៌អំពីប្រវត្តិសាស្ត្រ និងផែនការនាពេលអនាគតសំរាប់ការអភិវឌ្ឍន៍ទីក្រុងរបស់ប្រទេសសិង្ហបុរី នៅការិយាល័យរបស់អាជ្ញាធរអភិវឌ្ឍន៍ទីក្រុងឡើងវិញ ប្រទេសសិង្ហបុរី ខែ វិច្ឆិកា ឆ្នាំ 2009

រដ្ឋាភិបាលប្រទេសសិង្ហបុរីបានប្រាប់គ្លូបលវីតណេសថា *"ការនាំចូលខ្សាច់មកកាន់ប្រទេសសិង្ហបុរី ត្រូវបានធ្វើឡើងលើមូលដ្ឋានពាណិជ្ជកម្ម។ រដ្ឋាភិបាលប្រទេសសិង្ហបុរីមិនមែនជាភាគីមួយនៃកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយសំរាប់ការនាំចូលខ្សាច់ឡើយ"*។[156] ទោះយ៉ាងណា គ្លូបលវីតណេសបានរកឃើញភស្តុតាងថា ក្រុមប្រឹក្សាគ្រប់គ្រងស្ថិតក្រោមបណ្តាក្រសួងរបស់រដ្ឋាភិបាលប្រទេសសិង្ហបុរី កំពុងធ្វើលទ្ធកម្មខ្សាច់ ដែល ត្រូវបានចោទប្រកាន់ថាមកពីប្រទេសកម្ពុជា។ ស្នាមបរិស្ថាននៃការប្រើប្រាស់នេះ អាចមានច្រើនក្រាស់ក្រៃល។ រដ្ឋាភិបាលតម្រូវឱ្យក្រុមហ៊ុនដែល ប្រតិបត្តិការនៅក្រៅប្រទេស អនុវត្តតាមច្បាប់របស់ប្រទេសប្រភពដើម ហើយបញ្ញត្តិនៃច្បាប់នាំចូលខ្សាច់មួយចំនួនតម្រូវឱ្យមានកិច្ចសន្យាសម្បទានរុករករ៉ែ និងការវាយតម្លៃបរិស្ថាន។ ការទិញខ្សាច់ជាបន្តបន្ទាប់របស់ប្រទេសសិង្ហបុរីពីប្រទេសកម្ពុជាលើកឡើងនូវបញ្ហាជាច្រើនអំពីវិសាលភាព ដែលភ្នាក់ងារគ្រប់គ្រងកំពុងធានាឱ្យបណ្តាក្រុមហ៊ុនអនុវត្តតាមតម្រូវការ ឬ បណ្តាកាតព្វកិច្ចជាអន្តរជាតិកាន់តែច្រើនឡើងៗដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសិង្ហបុរី។

គ្លូបលវីតណេសជឿជាក់ថា ភស្តុតាងដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្តល់ឱ្យប្រទេសសិង្ហបុរីនូវឱកាសស្វែងរក ជម្រើសយ៉ាងសកម្មជាមុន សំរាប់ការរកប្រភពធនធានវត្ថុធាតុដើមប្រកបដោយចេរភាពដូចជាខ្សាច់នេះ។

### កម្មវិធីសាងសង់ និងការរុករានដីរបស់ប្រទេសសិង្ហបុរី

ការប្រើប្រាស់ខ្សាច់របស់ប្រទេសសិង្ហបុរី ត្រឹមជំរុញដោយកម្មវិធីសាងសង់ និងការរុករានដីរបស់ខ្លួន។ រដ្ឋរបស់ទីក្រុងដែលមានប្រជាជន 4.9 លាន នាក់ បានពង្រីកពី 581.5km$^2$ នៅក្នុងទសវត្សឆ្នាំ 1960 ទៅកាន់ 710.2km$^2$ នៅក្នុងឆ្នាំ 2008 ដែលកើនចំនួន 22%។[157] រដ្ឋាភិបាលបាន ចាប់អារម្មណ៍ផ្តោតទៅលើការប្រើប្រាស់សំភារៈច្នៃប្រើប្រាស់ឡើងវិញក្នុងការសាងសង់ ក៏ដូចជាការបង្កើតបច្ចេកវិទ្យាសាងសង់ "លើ និងក្រោម" ដើម្បីបំពេញតាមតម្រូវការផងដែរ[158] ទោះយ៉ាងណា ត្រូវបានគ្រោងថានឹងកើនទំហំដីចំនួន 7% ស្មើនឹងទំហំសរុប 760km$^2$ ។[159]

ប្រទេសសិង្ហបុរីនាំចូលខ្សាច់ទន្លេសំរាប់សំណង់ និងខ្សាច់សមុទ្រសំរាប់ការរុករានដី។[160] បរិមាណចាំបាច់សំរាប់ការរុករានដី អាចច្រើនក្រាស់ក្រៃល ហើយ ផ្អែកលើភាពជាក់លាក់នៃតំបន់។ ក្រុមហ៊ុនបូមខ្សាច់មួយដែលបានចុះកិច្ចសន្យាពីមុនដោយរដ្ឋាភិបាលប្រទេសសិង្ហបុរី បានផ្តល់ជូនរវាង 74,000m$^3$ ទៅ 376,712m$^3$ សំរាប់ដីមួយហិកតាដែលបានរុករាន។[161] ការរុករានដី មិនត្រឹមតែបំពេញតម្រូវការរៀបចំផ្ទះសំបែងប៉ុណ្ណោះ តែថែមទាំងសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម និងពាណិជ្ជកម្មផងដែរ។ គំរោងទ្រង់ទ្រាយធំនាពេលបច្ចុប្បន្នរួមមានការអភិវឌ្ឍន៍កំពង់ផែ និងឧស្សាហកម្មប្រេងឥន្ធនៈ Marina Bay Sands (ដែលជាកាស៊ីណូ និងរម្មណីយដ្ឋានកំសាន្តរួមគ្នាមួយ គ្រប់គ្រងដោយក្រុមហ៊ុន Las Vegas Sands Corp) ហើយនិង វាលប្រណាំងសេះអចិន្ត្រៃយ៍លើកដំបូងរបស់ប្រទេសសិង្ហបុរី ដែលកំពុងសាងសង់នៅលើជ្រោយចាងគីខាងកើត។[162]


គ្លូបលវីតណេស

តំបន់ម៉ារីណាភាគខាងត្បូង ខែ វិច្ឆិកា ឆ្នាំ 2009 ប្រទេសសិង្ហបុរី។ ម៉ារីណាភាគខាងត្បូង ត្រូវបានសាងសង់ឡើងលើដីរុករាន កំពូលប៉មនៅខាងស្តាំ គឺជាផ្នែកនៃគំរោងរម្មណីយដ្ឋានរួមបញ្ចូលគ្នារបស់ខ្សាច់ជ្រោយម៉ារីណា ហើយតំបន់ដែលកំពុងត្រូវបានអភិវឌ្ឍន៍ទៅខាងឆ្វេង នឹងរួមមានមជ្ឈមណ្ឌលកំសាន្ត និងពាណិជ្ជកម្មផងដែរ។

### កន្លែងដែលប្រទេសសិង្ហបុរីស្រង់ប្រភពធនធានខ្សាច់របស់ខ្លួន

ដោយប្រើអស់ការផ្គត់ផ្គង់ខ្សាច់ផ្ទាល់របស់ខ្លួននៅក្នុងទសវត្សឆ្នាំ 1960 ប្រទេសសិង្ហបុរីត្រូវតែស្វែងរកកន្លែងផ្សេងដើម្បីបំពេញតម្រូវការសាងសង់ និងរុករានដី។ តម្រូវការខ្សាច់របស់ប្រទេសសិង្ហបុរីគឺថា នៅក្នុងឆ្នាំ 2008 ប្រទេសនេះគឺជាអ្នកនាំចូលធំបំផុតក្នុងពិភពលោក ដែលមានចំនួន 14.2 លានតោន ក្នុងតម្លៃ 273 លានដុល្លារអាមេរិក ដែលលោតផ្លោHBI 3.8 លានតោននៅក្នុងឆ្នាំ 2007 ។[163] ក្នុងចំនួនសរុបនៃឆ្នាំនេះ ប្រទេសកម្ពុជាគឺជាប្រភពខ្សាច់ធំបំផុតទីបីរបស់ប្រទេសសិង្ហបុរី (ដែលផ្តល់ចំនួន 3.8 លានតោន ឬ 21.5%) បន្ទាប់ពីប្រទេសវៀតណាមចំនួន 45% និងប្រទេស ម៉ាឡេស៊ីចំនួន 22% ។[164] [xxv]




ទោះយ៉ាងណាក៏ដោយ តម្រូវការខ្សាច់របស់ប្រទេសជិតខាងរបស់ខ្លួនដ៏ខ្ពស់នេះ បានបង្ហាញនូវប្រការគួរឱ្យសង្ស័យ ។ ប្រទេសម៉ាឡេស៊ី បានហាមការនាំចេញខ្សាច់ទៅកាន់ប្រទេសសិង្ហបុរីនៅក្នុងឆ្នាំ 1997 ។ ទោះយ៉ាងណានាពេលថ្មីៗនេះ ការនាំចេញមានកម្រិតត្រូវបានអនុញ្ញាតឱ្យ ។[165] ចាប់តាំងពីពេលនោះរហូតដល់ខែ មករា ឆ្នាំ 2007 ប្រទេសឥណ្ឌូនេស៊ី គឺជាអ្នកផ្គត់ផ្គង់ខ្សាច់ធំរបស់ប្រទេសសិង្ហបុរី ទោះយ៉ាងណានៅក្នុងខែនោះ រដ្ឋាភិបាលប្រទេសឥណ្ឌូនេស៊ីក៏បានដាក់បំរាមទាំងស្រុងលើរាល់ការនាំចេញខ្សាច់ទាំងអស់ផងដែរ ។[166] បំរាមនេះ ត្រូវបានជំរុញមួយផ្នែកដោយការខូចខាតយ៉ាងធ្ងន់ធ្ងរដែលវិស័យខ្សាច់បានបង្កើតលើតំបន់ឆ្នេរសមុទ្ររបស់ប្រទេសឥណ្ឌូនេស៊ី ។ នៅក្នុងកោះ Riau ក្បែរប្រទេសសិង្ហបុរី ខ្សាច់ច្រើន រហូតដល់ 250,000 ទៅ 300,000 កំពុងត្រូវបាននាំចេញជារៀងរាល់ខែ ។ កោះមួយចំនួនបានបាត់រូបរាង ហើយកោះផ្សេងទៀតខូចខាតយ៉ាង ធ្ងន់ធ្ងរ ។[167]

បន្ទាប់ពីបំរាមរបស់ប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរីបានរំកិលរុករកខ្សាច់មកកាន់ប្រទេសវៀតណាម និងប្រទេសកម្ពុជា ។ នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ 2008 រដ្ឋាភិបាលប្រទេសវៀតណាមបានដាក់ការកម្រិតលើការនាំចេញខ្សាច់ ។ នេះគឺដើម្បីធានាឱ្យបានការផ្គត់ផ្គង់ក្នុងស្រុក កម្រិតការខូចខាត បរិស្ថាន និង និងដោះស្រាយការចោទប្រកាន់នៃ "សកម្មភាពដ៏គួរឱ្យសង្ស័យ" នេះនៅក្នុងឧស្សាហកម្ម ។[168] នៅថ្ងៃទី 8 ខែ ឧសភា ឆ្នាំ 2009 រដ្ឋាភិបាលប្រទេសកម្ពុជាបានចេញសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ ដើម្បីហាមការនាំចេញខ្សាច់ទន្លេ និងកម្រិតការនាំចេញខ្សាច់សមុទ្រ ដូចបានរៀបរាប់ខាងលើ ។[169] ជាងនេះទៀត នៅថ្ងៃទី 16 ខែ វិច្ឆិកា ឆ្នាំ 2009 ប្រទេសវៀតណាមបានចេញបំរាមទាំងស្រុងលើរាល់ការនាំចេញខ្សាច់សមុទ្រចាប់ពីខែ មិថុនា ឆ្នាំ 2010 តទៅ ។[170] ចាប់តាំងពីដើមឆ្នាំ 2010 ការរុករកត្រូវបានរាយការណ៍ថាបានពង្រីកដល់ប្រទេសភូមា ប្រទេសហ្វីលីពីន និងប្រទេសបង់ក្លាដេស ហើយប្រព័ន្ធផ្សព្វផ្សាយបានចោទប្រកាន់ក្រុមហ៊ុនដែលនាំចូលខ្សាច់ទៅកាន់ប្រទេសិង្ហបុរីថាជា "ការលួច ឆ្នេរសមុទ្រ" ពីប្រទេសឥណ្ឌូនេស៊ី និងប្រទេសម៉ាឡេស៊ី ។[171]

ទោះបីជាតួលេខការនាំចេញខ្សាច់សរុបពីប្រទេសកម្ពុជា មិនអាចទទួលបានជាសាធារណៈក៏ដោយ នៅក្នុងអាស៊ីអគ្នេយ៍ទាំងមូល មានតែប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសសិង្ហបុរីបានរាយការណ៍ពីការនាំចូលខ្សាច់ពីប្រទេសកម្ពុជា ។ ប្រទេសសិង្ហបុរីគ្របដណ្តប់ពាណិជ្ជកម្មនេះទំហំល្មម ។[172] ប្រទេសចិនមិនបានរាយការណ៍ពីការនាំចូលខ្សាច់ណាមួយពីប្រទេសកម្ពុជាទៅកាន់ UN Comtrade ទេ ចាប់ តាំងពីឆ្នាំ 1992 ទោះបីជាមានការរកប្រភពធនធានវត្ថុធាតុដើមនេះពីជុំវិញពិភពលោកក៏ដោយ ។[173] ស្របពេលនេះដែរ យោងតាមស្ថិតិរបស់ UN Comtrade បានឱ្យដឹងថា ប្រទេស សិង្ហបុរីពិតជានាំចេញខ្សាច់ប្រចាំឆ្នាំមែន តែត្រឹមចំនួនតិចតួចប៉ុណ្ណោះ នៅក្នុងឆ្នាំ 2008 វាបាននាំចេញ 5,600 តោន ។[174]

នៅពេលដែលគ្លូបលវីតណេសបានជួបប្រជុំជាមួយតំណាងរបស់រដ្ឋាភិបាលប្រទេសសិង្ហបុរីនៅក្នុងឆ្នាំ 2009 ពួកគេបានបង្ហាញទស្សនៈថា ប្រទេស សិង្ហបុរីមិនមែនជាអ្នកនាំចូលសំខាន់មួយឡើយ ប្រៀបជាមួយនឹងបណ្តាប្រទេសផ្សេងទៀតនៅក្នុងតំបន់ (ឧទាហរណ៍ ប្រទេសចិន) ។ នៅឯកិច្ចប្រជុំ នោះ គ្លូបលវីតណេសបានស្នើសុំស្ថិតិ ការនាំចូលខ្សាច់របស់ប្រទេសសិង្ហបុរី ដើម្បីបញ្ជាក់ពីបញ្ហានេះពីពួកគេ អកុសលមកទល់ពេលបោះពុម្ពផ្សាយនេះ មិនមានព័ត៌មានណាមួយត្រូវបានទទួលនៅឡើយ ។ ទោះយ៉ាងណា ផ្អែកតាមតួលេខពាណិជ្ជកម្មដែលអាចទទួលបានជាសាធារណៈដែលបានបង្ហាញខាងលើ គ្លូបលវីតណេសជឿជាក់ថា ការពិតណាស់ប្រទេសសិង្ហបុរី គឺជាអ្នកនាំចូលខ្សាច់ដ៏សំខាន់បំផុតពីប្រទេសកម្ពុជា ហើយហេតុនេះមានឱកាសកំណត់គោលនយោបាយដែលអាច កែលំអបានច្រើននូវអភិបាលកិច្ចនៃវត្ថុធាតុដើមនេះ ។

## តួនាទីរបស់រដ្ឋាភិបាលប្រទេសសិង្ហបុរីនៅក្នុងការនាំចូលខ្សាច់របស់ប្រទេស

ពេលដែលវាជាក់ច្បាស់ថា ប្រទេសសិង្ហបុរីគឺជាអ្នកនាំចូលខ្សាច់របស់ប្រទេសកម្ពុជា តួនាទីជាក់លាក់របស់រដ្ឋាភិបាលប្រទេសសិង្ហបុរីនៅក្នុងការនាំចូល ខ្សាច់

xxv អ្នកអាននឹងបានសំគាល់ឃើញពីភាពខុសគ្នារវាងតួលេខពីឆ្នាំ 2008 និងតម្លៃប៉ាន់ស្មានការនាំចេញខ្សាច់ពីខេត្តកោះកុងទៅកាន់ប្រទេសសិង្ហបុរីសំរាប់ឆ្នាំ 2009 ដូចបានជម្រាបជូននៅទំព័រ 16 ។ ការប៉ាន់ស្មាន ដោយគ្លូបលវីតណេស ផ្អែកទៅលើព័ត៌មានដែលអាចមានប្រសើរបំផុត ។ គ្លូបលវីតណេស សូមស្វាគមន៍រាល់ការបញ្ជាក់ពីរដ្ឋាភិបាលប្រទេសកម្ពុជា និងប្រទេសសិង្ហបុរីលើ ស្ថិតិពាណិជ្ជកម្ម ពិតប្រាកដ ។



HOUSING & DEVELOPMENT BOARD

SPECIFICATIONS

SUPPLY OF CONCRETING SAND TO THE HDB

SECTION 2 : SUPPLEMENTARY SPECIFICATIONS

2.7.1 Source

The Contractor shall be required to supply the Concreting Sand from approved sources. In this respect, the Contractor shall provide and submit together with his Tender Proposal, all necessary information and documentary evidence to the satisfaction of the SO Rep that he is able to comply with the quality and quantity requirements as specified. The documents shall include but not limit to the follow:

a) location maps of the source country and region;
b) map and grid reference for the quarry;
c) concession for quarrying and Export Permit from the government of the source country; the reserve volume for quarrying as well as any environmental impact assessment or equivalent;
d) schematic diagrams and photographs showing the complete production processes of the Goods;
e) type, quantity and capacity of each production machinery or equipment;
f) in-house quality control plan;
g) all test reports as specified in Clause "Certificate Of Compliance In Tender Submission"; and
h) all other relevant information pertaining to the supply source.

ក្រុមប្រឹក្សាគ្រប់គ្រងផ្ទះសម្បែង និងអភិវឌ្ឍន៍របស់រដ្ឋាភិបាលប្រទេសសិង្ហបុរី
យថាប្រភេទបន្ថែមសំរាប់ការផ្គត់ផ្គង់ខ្សាច់បូកទៅឱ្យក្រុមប្រឹក្សាគ្រប់គ្រងផ្ទះសម្បែង និងអភិវឌ្ឍន៍

*"ការនាំចូលខ្សាច់មកកាន់ ប្រទេសសិង្ហបុរី ត្រូវបានធ្វើឡើងលើមូលដ្ឋានពាណិជ្ជកម្ម ។ រដ្ឋាភិបាលប្រទេសសិង្ហបុរី មិនមែនជាភាគីមួយនៃកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយសំរាប់ការនាំចូលខ្សាច់ឡើយ" ។*

ការឆ្លើយតបជាលាយលក្ខណ៍អក្សរពីរដ្ឋាភិបាលប្រទេសសិង្ហបុរីនៅក្នុងខែ មេសា ឆ្នាំ 2010 ចំពោះបណ្តាសំណួរពីគ្លូបលវិតណេសអំពីតួនាទីរបស់រដ្ឋាភិបាលនៅក្នុងពាណិជ្ជកម្មខ្សាច់

មិនមានភាពច្បាស់លាស់ទេ ។ រដ្ឋាភិបាលបានប្រាប់គ្លូបលវិតណេសតាមអ៊ីម៉េលនៅក្នុងខែ មេសា ឆ្នាំ 2010 ថា *"ការនាំចូលខ្សាច់ទៅកាន់ ប្រទេសសិង្ហបុរី ត្រូវបានធ្វើឡើងផ្អែកតាមមូលដ្ឋានពាណិជ្ជកម្ម ។ រដ្ឋាភិបាលប្រទេសសិង្ហបុរី មិនមែនជាភាគីមួយនៃកិច្ចព្រមព្រៀង ឬកិច្ចសន្យាសំរាប់ ការនាំចូលខ្សាច់ណាមួយឡើយ"*[175] ទោះយ៉ាងណា គ្លូបលវិតណេសបានឃើញឯកសារបី សំណុំ ដែលបង្ហាញថារដ្ឋាភិបាលខ្លួនឯងទិញខ្សាច់ ។

ទីមួយ ក្នុងអំឡុងពេលពិភាក្សាក្នុងសភាពិតម្រូវការសំរាប់ រដ្ឋាភិបាលដើម្បីផ្គត់ផ្គង់សំភារៈសំណង់ ដើម្បីធ្វើឱ្យមានស្ថេរភាពទីផ្សារក្នុងស្រុក តំណាងរដ្ឋាភិបាលម្នាក់បានបញ្ជាក់ថា *"... ក្នុងឋានៈជាអ្នកអភិវឌ្ឍន៍ និងជាម្ចាស់គម្រោង រដ្ឋាភិបាលនឹងជួយអ្នកម៉ៅការដោយការរួមចំណែករហូតដល់ 75% នៃកំណើនតម្លៃខ្សាច់ និងក្រានីត"* ។[176]

ទីពីរ គេហទំព័ររដ្ឋាភិបាលប្រទេសសិង្ហបុរី បានរៀបរាប់លំអិតអំពីការស្នើសុំដែលចេញដោយក្រុមប្រឹក្សា រៀបចំផ្ទះសម្បែង និងអភិវឌ្ឍន៍ (ក្រុមប្រឹក្សា គ្រប់គ្រងរបស់រដ្ឋាភិបាលស្ថិតក្រោមក្រសួងអភិវឌ្ឍន៍ជាតិ[177]) សុំការផ្គត់ផ្គង់ខ្សាច់សំរាប់គម្រោងសាងសង់ ។[178] សំណើទាំងនេះបង្ហាញថា អ្នកម៉ៅការត្រូវតែចុះបញ្ជីដើម្បីផ្គត់ផ្គង់សំភារៈសំណង់មូលដ្ឋានជាមួយនឹង BCA និងផ្តល់ខ្សាច់ពី "ប្រភពដែលទទួលបានការអនុញ្ញាត" ។ ពួកគេត្រូវមានភស្តុតាងជាឯកសារពីអាជ្ញាប័ណ្ណសម្បទាន និងទីតាំងនៅក្នុងប្រទេសប្រភពដើម លិខិតអនុញ្ញាតនាំចេញ និងធ្វើការវាយតម្លៃផលប៉ះពាល់ បរិស្ថាន ។[179]

ទីបី គ្លូបលវិតណេសបានឃើញកិច្ចសន្យាមួយរវាង JTC និងក្រុមហ៊ុននាំចូលខ្សាច់ ដើម្បីទិញខ្សាច់ពីប្រទេសកម្ពុជា ស្របពេលនេះដែរ បណ្តាប្រភពឧស្សាហកម្មជាច្រើននៅក្នុងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជាបានអះអាងថា ខ្សាច់ដែលបាននាំចេញពីប្រទេសកម្ពុជា ត្រូវបានទិញដោយ JTC ។[180] នៅក្នុងអ៊ីម៉េលរបស់ខ្លួននៅខែ មេសា ឆ្នាំ 2010 រដ្ឋាភិបាលប្រទេសសិង្ហបុរីបានសរសេរថា *"រដ្ឋាភិបាលប្រទេសសិង្ហបុរី មិនមែនជាភាគីមួយនៃ កិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយ សំរាប់ការនាំចូលខ្សាច់ឡើយ ។ JTC ដែលជាក្រុមប្រឹក្សាគ្រប់គ្រងមួយស្ថិតក្រោមក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មនៃរដ្ឋាភិបាលប្រទេសសិង្ហបុរី ពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់ខ្សាច់ ដែលជាអង្គភាពឯកជន ទៅលើមូលដ្ឋានពាណិជ្ជកម្ម ដើម្បីផ្គត់ផ្គង់ខ្សាច់សំរាប់ការរុករានដី និងការងារអភិវឌ្ឍន៍ផ្សេងទៀត ។ អ្នកផ្គត់ផ្គង់ខ្សាច់ទាំងនេះ ទិញខ្សាច់ពីម្ចាស់សម្បទានខ្សាច់ក្នុងតំបន់នៅប្រទេសប្រភពដើមផ្សេងៗ ។ ម្ចាស់សម្បទានទាំងនេះ កំណត់ទីតាំងប្រភពធនធាន និងធ្វើការដកស្រង់ធនធាន"* ។[181] ការពិតគឺថា រដ្ឋាភិបាលបានបញ្ជាក់ថា ខ្លួនមិនមែនជាភាគីនៃ កិច្ចព្រមព្រៀងណាមួយសំរាប់ការនាំចូលខ្សាច់ ហើយនៅក្នុងប្រយោគបន្ទាប់និយាយថា JTC ចូលរួមក្នុងការផ្គត់ផ្គង់ខ្សាច់



*www.pbase.com/bmcnorrow*

កោះរីអូ ប្រទេសឥណ្ឌូនេស៊ី ។ ប្រទេសសិង្ហបុរីបាននាំចូលខ្សាច់រហូតដល់ 250,000 - 300,000 ក្នុងមួយខែពីកោះរីអូរបស់ប្រទេសឥណ្ឌូនេស៊ី រហូតដល់ឆ្នាំ 2007 នៅពេលដែលពាណិជ្ជកម្មនេះត្រូវបានបញ្ឈប់ មួយផ្នែកដោយសារការបារម្ភថាកោះជាច្រើននឹងបាត់រូបរាង

ហាក់បីដូចជាថារដ្ឋាភិបាល គិតថា ក្រុមប្រឹក្សាគ្រប់គ្រង គឺជាអង្គភាពផ្សេងពីរដ្ឋាភិបាល ។ ទោះយ៉ាងណា ដោយ JTC, BCA និងក្រុមប្រឹក្សាគ្រប់គ្រងផ្ទះសម្បែង និងអភិវឌ្ឍន៍ ស្ថិតនៅក្នុងចម្ងាយកៀកនឹងបណ្តាក្រសួងរដ្ឋាភិបាលជាលាក់ គ្លូបលវីតណេសជឿជាក់ថា រដ្ឋាភិបាលគួរតែមានការទទួលខុសត្រូវសំខាន់ៗចំពោះ សកម្មភាពរបស់ពួកគេ ។

ចុងក្រោយ អាជ្ញាប័ណ្ណធ្វើអាជីវកម្ម និងនាំចេញខ្សាច់របស់ប្រទេសកម្ពុជាពីរ មានហត្ថលេខា និងត្រារបស់តំណាងនៃស្ថានទូតប្រទេសសិង្ហបុរីប្រចាំ ប្រទេសកម្ពុជា ។ គ្លូបលវីតណេសមិនមានការយល់ដឹងច្បាស់លាស់ អំពីសារៈសំខាន់នៃត្រានេះ ដូចបានពិភាក្សាបន្ថែមទៀតនៅក្នុងទំព័រ 13 ខាងលើ ។

## ការប្តេជ្ញាចិត្តរបស់ប្រទេសសិង្ហបុរីចំពោះចីរភាព

ផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ចសង្គមអវិជ្ជមានដែលបណ្តាលឱ្យមានក្នុងតំបន់ដោយការនាំចូលខ្សាច់របស់ប្រទេសសិង្ហបុរី ហាក់បីដូចជាផ្ទុយ ទាំងស្រុងនឹងជំហររបស់ខ្លួន ក្នុងឋានៈជាអ្នកនាំមុខក្នុងតំបន់សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ប្លង់អភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសសិង្ហបុរី *"ប្រទេសសិង្ហបុរីរស់រវើក និងរស់រាន : យុទ្ធសាស្ត្រសំរាប់ការរីកចម្រើនប្រកបដោយចីរភាព"* បង្ហាញពីគោលដៅរបស់រដ្ឋាភិបាលក្នុងការផ្តល់ឱ្យនូវគំរូអភិវឌ្ឍន៍ការប្រើប្រាស់ធនធានប្រកបដោយចីរភាព នៅក្នុងព្រំដែនជាតិរបស់ខ្លួន និងឆ្លើយតបទៅនឹងការខ្វះខាតធនធានជាសកល ។[182] ការឧទ្ទេសនាមរបស់រដ្ឋាភិបាលទៅកាន់របាយការណ៍នេះបានឱ្យដឹងថា "យើងចង់អភិវឌ្ឍន៍ប្រទេសសិង្ហបុរីនៅក្នុងវិធីប្រកបដោយចីរភាពមួយ ហេតុនេះជំនាន់ក្រោយៗរបស់ប្រជាជនសិង្ហបុរី ក៏អាចរីករាយបានជាមួយនឹងទាំងការរីកចម្រើនសេដ្ឋកិច្ច និងបរិស្ថានរស់នៅល្អ ។ ប្រសិនបើយើងធ្វើឱ្យរដ្ឋទីក្រុងរបស់យើងរីកចម្រើននៅក្នុងវិធីប្រកបដោយប្រសិទ្ធិភាព ស្អាត និងពណ៌បៃតង ហើយប្រសិនបើយើងម្នាក់ៗមានការ យល់ដឹងពីបរិស្ថានកាន់តែច្រើននៅក្នុងវិធីដែលយើងរស់នៅ ធ្វើការ លេងកំសាន្ត និងទំនាក់ទំនង នោះយើងទាំងអស់នឹងរួមចំណែកជាផ្នែកមួយក្នុងការការពារបរិស្ថានជាសកល" ។[183]



ប្លង់អភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រដ្ឋាភិបាលប្រទេសសិង្ហបុរី ដែលបានធ្វើឡើងនៅក្នុងឆ្នាំ 2009 ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវចំរុះថ្នាក់ជាតិរបស់ប្រទេសសិង្ហបុរី ដែលត្រូវបានចាប់ដំណើរក្នុងឆ្នាំ 2009 ផងដែរ ណែនាំខ្លួនឯងថាជាផែនការមេដើម្បីជំរុញឱ្យមានការអភិរក្សជីវចំរុះ តាមរយៈ "គំរោងការណ៍ជាក់ស្តែង" និង "ដំណោះស្រាយតែមួយគត់" ដើម្បីបំពេញតាមការប្តេជ្ញាចិត្តថ្នាក់ តំបន់ និងជាអន្តរជាតិរបស់ប្រទេសសិង្ហបុរី ដែលជាចំបងគឺអនុសញ្ញាស្តីពីជីវចំរុះជីវសាស្ត្រ ។[184] នៅក្នុងខែ មិថុនា ឆ្នាំ 2010 នឹងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំបណ្តាទីក្រុងលើពិភពលោករៀងរាល់ពីរឆ្នាំ ដោយមានប្រធានបទ *"ទីក្រុងដ៏រស់រវើក និងប្រកបដោយចីរភាពសំរាប់អនាគត"* ដែលផ្តោតទៅលើភាពជាអ្នកនាំមុខ អភិបាលកិច្ច និងការបង្កើតឱ្យមានសហគមន៍ដ៏រស់រវើក និងប្រកបដោយចីរភាព ។[185] នៅពីក្រោយពីជាអ្នកនាំមុខផ្នែក បរិស្ថាន ប្រទេសសិង្ហបុរីដឹងពីការទទួលខុសត្រូវក្នុងការប្រើប្រាស់ចំណុចខ្លាំងក្នុងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនដើម្បីជួយប្រទេសផ្សេងទៀតនៅក្នុងតំបន់ ដូច ដែលរដ្ឋមន្ត្រីម្នាក់បាននិយាយអំឡុងកិច្ចពិភាក្សាសភាថា *"នោះតែងតែជាគំរោងការណ៍របស់យើង - ជួយអ្នកជិតខាង ដោយសារយើងជឿជាក់ថា ភាពរុងរឿងរបស់ពួកគេ គឺល្អសំរាប់យើងផងដែរ"* ។[186] នៅក្នុងអ៊ីម៉ែលរបស់ខ្លួននាខែ មេសា ឆ្នាំ 2010 រដ្ឋាភិបាលប្រទេសសិង្ហបុរីបានសរសេរថា

*"ប្រទេសសិង្ហបុរីប្តេជ្ញាចិត្តចំពោះការការពារបរិស្ថានជាសកល... ប្រទេសសិង្ហបុរីមានតួនាទីយ៉ាងសំខាន់លើបញ្ហាការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចជា សហប្រតិបត្តិការជាអន្តរជាតិនៅក្នុងការការពារជីវចំរុះក្នុងទីក្រុង និងដោះស្រាយចំពោះការរំខានធ្វើបាបឆ្លងព្រំដែនផងដែរ"* ។[187]

## តើការប្តេជ្ញាចិត្តចំពោះចីរភាពរបស់ប្រទេសសិង្ហបុរី ត្រូវបានធ្វើឱ្យអន្តរាយដែរឬទេ?

ទោះយ៉ាងណា ការពិនិត្យកាន់តែជិតដិតទៅលើគោលនយោបាយទាំងនេះ បង្ហាញពីភាពខុសគ្នាដ៏គួរឱ្យរំខានរវាងការឆ្លើយតបតាមចំណង់របស់ ប្រទេសសិង្ហបុរី ទៅនឹងការខ្វះខាតធនធានជាសកល និងឥទ្ធិភាពបញ្ញត្តិច្បាប់របស់ខ្លួន ។ មិនមានប្លង់អភិវឌ្ឍន៍ប្រកបដោយចីរភាព ឬយុទ្ធសាស្ត្រ និង ផែនការសកម្មភាពជីវចំរុះថ្នាក់ជាតិតម្រូវឱ្យមានការស៊ើបអង្កេតបរិស្ថាន ឬសង្គម នៅពេលរកប្រភពធនធានវត្ថុធាតុដើម (ដូចជាខ្សាច់) ឆ្ងាយពីព្រំដែនរបស់ប្រទេសសិង្ហបុរី ។ នៅក្នុងអ៊ីម៉ែលរបស់ខ្លួននាខែ មេសា ឆ្នាំ 2010 រដ្ឋាភិបាលបានសរសេរថា *"យើងតែងតែទទូចថា ការនាំចូលខ្សាច់ត្រូវតែអនុវត្តតាមច្បាប់ និងបទបញ្ញត្តិ ព្រមទាំងតម្រូវការពាក់ព័ន្ធ រួមទាំងបញ្ញត្តិនៃច្បាប់បរិស្ថានរបស់ប្រទេសប្រភពដើមផងដែរ"* ។[188] អ៊ីម៉ែលបានបន្តថា *"... គយរបស់យើងបានដាក់អនុវត្តនីតិវិធីពិនិត្យ និងស៊ើបអង្កេតការនាំចូលទំនិញនៅចំណុចឆែកឆេរ ។ យើងក៏តម្រូវឱ្យអ្នកផ្គត់ផ្គង់ខ្សាច់ចំពោះគម្រោងការរុករានដី ឱ្យបង្ហាញឯកសារផ្សេងៗ និងអាជ្ញាប័ណ្ណពីប្រទេសប្រភពដើម ហើយពួកគេនឹងត្រូវបានដោះស្រាយ ប្រសិនបើមាន ភាពមិនស្របគ្នា ឬភាពមិនធម្មតា"* ។ នេះបង្ហាញឱ្យឃើញតែបញ្ញត្តិនៃច្បាប់ដែលគ្លូបលវីតណេសអាចរកឃើញថាគ្រប់គ្រងការរកប្រភពធនធាន និង នាំចូលខ្សាច់តែប៉ុណ្ណោះ ។ បញ្ញត្តិនៃច្បាប់ស្តីពីការនាំចូល និងនាំចេញរបស់ប្រទេសសិង្ហបុរី (2003) ចែងថា *"ទំនិញទាំងឡាយស្ថិតក្រោមការ គ្រប់គ្រងលើការនាំចេញរបស់ប្រទេសនាំចេញ"* ។[189]

នៅក្នុងខែ មិនា ឆ្នាំ 2009 ដោយសារមានការអាក់ខានផ្គត់ផ្គង់សំភារៈសំណង់ពីប្រទេសឥណ្ឌូនេស៊ីនៅក្នុងឆ្នាំ 2007 វិសោធនកម្មមួយត្រូវបានអនុម័តឱ្យសេចក្តីព្រាងច្បាប់របស់អាជ្ញាធរសាងសង់ និងសំណង់ ដែលផ្តល់សិទ្ធិអំណាចច្បាប់ដល់ BCA ទៅលើអ្នកនាំចូលសំភារៈសំណង់ ។ ដោយស្ថិត ក្រោមគ្រោងការណ៍ផ្តល់អាជ្ញាប័ណ្ណនេះ អ្នកផ្គត់ផ្គង់ត្រូវតែបំពេញតាមបទដ្ឋានគុណភាពយ៉ាងមធ្យ័ត ដាក់ពាក្យសុំលិខិតអនុញ្ញាតនាំចូលសំរាប់ការ បញ្ជូននីមួយៗ



From: [redacted]
To: [redacted]
Cc: [redacted]
Subject: Reply to Global Witness on Letters

Follow Up Flag: Follow up

Dear Global Witness,

អ៊ីម៉ែលដែលបានទទួលដោយគ្លូបលវីតណេសពីក្រសួងអភិវឌ្ឍន៍ជាតិ រដ្ឋាភិបាលប្រទេសសិង្ហបុរី ថ្ងៃទី 22 ខែ មេសា ឆ្នាំ 2010 ។

និងអាចធ្វើឱ្យប្រាកដថាមាន "ភាពបត់បែនផ្នែកផ្គត់ផ្គង់តាមរយៈផែនការបន្តអាជីវកម្ម" ។[190] ចាប់តាំងពីមានវិសោធនកម្មនេះ BCA ដែលជាភ្នាក់ងារទទួលខុសត្រូវចំពោះការគ្រប់គ្រងបទដ្ឋាននាំចូលរួមផ្នែកសំណង់ បានកំណត់របបតេស្តិ៍បីដំណាក់កាលសំរាប់ការធានាគុណភាព ។[191] ក្នុងការរៀបចំតេស្តិ៍ដំបូង ក្រុមហ៊ុននាំចូលត្រូវផ្តល់លំអិតពីទីតាំងរុករករ៉ែ និងប្រតិបត្តិករ ។[192] ទោះយ៉ាងណា មិនដូចជាការស្នើសុំលទ្ធកម្មរបស់ក្រុមប្រឹក្សាគ្រប់គ្រងផ្ទះសំបែង និងអភិវឌ្ឍន៍ដែលបានរៀបរាប់ខាងលើទេ តម្រូវការតេស្តិ៍របស់ BCA មិនរំពឹងឱ្យបណ្តាក្រុមហ៊ុនផ្តល់នូវភស្តុតាងពីការវាយតម្លៃបរិស្ថាន ឬលិខិតអនុញ្ញាតនាំចេញឡើយ ។[193]

គ្លូបលវីតណេសមិនអាចបញ្ជាក់ថាតើ ភ្នាក់ងាររដ្ឋាភិបាលមួយណាទទួលខុសត្រូវចំពោះការគ្រប់គ្រងការនាំចូលខ្សាច់សំរាប់រុករានដី ដូចដែលបានប្រឈមសំរាប់ការសាងសង់ឡើយ ។ ការស្នើសុំលទ្ធកម្មខ្សាច់សំរាប់ការរុករានដីមិនត្រូវបានរាយបង្ហាញលើគេហទំព័ររបស់រដ្ឋាភិបាល ហើយគ្មានបញ្ញត្តិនៃច្បាប់មានតម្លៃស្មើសំរាប់ការនាំចូលទាំងនេះត្រូវបានរកឃើញឡើយ ។ ទោះយ៉ាងណា នៅក្នុងអ៊ីម៉េលរបស់ខ្លួននាខែ មេសា ឆ្នាំ 2010 រដ្ឋាភិបាលបានសរសេរ "*JTC តម្រូវឱ្យអ្នកផ្គត់ផ្គង់ខ្សាច់របស់ខ្លួនទាំងអស់អនុវត្តតាមនីតិវិធីស្របច្បាប់ក្នុងតំបន់ដើម្បីជីកស្រង់ធនធាន ឬដឹកជញ្ជូនខ្សាច់ពីប្រភព ដោយមិនបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ហើយស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីផលប៉ះពាល់បរិស្ថាន ។JTC ក៏រំលឹកជាទៀងទាត់ដល់អ្នកផ្គត់ផ្គង់ខ្សាច់របស់ខ្លួនអំពីផលវិបាកពីកិច្ចសន្យាធ្ងន់ធ្ងរ ប្រសិនបើពួកគេមិនអនុវត្តបញ្ញត្តិនៃច្បាប់ និងការបារម្ភពីបរិស្ថាន នៅក្នុងប្រទេសប្រភពដើម*" ។[194]

## កាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសសិង្ហបុរី

ដោយសារតែតម្រូវការរបស់រដ្ឋាភិបាលប្រទេសសិង្ហបុរីថា បណ្តាក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងប្រទេសសិង្ហបុរីត្រូវតែអនុវត្តតាមច្បាប់ជាតិនៃរដ្ឋប្រភពដើម បណ្តាក្រុមហ៊ុនប្រទេសសិង្ហបុរីទាំងអស់ដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាត្រូវតែអនុវត្តតាមច្បាប់ប្រទេសកម្ពុជា ។ នេះមិនគិតថាតើពួកគេកំពុងប្រតិបត្តិការដោយស្ថិតក្រោមកិច្ចសន្យាជាមួយភ្នាក់ងាររដ្ឋាភិបាលប្រទេសសិង្ហបុរីដែរឬអត់នោះឡើយ ។ ច្បាប់របស់ប្រទេសកម្ពុជារួមមាននូវការការពារបរិស្ថាន និងសង្គមដូចបានរៀបរាប់ខាងលើក្នុងជំពូក 4 ដូចជា អនុសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ទោះបីជាប្រទេសសិង្ហបុរីខ្លួនឯងមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាសិទ្ធិមនុស្សនេះក៏ដោយ ។



គ្លូបលវីតណេស

នាវាត្រូវបានថតថាមកដល់កំពង់ផែប្រទេសសិង្ហបុរីនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ។ កោះជូរ៉ុងនៅលើគំរោងរុករានដីធំបំផុតរបស់ប្រទេសសិង្ហបុរី អាចមើលបានតាមផ្នែកសាវតា ។

*"បណ្តារដ្ឋនឹងចាត់វាល់វិធានការណ៍ទាំងអស់ដែលចាំបាច់ដើម្បីធ្វើឱ្យប្រាកដថាបណ្តាសកម្មភាពស្ថិតក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ពួកគេ ត្រូវបានធ្វើឡើងដោយមិនត្រូវបណ្តាលឱ្យមានការខូចខាតដោយការបំពុលដល់រដ្ឋផ្សេងទៀត និងបរិស្ថានរបស់ពួកគេ" ។*

មាត្រា 194(2) នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ

ទោះយ៉ាងណាប្រទេសសិង្ហបុរីបានផ្តល់សច្ចាប័នលើអនុសញ្ញាជីវចំរុះជីវសាស្ត្រ (CBD) និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) ។[xxvi] ទាំងនេះផ្តល់ឱ្យរដ្ឋាភិបាលប្រទេសសិង្ហបុរីនិងប្រទេសរបស់ខ្លួននូវការទទួលខុសត្រូវដូចគ្នានឹងប្រទេសកម្ពុជាក្នុងការការពារ ប្រព័ន្ធអេកូឡូហ្ស៊ីសមុទ្រ និងទប់ស្កាត់ការធ្លាក់ចុះបរិស្ថាននៅក្នុងទឹកប្រទេសរបស់ខ្លួន ក៏ដូចជាបរិស្ថានសមុទ្រជារួម - ដូចជាការបូមខ្សាច់នៅក្នុងទឹក របស់ប្រទេសកម្ពុជាដែរ ។[195] មាត្រា 194 (2) នៃ UNCLOS ចែងថា "*បណ្តារដ្ឋនឹងចាត់វាល់វិធានការណ៍ទាំងអស់ដែលចាំបាច់ ដើម្បីធ្វើឱ្យប្រាកដថាបណ្តាសកម្មភាពស្ថិតក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ពួកគេត្រូវបានធ្វើឡើងដោយមិនត្រូវបណ្តាលឱ្យមានការខូចខាតដោយការបំពុលដល់រដ្ឋផ្សេងទៀត និងបរិស្ថានរបស់ពួកគេ*"។ មាត្រា 235(2) បន្តបញ្ជាក់ថា "*រដ្ឋត្រូវធ្វើឱ្យប្រាកដថា អាចទទួលបានបណ្តឹងសើរើយោងតាម ប្រព័ន្ធច្បាប់របស់ពួកគេ សំរាប់ការផ្តល់សំណងភ្លាមៗ និងគ្រប់គ្រាន់ ឬជំនួយផ្សេងទៀតយោងលើការខូចខាតដែលបណ្តាលមកពីការបំពុលបរិស្ថានសមុទ្រដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដោយស្ថិតក្រោមយុត្តាធិការរបស់ពួកគេ*"។ កាតព្វកិច្ចទាំងនេះរួមមាន ការការពាររាល់ប្រភេទការបំពុល សមុទ្រទាំងអស់ (រួមទាំងប្រតិបត្តិការនៅជ្រលងសមុទ្រដូចជាការបូមខ្សាច់ជាដើម) ដែលមាត្រា 198, 199, 204 nig 206 នៃ UNCLOS តម្រូវឱ្យមាន EIAs យុទ្ធសាស្ត្រសម្រាល និងផែនការត្រួតពិនិត្យ ។[196]

## តម្រូវការសំរាប់ប្រទេសសិង្ហបុរីក្នុងការរកប្រភពធនធានខ្សាច់របស់ខ្លួនប្រកបដោយចេរភាព

គ្លូបលវីតណេសជឿជាក់ថា ប្រទេសសិង្ហបុរីត្រូវតែទទួលយកការទទួលខុសត្រូវចំពោះផលប៉ះពាល់ក្នុងតំបន់នៃការប្រើប្រាស់ខ្សាច់របស់ខ្លួន ។ ឯកសាររបាយការណ៍នេះបង្ហាញថា បណ្តាក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរីកំពុងរុករកធនធានខ្សាច់ពីសម្បទានបូមខ្សាច់ដែលមានទីតាំងនៅក្នុងតំបន់ការពារ ឬ ក្បែរលំនៅដែលមានសារៈសំខាន់ជាអន្តរជាតិ ដោយមិនគិតពីជីវភាពរស់នៅក្នុងតំបន់ ។ ប្រតិបត្តិការបូមខ្សាច់នេះហាក់បីដូចជាមិនស្របតាមការ ការពារផ្លូវច្បាប់ផ្នែកបរិស្ថាន និងសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា ។ ពួកវាហាក់បីដូចជាមិនស្របតាមកាតព្វកិច្ចផ្ទាល់របស់ប្រទេសសិង្ហបុរីដោយស្ថិតក្រោម UNCLOS និង CBD ។ ជាងនេះទៀត របាយការណ៍នេះបានបង្ហាញជាសង្ខេបនូវការខ្វះខាតតម្លាភាពនៅក្នុងប្រទេសកម្ពុជាអំពីកន្លែង ដែលប្រាក់ចំណូលរកបានដោយវិស័យខ្សាច់នឹងចូលទៅកាន់រតនាគារជាតិ ។ ដោយសារប្រទេសវៀតណាមនឹងហាមរាល់ការនាំចេញខ្សាច់ទាំងអស់ចាប់

xxvi ប្រទេសសិង្ហបុរីបានផ្តល់សច្ចាប័ន CBD នៅក្នុងឆ្នាំ 1995 ហើយបានចូលជាធរមាននៅក្នុងប្រទេសសិង្ហបុរីនៅឆ្នាំ 1996 ។UNCLOS ត្រូវបានផ្តល់សច្ចាប័ន និងចូលជាធរមាននៅថ្ងៃ ដូចគ្នានៅក្នុងឆ្នាំ 1994 ។

ពីខែ មិថុនា ឆ្នាំ 2010 នោះប្រទេសកម្ពុជា ប្រហែលជាអាចក្លាយជាប្រភពខ្សាច់កាន់តែមានសារៈសំខាន់សំរាប់ប្រទេសសិង្ហបុរី ។

ភស្តុតាងដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ បង្កើតចម្ងល់អំពីថាតើភ្នាក់ងារគ្រប់គ្រងរបស់ប្រទេសសិង្ហបុរីធានាបានថា ក្រុមហ៊ុនបំពេញបាន តាមតម្រូវការរបស់ពួកគេ ដើម្បីអនុវត្តតាមច្បាប់ប្រទេសប្រភពដើម ដែលករណីនេះគឺច្បាប់ប្រទេសកម្ពុជាមានប្រសិទ្ធិភាពយ៉ាងណា ។ នេះគឺជាការសំខាន់ពិសេសដែលថា បរាជ័យនៃបញ្ញត្តិនៃច្បាប់របស់ប្រទេសកម្ពុជា ជាពិសេសពាក់ព័ន្ធនឹងកំណែទំរង់អភិបាលកិច្ចធនធានធម្មជាតិ ត្រូវបានកត់ត្រាទុកបានយ៉ាងល្អ ដោយរួមទាំងដោយគ្លូបលវីតណេសផងដែរ ។ ជាតួយ៉ាងនេះ រដ្ឋាភិបាលដែលមានការទទួលខុសត្រូវ គួរទាមទារឱ្យបណ្តាក្រុមហ៊ុនរបស់ខ្លួនមានការព្យាយាមបន្ថែមទៀត ក្នុងការការពារថែរក្សាសុវត្ថិភាពបរិស្ថាន និងសង្គម ។ ដូចដែលភស្តុតាងមួយចំនួនបង្ហាញអញ្ចឹង ប្រសិនបើក្រុមប្រឹក្សាគ្រប់គ្រងស្ថិតក្រោមរដ្ឋាភិបាលប្រទេសសិង្ហបុរីខ្លួនឯង កំពុងធ្វើលទ្ធកម្មខ្សាច់នាំចេញពីប្រទេសកម្ពុជា នោះអាជ្ញាធរប្រទេសសិង្ហបុរី ត្រូវតែចាត់វិធានការណ៍បន្ទាន់ផងដែរ ដើម្បីស៊ើបអង្កេតការពាក់ព័ន្ធជាក់ស្តែងដោយផ្ទាល់នឹងការបំពានជាបន្តបន្ទាប់នៃការការពារទាំងនេះដោយបណ្តាក្រុមហ៊ុនដែលពួកគេចុះកិច្ចសន្យា ។ ប្រសិនបើការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវបានដាក់ជូនរដ្ឋាភិបាលប្រទេសសិង្ហបុរីដូចដែលតម្រូវដោយការស្នើសុំលទ្ធកម្មមួយចំនួន ឯកសារទាំងនេះគួរតែបានបង្ហាញថា សម្បទានមិនបានអនុវត្តតាមច្បាប់ប្រទេសកម្ពុជា ។ នេះលើកឡើងនូវការបារម្ភធ្ងន់ធ្ងរ អំពីថាតើកិច្ចសន្យាលទ្ធកម្មបែបនេះ គួរតែត្រូវបានដោះស្រាយដំបូងគេដែរឬអត់ ។

ចម្ងល់អំពីចីរភាពនៃការរុករកធនធានខ្សាច់ពីតំបន់ត្រូវបានលើកឡើងរួចហើយនៅក្នុងរដ្ឋាភិបាលប្រទេសសិង្ហបុរី ។ នៅក្នុងកិច្ចពិភាក្សាសភាក្នុងឆ្នាំ 2007 បន្ទាប់ពីបំរាមរបស់ប្រទេសឥណ្ឌូនេស៊ីវាហាក់បីដូចជាថា ឃ្លាមួយត្រូវបានបន្ថែមទៅក្នុងការស្នើសុំផ្គត់ផ្គង់ខ្សាច់ ដែលតម្រូវឱ្យវាត្រូវបានរុករក ប្រកបដោយចីរភាព ហើយឱ្យអ្នកផ្គត់ផ្គង់ផ្តល់នូវរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានដើម្បីធ្វើឱ្យវាមានចីរភាព ។ កិច្ចពិភាក្សាបានសន្និដ្ឋានថា រដ្ឋាភិបាល *"... មិនបានឃើញពីតម្រូវការ ឬមិនឃើញថាសមរម្យសំរាប់យើងកំណត់លក្ខខណ្ឌលើអ្នកនាំចេញនៅក្នុងបណ្តាប្រទេសនាំចេញឡើយ ។ អ្នកនាំចេញមិនមែនរុករករ៉ែតែសំរាប់ការនាំចេញទៅកាន់ប្រទេសសិង្ហបុរីឡើយ"* ។[197] វិសោធនកម្មថ្មីៗលើក្របខណ្ឌច្បាប់របស់ BCA សំរាប់ ការនាំចូលខ្សាច់ ឆ្លើយតបទៅនឹងតំរូវការធានាឱ្យបានចីរភាពសេដ្ឋកិច្ចសំរាប់វិស័យសំណង់ក្នុងប្រទេស គឺជាភស្តុតាងថា រដ្ឋាភិបាលប្រទេសសិង្ហបុរី អាចឆ្លើយតបយ៉ាងសកម្មចំពោះការផ្លាស់ប្តូរស្ថានភាពទីផ្សារ ។ ដូចគ្នានេះដែរ តាមរយៈការដោះស្រាយការរំខានតាមព្រំដែន រដ្ឋាភិបាលប្រទេសសិង្ហបុរីបានបង្ហាញថា ខ្លួនអាចសម្របសម្រួលបានដោយជោគជ័យនូវការផ្លាស់ប្តូរគោលនយោបាយបរិស្ថានក្នុងតំបន់ ទៅលើបញ្ហាដែលស្ថិតនៅក្រៅព្រំដែនជាតិរបស់ខ្លួន ។

ការពឹងផ្អែករបស់ប្រទេសសិង្ហបុរីលើពាណិជ្ជកម្មវត្ថុធាតុដើមក្នុងតំបន់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ផ្តល់ឱ្យរដ្ឋាភិបាលនូវឱកាសស្វែងរកជម្រើសយ៉ាងសកម្មសំរាប់ការរកប្រភពធនធានប្រកបដោយចីរភាព ។ ជំហរនេះ នឹងមិនត្រឹមតែធ្វើឱ្យប្រាកដថា អាជ្ញាធរគ្រប់គ្រងរបស់ខ្លួនកំពុង បំពេញការទទួលខុសត្រូវស្របច្បាប់ពាក់ព័ន្ធនឹងប្រតិបត្តិការនៃបណ្តាក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរីនៅខាងក្រៅព្រំដែនជាតិរបស់ខ្លួន តែវានឹងធ្វើឱ្យប្រាកដថាប្រទេសសិង្ហបុរីកំពុងបំពេញកាតព្វកិច្ចផ្ទាល់របស់ខ្លួនស្ថិតក្រោមច្បាប់អន្តរជាតិ ហើយស្របពេលនេះដែរ ធ្វើឱ្យរដ្ឋាភិបាលបង្ហាញបានពី ការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះចីរភាពបរិស្ថានផងដែរ ។



គ្លូបលវីតណេស

ការបូមខ្សាច់ដែលកើតឡើងនៅខាងក្នុងជម្រកសត្វព្រៃពាមក្រសោប និងតំបន់រុំាសារកោះកាពិ ត្រូវបានថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ខេត្តកោះកុង ប្រទេសកម្ពុជា ។ លំនៅនេះ ត្រូវបានទទួលស្គាល់ថាជាដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ និងជាលំនៅរបស់ប្រភេទពូជរងគ្រោះថ្នាក់ជាច្រើន ។



ក្លូបលវីតណេស

អន្ទាក់ក្តាមអត់បានការ ខែ វិច្ឆិកា ឆ្នាំ 2009 ខេត្តកោះកុង ប្រទេសកម្ពុជា ប្រជានេសាទក្នុងតំបន់បានប្រាប់គ្លូបលវីតណេសថា ពូជត្រី និងទិន្នផលក្តាមត្រូវបានបំផ្លិចបំផ្លាញ ចាប់តាំងពីការបូមខ្សាច់បានចាប់ផ្តើម។

ស្របពេលជាមួយគ្នានេះ ប្រទេសសិង្ហបុរីអាចជួយដល់ភាពជាអ្នកនាំមុខរបស់ខ្លួននៅក្នុង អភិបាលកិច្ចល្អក្នុងតំបន់ ដោយអនុវត្តការធ្វើសវនកម្មហិរញ្ញវត្ថុ ប្រកប ដោយតម្លាភាពលើរាល់អង្គភាពរបស់ប្រទេសសិង្ហបុរី ដែលពាក់ព័ន្ធនឹងវិស័យ ខ្សាច់របស់ប្រទេសកម្ពុជា។

គ្លូបលវីតណេសបានរៀបចំកិច្ចប្រជុំមួយជាមួយតំណាងរបស់រដ្ឋាភិបាលប្រទេសសិង្ហបុរីនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ដែលក្នុងនោះយើងបាន ព្រមព្រៀងបង្ហាញលទ្ធផលនៃការស៊ើបអង្កេតដែលបានរៀបរាប់នៅក្ នុងរបាយការណ៍ នៅក្នុងនិទាឃរដូវឆ្នាំ 2010 សំរាប់ពិភាក្សាបន្ថែមទៀត។ ជាអកុសល នៅពេលគ្លូបលវីតណេសបានព្យាយាមរៀបចំកិច្ចប្រជុំតាមដាននៅក្នុងខែ មិនា ឆ្នាំ 2010 តំណាងរដ្ឋាភិបាលបានឆ្លើយតបថា :

*"សូមអរគុណអ្នកសំរាប់ចំណាប់អារម្មណ៍របស់អ្នក ក្នុងការបង្កើតកិច្ចប្រជុំជាលើកទីពីរជាមួយយើង។ យើងដឹងថា ចំណាប់អារម្មណ៍ចំបងរបស់អ្នក គឺស្ថិតក្នុងការពិភាក្សាពីឧស្សាហកម្មខ្សាច់នៅក្នុងប្រទេសកម្ពុជា។ ការនាំចូលខ្សាច់របស់យើង គឺជាសកម្មភាពពាណិជ្ជកម្មបរិសុទ្ធមួយ ដែលយើង តំរូវឱ្យអ្នកមៅការអនុវត្តតាមច្បាប់របស់ប្រទេសប្រភពដើម។ ដូចដែលយើងបានជួបប្រជុំគ្នាជាមួយនឹងគ្លូបលវីតណេសកាលពីខែ វិច្ឆិកា ឆ្នាំមុន ហើយបានផ្តល់ព័ត៌មានលើបញ្ហានេះហើយ យើងមិនមានព័ត៌មានថ្មីទៀតដើម្បីចែករំលែកទេ។ ហេតុនេះ យើងគិតថា កិច្ចប្រជុំមួយទៀតប្រហែលជា មិនចាំបាច់ទេ"*។[198]

គ្លូបលវីតណេសបានសរសេរលិខិតទៅកាន់រដ្ឋាភិបាលប្រទេសសិង្ហបុរី BCA និង JTC ផងដែរ ដើម្បីស្នើសុំការឆ្លើយតបរបស់ ពួកគេចំពោះលទ្ធផលរកឃើញសំខាន់ៗដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ។ ការឆ្លើយតបមួយត្រូវបានទទួលកាលពីថ្ងៃទី 22 ខែ មេសា ឆ្នាំ 2010 ហើយផ្នែកពាក់ព័ន្ធអាចមើលឃើញបាននៅក្នុងរបាយការណ៍ នេះ។



www.wildsingapore.com / Ria Tan

ស្មៅសមុទ្រ ផ្តល់សេវាប្រព័ន្ធអេកូឡូហ្ស៊ីយ៉ាងសំខាន់។ វាលស្មៅសមុទ្ររបស់ប្រទេសកម្ពុជា ពេលដែលវាលស្មៅធំបំផុតនៅក្នុងសមុទ្រចិនភាគខាងត្បូង កំពុងស្ថិតក្រោមការគំរាមកំហែងពីការបូមខ្សាច់។

# 6. ប្រធានខ្សាច់ ៖

## ម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា – តើនេះជាជំនួយមានប្រសិទ្ធិភាពដែរឬទេ?

រដ្ឋាភិបាលកម្ពុជា មានប្រវត្តិដ៏យូរអង្វែងមួយនៃការប្រើប្រាស់ជំនួយរបស់ម្ចាស់ជំនួយអន្តរជាតិ ដើម្បីផ្តល់សេវារបស់រដ្ឋសំខាន់ៗដូចជា ហេដ្ឋារចនាសម្ព័ន្ធ ការថែទាំសុខភាព និងការអប់រំ។ ចេញពីលទ្ធផលភ្លាមៗនៃសង្គ្រាមស៊ីវិលរបស់ប្រទេសកម្ពុជា នេះអាចជាការដោះសារបាន។ ស្ទើរ តែ 20 ឆ្នាំក្រោយមក នេះមិនអាចជាការដោះសារបានឡើយ។ ជាមួយនឹងតម្រូវការមូលដ្ឋានរបស់ប្រជាជនកម្ពុជាត្រូវបានគាំទ្រដោយជំនួយ ពួកវរជននយោបាយរបស់ប្រទេសកម្ពុជា មានសេរីភាពធ្វើអាជីវកម្មទ្រព្យរបស់រដ្ឋសំរាប់ជាផលចំណេញផ្ទាល់ខ្លួន និងគាំទ្រតួនាទីអំណាចផ្ទាល់របស់ ពួកគេ។ ធនធានធម្មជាតិរបស់ប្រទេស – ដី ព្រៃ រ៉ែ ប្រេង ឆ្នេរសមុទ្រ ជលផលរបស់ប្រទេស – គឺជាប្រភពសំរាប់ជាប្រាក់ចំណូលក្រៅថវិកានេះ។

សំរាប់អ្នកទាំងឡាយដែលមានអំនាច គ្មានការលើកទឹកចិត្តណាមួយឱ្យផ្លាស់ប្តូរទេ។ វាធ្វើឱ្យត្រូវនឹងគំរូអាជីវកម្មរបស់ពួកគេបានល្អណាស់ ដើម្បីឱ្យជំនួយរបស់ម្ចាស់ជំនួយ គាំទ្រមុខងារមូលដ្ឋានរបស់រដ្ឋ ស្របពេលដែលពួកគេខ្លួនឯងចូលរួមក្នុងការហែកច្រៀកទ្រព្យសម្បត្តិ។ នេះគឺជាមូលហេតុដែលរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដោយម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា ដើម្បីកែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រទេសឱ្យបានជាផលប្រយោជន៍ប្រជាជនកាន់តែច្រើន បានបរាជ័យ។

បណ្តាម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា មានភាពយឺតយ៉ាវ – ឬមិនមានចេតនាទទួលស្គាល់តថភាពនេះ។ ឥឡូវនេះប្រវត្តិសាស្ត្រមានរយៈពេល 18 ឆ្នាំ ហើយនៃការចូលរួមបរាជ័យរបស់ម្ចាស់ជំនួយក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ដែលមើលឃើញបានតាមរយៈលំដាប់លំដោយនៃការសន្យាដែលមិនបានបំពេញផ្នែកអភិបាលកិច្ចឆ្ពោះទៅកាន់ការទទួលខុសត្រូវ និងតម្លាភាព។



ម្តាយ និងកូនម្នាក់ដើរកាត់សំណល់បាក់បែក ជាទីកន្លែងដែលផ្ទះរបស់ពួកគេស្ថិតនៅបន្ទាប់ពីការបណ្តេញចេញដោយបង្ខំ ដើម្បីធ្វើផ្លូវសំរាប់សណ្ឋាគារ ក្រុងព្រះសីហនុ ឆ្នាំ 2008 ស្របពេលដែលប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្លាំងនាប៉ុន្មានឆ្នាំថ្មីៗនេះ អត្ថប្រយោជន៍នេះ ត្រូវបានច្បាមចាប់ដោយវរជនអាជីវកម្ម និងនយោបាយរបស់ប្រទេស ដោយទុកឱ្យប្រជាជនភាគច្រើនក្រីក្រ។

Amnesty International



AP/Press Association

ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា នៅចុងបញ្ចប់នៃកិច្ចប្រជុំរវាងម្ចាស់ជំនួយ-រដ្ឋាភិបាល នៅក្នុងទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី 20 ខែ មិថុនា ឆ្នាំ 2007។

ប៉ុន្មានឆ្នាំថ្មីៗនេះ គ្មានអ្វីផ្លាស់ប្តូរទេ។ មួយខែមុនខែ ធ្នូ ឆ្នាំ 2008 វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) និងមួយរយៈពេលខ្លីមុនការបោះពុម្ពផ្សាយប្រទេសជាតិលក់ គ្លូបលវីតណេសបានទាក់ទងបណ្តាម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា ដើម្បីកើនរំលឹកពួកគេ អំពីគ្រោះថ្នាក់នៃមហន្តរាយពីអំពើពុករលួយនៅក្នុងឧស្សាហកម្មដកស្រង់ធនធានដែលកំពុងមានការកើនឡើងរបស់ប្រទេសនេះ។ ដោយមាននូវគ្រោះថ្នាក់ជាក់ច្បាស់ពាក់ព័ន្ធនឹង លាភហិរញ្ញវត្ថុដែលទទួលបានដោយចៃដន្យដែលអាចមាន គ្លូបលវីតណេសបានស្នើដល់បណ្តាម្ចាស់ជំនួយឱ្យធ្វើការផ្តល់ជំនួយ ជាលក្ខខណ្ឌនឹងការចាត់ វិធានការណ៍ដោយរដ្ឋាភិបាលឱ្យបំបាត់ចោលអំពើពុករលួយ និងជម្រុញឱ្យមានអភិបាលកិច្ចល្អនៅក្នុងវិស័យទាំងនេះ។

លទ្ធផលមានស្តួចស្តើង។ នៅឯកិច្ចប្រជុំបណ្តាម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា ជាថ្មីម្តងទៀតបានបង្កើនទឹកប្រាក់ជំនួយអភិវឌ្ឍន៍របស់ពួកគេឱ្យប្រទេស កម្ពុជា។ តួលេខផ្លូវការដែលបានលើកឡើង មានប្រមាណ 1 ពាន់លានដុល្លារអាមេរិក។ តួលេខនេះ ធំស្ទើរតែស្មើនឹងប្រាក់ចំណូលក្នុងស្រុកទាំងមូលរបស់ប្រទេសកម្ពុជា តាមរយៈរតនាគារជាតិសំរាប់ឆ្នាំដូចគ្នានេះ។[199] សេចក្តីយោងតែមួយគត់អំពីឧស្សាហកម្មដកស្រង់ធនធានរបស់ប្រទេសនៅក្នុងបណ្តាចំណុចប្រសើរៗទាំងឡាយដែលបានបង្កើតឡើងរវាងពេលនោះ និងកិច្ចប្រជុំបន្ទាប់ (ខែ មិថុនា ឆ្នាំ 2010) គឺដើម្បីបង្កើតប្រព័ន្ធទិន្នន័យដែលអាចទទួលបានជាសាធារណៈពីសម្បទានរុករករ៉ែ។ ស្ទើរតែ 18 ខែក្រោយមក ហើយមកទល់នឹងពេលដែលគ្លូបលវីតណេសអាចមើលឃើញ គ្មាន ប្រព័ន្ធទិន្នន័យណាមួយត្រូវបានបង្កើតឡើងឡើយ។

រឿងរ៉ាវនៃការបាត់បង់ខ្សាច់របស់ខេត្តកោះកុង គឺជាការចោទប្រកាន់មួយនៃការបរាជ័យនេះដោយសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយឱ្យបាន សមរម្យនូវការចាប់ទ្រព្យសម្បត្តិរបស់រដ្ឋដោយក្រុមបុគ្គលដែលមានទំនាក់ទំនងល្អមួយក្រុមតូច។ អ្នកទាំងឡាយដែលគ្រប់គ្រងវិស័យនេះធ្វើបាន យ៉ាងប្រសើរ។ គ្លូបលវីតណេសប៉ាន់ស្មានថា តម្លៃប្រចាំឆ្នាំនៃពាណិជ្ជកម្មខ្សាច់នៅក្នុងខេត្តកោះកុងតែមួយគត់មាន 28.7 លានដុល្លារអាមេរិក។ ស្របពេលនេះដែរ គ្មានវិធីណាមួយដើម្បីតាមដានថាតើកម្រៃសួយសារពីវិស័យខ្សាច់ដែលត្រូវបង់សំរាប់ឆ្នាំ 2009 នឹងទៅដល់រតនាគារជាតិដែរឬ អត់។ ជាធម្មតា វាគឺជាជនក្រីក្ររបស់ប្រទេសកម្ពុជា ដែលទទួលខុសត្រូវចំពោះផលប៉ះពាល់នៃការចាប់យករបស់វរជននេះ ដោយមានការបាត់បង់នូវជីវភាពរស់នៅនិងបរិស្ថានឆ្នេរសមុទ្ររបស់ពួកគេ។



គ្លូបលវីតណេស

ការកាប់ឈើខុសច្បាប់នៅក្នុងជម្រកសត្វព្រៃភ្នំឱរ៉ាល់ ឆ្នាំ 2004 ។ សំរាប់រយៈពេល 15 ឆ្នាំចុងក្រោយ ម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា បានបរាជ័យធ្វើឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះអំពើពុករលួយក៏រិតខ្ពស់ និងការបរាជ័យលើគោលនយោបាយពាក់ព័ន្ធនឹងការធ្វើអាជីវកម្មធនធានធម្មជាតិរបស់ប្រទេស ។

មានរឿងមួយទៀតនៅទីនេះផងដែរ : នោះគឺការទទួលខុសត្រូវសារពើពន្ធរបស់ម្ចាស់ជំនួយចំពោះប្រជាជនក្នុងស្រុកផ្ទាល់របស់ពួកគេ ។ អ្នកជាប់ពន្ធ ក្នុងប្រទេសរបស់ម្ចាស់ជំនួយ ផ្តល់ប្រាក់របស់ពួកគេឱ្យរដ្ឋាភិបាលរបស់ពួកគេ ដោយរំពឹងទុកថាមូលនិធិអភិវឌ្ឍន៏ ត្រូវបានចំណាយលើការកាត់បន្ថយ ភាពក្រីក្រនៅក្រៅប្រទេស ។ ហើយនៅក្នុងបណ្តាប្រទេសជាច្រើនដែលមានរដ្ឋាភិបាលកាន់តែស្លូត ជំនួយរបស់ម្ចាស់ជំនួយបានសម្រេចគោលដៅនេះ កាន់តែច្រើន ។ តែការអនុវត្តនៅក្នុងប្រទេសកម្ពុជា គឺជាការគំរាមកំហែងដ៏អាក្រក់មួយ ។

ជួសឱ្យការកាត់បន្ថយភាពក្រីក្រ មូលនិធិរបស់ម្ចាស់ជំនួយ ហាក់បីដូចជាកំពុងដោះលែងពួកវរជនពុករលួយ ឱ្យចូលរួមក្នុងដំណើរការហែកច្រៀក ទ្រព្យសម្បត្តិលក់ដុំ ។ បណ្តាម្ចាស់ជំនួយរបស់ប្រទេសហាក់បីដូចជាមិនមានឧបករណ៏ ឬបំណងផ្នែកនយោបាយដើម្បីឆ្លើយតបនឹងបញ្ហានេះទេ ។ ដោយមានទំហំមូលនិធិអភិវឌ្ឍន៏អាចទទួលបានមានកម្រិតនៅក្នុង បរិយាកាសសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ការផ្តល់ជំនួយដោយមិនមានតម្រូវការ កើតឡើងស្របគ្នាលើរដ្ឋាភិបាលទទួលជំនួយឱ្យគ្រប់គ្រងមានប្រសិទ្ធិភាព នូវធនធានផ្ទាល់របស់ខ្លួន គឺជាការប្រើប្រាស់ប្រាក់របស់អ្នកជាប់ពន្ធអន់ បំផុត ។

ក្នុងឋានៈជាភាគីពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍន៏របស់ប្រទេសកម្ពុជា ដែលបានរៀបចំឡើងសំរាប់ CDCF នាពេលបន្ទាប់ក្នុងខែ មិថុនា ឆ្នាំ 2010 ការបង្ហាញជាច្រើនហាក់បីដូចជាថា ម្ចាស់ជំនួយអន្តរជាតិ មិនទាន់បានសន្យាបង្កើនតួលេខជំនួយម្តងទៀតនៅឡើយ ហើយថារដ្ឋាភិបាលបរាជ័យ បំពេញបាននូវសន្ទស្សន៏សំខាន់ៗសំរាប់អភិបាលកិច្ចកាន់តែប្រសើរម្តងទៀតនៅឡើយ ។ គ្លូបលវីតណេស នឹងស្នើសុំគំរូថ្មី : ជាគំរូមួយបង្កើនល្បឿន ឆ្ពោះទៅកាន់ការធ្វើឱ្យប្រទេសកម្ពុជាអាចថែរក្សាធនធានផ្ទាល់របស់ខ្លួនសំរាប់ការអភិវឌ្ឍន៏ ជាជាងបន្តវដ្តនៃការពឹងផ្អែកលើជំនួយដែលបង្កើនឱ្យមាន អំពើពុករលួយនេះ ។

ជំនួសឱ្យការមើលមកឆ្នាំនេះថាជា "អាជីវកម្មដូចធម្មតា" បណ្តាម្ចាស់ជំនួយរបស់ប្រទេស អាចអនុវត្តការផ្តល់ជំនួយផ្អែកតាមគោលការណ៏នៃការ ទទួលខុសត្រូវរួមគ្នា ការទទួលខុសត្រូវរបស់រដ្ឋ ដើម្បីការពារប្រជាពលរដ្ឋរបស់ខ្លួន និងរួមប្តេជ្ញាចិត្តប្រើប្រាស់ជំនួយអភិវឌ្ឍន៏ឱ្យមានប្រសិទ្ធិភាព ។ បណ្តាម្ចាស់ជំនួយអាចផ្តោតទៅលើការបង្កើតបរិយាកាសមួយ ដែលក្នុងនោះសង្គមស៊ីវិលថ្នាក់ជាតិ ចាប់ផ្តើមអំពាវនាវឱ្យរដ្ឋាភិបាលរបស់ពួកគេ ទទួលខុសត្រូវដោយការបង្កើតសន្ទស្សន៏ជាប់លាប់ ផ្តោតតាមគោលដៅ និងអាចវាស់វែងបាន ដើម្បីធ្វើឱ្យប្រាកដថា ភោគទ្រព្យធនធានធម្មជាតិរបស់ ប្រទេស ត្រូវបានប្រើប្រាស់សំរាប់ការអភិវឌ្ឍន៏ ។ ហើយនាឆ្នាំបន្ទាប់ៗទៀត ការប្តេជ្ញាចិត្តរបស់ម្ចាស់ជំនួយដើម្បីផ្តល់ជំនួយអភិវឌ្ឍន៏ អាចអនុវត្តតាម មិនមែនដឹកនាំ ការរីកចម្រើនជាក់លាក់នៅក្នុងការអនុវត្តវិធានការណ៏ទាំងនេះ ដើម្បីសម្រេចបានអភិបាលកិច្ចកាន់តែប្រសើរនៅក្នុងវិស័យខ្សាច់ និង ធនធានធម្មជាតិទាំងមូល ។

# 7. អនុសាសន៍

## រាជរដ្ឋាភិបាលកម្ពុជាគួរតែ ៖

1. ព្យួរជាបន្ទាន់សកម្មភាពធ្វើអាជីវកម្មខ្សាច់ដែលមានទំនោរនាំចេញទាំងអស់ ។ ពិនិត្យឡើងវិញរាល់អាជ្ញាប័ណ្ណ យោងតាមច្បាប់ប្រទេស កម្ពុជា តាមរយៈក្រុមការងារឯករាជ្យ ដែលតំណាងឱ្យបណ្ដាក្រសួងពាក់ព័ន្ធ និងបណ្ដាសហគមន៍រងផលប៉ះពាល់ ។

2. ពិនិត្យឡើងវិញនូវប្រព័ន្ធផ្ដល់អាជ្ញាប័ណ្ណ ដើម្បីឱ្យអាជ្ញាប័ណ្ណដែលបានចេញជាថ្មីឱ្យបន្តការធ្វើអាជីវកម្ម និងការនាំចេញ ព្រមទាំង អាជ្ញាប័ណ្ណថ្មីៗ ត្រូវបានផ្ដល់ឱ្យ ប្រសិនបើក្រុមហ៊ុនអាចបង្ហាញថាពួកគេ ៖

   - កំពុងប្រតិបត្តិការស្របតាមបញ្ញត្តិនៃច្បាប់ជាតិប្រទេសកម្ពុជា រួមទាំងការធ្វើអធិការកិច្ចជាទៀងទាត់ ដោយចំហរ និងដោយ ឯករាជ្យដោយភ្នាក់ងារសាធារណៈ
   - បានបញ្ចប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានយោងតាមច្បាប់ ជាមួយនឹងការចូលរួមពីសាធារណៈជន និងបង្កើតនូវផែនការ គ្រប់គ្រងបរិស្ថាន ដែលរួមទាំងវិធានការណ៍ទប់ស្កាត់ផល ប៉ះពាល់ដល់លំនៅដែលងាយរងផលប៉ះពាល់ផ្នែកបរិស្ថាន និង ប្រជាជនមូលដ្ឋាន ស្របជាមួយនឹងការអនុវត្តប្រសើរបំផុតជាអន្តរជាតិ
   - ចេញផ្សាយព័ត៌មានជាសាធារណៈអំពីម្ចាស់ទទួលប្រយោជន៍របស់ពួកគេ ប្រភពមូលនិធិរបស់ពួកគេ កំណត់ត្រាតាមដានរបស់ ពួកគេនៅក្នុងឧស្សាហកម្ម សមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុរបស់ពួកគេដើម្បីធ្វើអាជីវកម្មសិទ្ធិបូមខ្សាច់ណាមួយដែលត្រូវ បានផ្ដល់ជូន សមត្ថភាពរបស់ពួកគេដើម្បីសម្រាលផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ចសង្គមអវិជ្ជមាន និងការមានមូលនិធិដើម្បី ដោះស្រាយការខូចខាតណាមួយដែលបានកើតឡើង ។

3. ចាត់វិធានការណ៍បន្ទាន់ ដើម្បីធានាឱ្យមានតម្លាភាពនៅក្នុងការចេញអាជ្ញាប័ណ្ណជាថ្មីនេះ និងការផ្ដល់ឱ្យនាពេលអនាគតនៃសម្បទានរុករក រ៉ែខ្សាច់ ៖

   - ផ្ដល់សិទ្ធិធ្វើអាជីវកម្ម និងនាំចេញខ្សាច់ក្នុងការដេញថ្លៃជាចំហរ និងប្រកួតប្រជែង ដោយធ្វើឱ្យលក្ខណៈវិនិច្ឆ័យលក្ខណៈសម្បត្តិ ជាមុន ឱ្យទទួលបានជាសាធារណៈ
   - ចេញផ្សាយរាល់កិច្ចសន្យាធ្វើអាជីវកម្ម និងនាំចេញខ្សាច់ទាំងអស់ ហើយនិងលំអិតពេញលេញពីការដេញថ្លៃដែលបានជោគជ័យ និងមិនបានជោគជ័យ មុនពេលកិច្ចសន្យាចាប់ផ្ដើមអនុវត្ត ។

4. ធានាឱ្យមានការបង្ហាញពេញលេញ និងជាបន្តបន្ទាប់នូវព័ត៌មានពាក់ព័ន្ធនឹងការធ្វើអាជីវកម្មស្រទាប់រ៉ែខ្សាច់ ថាជាទ្រព្យសម្បត្តិ សាធារណៈ ។ ព័ត៌មានដែលអាចទទួលបានជាសាធារណៈគួរតែរួមមាន ៖

   - ទំហំ ទីតាំង និងសញ្ញាណនៃស្រទាប់រ៉ែ
   - ឈ្មោះប្រតិបត្តិករ និងដៃគូណាមួយ និង/ឬអ្នកចុះហត្ថលេខាបន្តនៃសម្បទាន/អាជ្ញាប័ណ្ណណាមួយ
   - លំអិតពីការសន្យាណាមួយដែលធ្វើឡើងដើម្បីទទួលបានសិទ្ធិ ។

5. ធានាឱ្យមានការគ្រប់គ្រងប្រកបដោយតម្លាភាពលើប្រាក់ចំណូលដែល រកបានពីការធ្វើអាជីវកម្ម និងការនាំចេញខ្សាច់ ៖

   - ចេញផ្សាយព័ត៌មានប្រាក់រង្វាន់ពីការចុះហត្ថលេខា និងការបង់ប្រាក់ចំណាយតែម្ដង ផ្សេងទៀតដែលធ្វើឡើងដោយក្រុមហ៊ុន ឱ្យ រដ្ឋាភិបាលប្រទេសកម្ពុជា ធ្វើឱ្យការបង់ប្រាក់ចំណាយទាំងនេះទៅជាគណនីធនាគាររបស់រដ្ឋាភិបាលតែមួយគត់ ដែលត្រូវបានធ្វើ សវនកម្មដោយឯករាជ្យ ។
   - ធ្វើការបង់ប្រាក់ចំណាយធម្មតាពាក់ព័ន្ធនឹងការដកស្រង់ធនធាន (រួមមានសួយសារ ពន្ធ និងអាករ) ទៅក្នុងគណនីរដ្ឋាភិបាល ពិតប្រាកដដែលត្រូវបានធ្វើសវនកម្មដោយឯករាជ្យ ។
   - លទ្ធផលនៃសវនកម្មទាំងពីរ ត្រូវតែធ្វើឱ្យអាចទទួលបានជាសាធារណៈក្នុងទម្រង់ជាចំណែកតូចៗ ។

6. ធ្វើការពិនិត្យពេញលេញលើក្របខណ្ឌច្បាប់ដែលគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់ រួមទាំងបញ្ញត្តិនៃច្បាប់បរិស្ថានផងដែរ ។ អនុម័ត គោលការណ៍ប្រុងប្រយ័ត្នជាមុន ជាមូលដ្ឋានសំរាប់ការគ្រប់គ្រងការធ្វើអាជីវកម្មធនធានធម្មជាតិ ។

7. ជំនួស សេចក្ដីសម្រេចពាក់ព័ន្ធនឹងការកម្រិតលើការធ្វើអាជីវកម្មខ្សាច់ ដោយអនុក្រិត្យដែលកំណត់នូវតម្រូវការបច្ចេកទេសនៃការផ្ដល់ ការពិនិត្យឡើងវិញ និងការបដិសេធអាជ្ញាប័ណ្ណសំរាប់ការធ្វើអាជីវកម្មខ្សាច់ និងត្រូវបានធ្វើឱ្យស្របពេញលេញជាមួយច្បាប់រុករករ៉ែ បរិស្ថាន និងធនធានទឹក ។ ធ្វើឱ្យប្រាកដថា ចំណុចនេះត្រូវបានធ្វើឡើងតាមរយៈការពិភាក្សាអន្តរក្រសួង ដោយពាក់ព័ន្ធនឹងការប្រឹក្សាពី សង្គមស៊ីវិល និងថាអត្ថបទចុងក្រោយរួមមាន ៖

   - ការបញ្ជាក់ពីស្ថានភាពដែលការបូមខ្សាច់អាចកើតឡើងនៅក្នុងទឹកសាប នៅក្នុងទឹកសមុទ្រ និងសម្រាប់នាំចេញ ដោយកំណត់ ពីវិធានការណ៍ការពារបណ្ដាបរិយាកាសជុំវិញដែលងាយរងផលប៉ះពាល់ផ្នែកបរិស្ថាន ។
   - តម្រូវការបច្ចេកទេស និងបរិស្ថានសម្រាប់រាល់ការបូមខ្សាច់គ្រប់ប្រភេទទាំងអស់ ជាមួយនឹងបណ្ដាលក្ខខណ្ឌទាំងអស់ដែលបាន កំណត់ក្នុងសន្ទានុក្រមពេញលេញ ។
   - ការទទួលខុសត្រូវរបស់អាជ្ញាធរផ្សេងៗ នីតិវិធីដែលត្រូវតែអនុវត្តតាមក្នុងការវាយតម្លៃសមត្ថភាពក្រុមហ៊ុនក្នុងការធ្វើ ប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងថាតើសកម្មភាពដែលបានស្នើសុំស្របជាមួយច្បាប់ និងការដាក់ទោសទណ្ឌចំពោះការបំពាន ដែរឬអត់ ។
   - នីតិវិធីសម្រាប់ការធ្វើអធិការកិច្ចឡើងវិញលើកិច្ចសន្យាដែលមានស្រាប់ រួមទាំងកិច្ចសន្យាទាំងឡាយណាសម្រាប់ការនាំឱ្យមាន ប្រតិបត្តិការស្របតាមបញ្ញត្តិនៃច្បាប់ផងដែរ ។

8. បញ្ជាក់ច្បាស់ពីតួនាទីគណៈកម្មការការធ្វើអាជីវកម្មខ្សាច់ និងការទទួលខុសត្រូវរបស់គណៈកម្មការទាក់ទងនឹងភ្នាក់ងារផ្សេងទៀតដែល ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មខ្សាច់ និងការនាំចេញ ហើយធ្វើឱ្យប្រាកដថាគណៈកម្មការអាចដើរតួជាភ្នាក់ងារឯករាជ្យដើម្បីបំពេញតាម គោលបំណងរបស់ខ្លួន ។

9. ផ្តល់សំណងដល់ប្រជាជនមូលដ្ឋានដែលរងផលប៉ះពាល់ដោយសកម្មភាពបូមខ្សាច់ យោងតាមច្បាប់ជាតិរបស់ប្រទេសកម្ពុជា និងការអនុវត្ត ប្រសើរបំផុតជាអន្តរជាតិ ។

## រដ្ឋាភិបាលប្រទេសសិង្ហបុរីគួរតែ :

1. បញ្ឈប់បណ្តោះអាសន្នការនាំចូលខ្សាច់ទាំងអស់ពីប្រទេសកម្ពុជា និងពិនិត្យឡើងវិញរាល់កិច្ចសន្យាពាក់ព័ន្ធដើម្បីដោះស្រាយការបារម្ភ ដែលបានលើកឡើងក្នុងរបាយការណ៍នេះ ។

2. ធ្វើសវនកម្មរាល់ការបង់ប្រាក់ចំណាយទាំងអស់ដែល បានធ្វើឡើងដោយបណ្តាអង្គភាពរដ្ឋាភិបាលរបស់ប្រទេសសិង្ហបុរី ឬបណ្តាក្រុមហ៊ុន របស់ប្រទេសសិង្ហបុរី សម្រាប់ការនាំចូលខ្សាច់របស់ប្រទេសកម្ពុជា ។ ធ្វើឱ្យប្រាកដថាមានតម្លាភាពពេញលេញ និងបង្ហាញពីការបង់ប្រាក់ ចំណាយនាពេលអនាគតណាមួយដោយបណ្តាក្រុមហ៊ុនរបស់ប្រទេសសិង្ហបុរី សម្រាប់ខ្សាច់របស់ប្រទេសកម្ពុជា ដើម្បីធានាថាទឹកប្រាក់ ត្រឹមត្រូវបានដល់រតនាគាររបស់ប្រទេសកម្ពុជា ។

3. ប្រើប្រាស់តួនាទីរបស់ខ្លួនជាអ្នកនាំមុខក្នុងតំបន់ក្នុងការគ្រប់គ្រងបរិស្ថាន ដើម្បីធ្វើជាគំរូលើពាណិជ្ជកម្មខ្សាច់ និងតម្រូវឱ្យវត្ថុធាតុដើម ត្រូវ តែយកមកពីប្រភពប្រកបដោយចេរភាពជាអន្តរជាតិ ព្រមទាំងពិនិត្យពីរបៀបដែលតំបន់អាស៊ីអគ្នេយ៍ អាចដោះស្រាយបាននូវ ការគ្រប់គ្រងវត្ថុធាតុដើមប្រកបដោយចេរភាព ។

4. ដាក់ឱ្យប្រើប្រាស់នូវសេចក្តីណែនាំសម្រាប់ការយកប្រភពវត្ថុធាតុដើម ប្រកបដោយចេរភាព ពីក្រៅព្រំដែនប្រទេសរបស់ខ្លួន ដែលស្រប តាមសេចក្តីណែនាំពីការអនុវត្តប្រសើរបំផុតនៃការបូមខ្សាច់របស់ឧស្សាហកម្មជាអន្តរជាតិ ដូចបានរៀបរាប់ខាងលើនៅក្នុងទំព័រ 25 ។

5. ពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ (វិសោធនកម្ម) របស់អាជ្ញាធរសាងសង់ និងសំណង់ឆ្នាំ 2009 តម្រូវការតេស្តិ៍ BCA សម្រាប់ នាំចូលវត្ថុធាតុគ្រើម និងរលោង (ខែ មិថុនា ឆ្នាំ 2009) បញ្ញត្តិនៃច្បាប់ស្តីពីការនាំចូល និងនាំចេញ (ត្រូវបានពិនិត្យឡើងវិញឆ្នាំ 1995) និងក្របខណ្ឌច្បាប់ផ្សេងទៀតដើម្បីកំណត់ថា ការនាំចូលវត្ថុធាតុ :

   - ត្រូវបានបូម និងនាំចេញស្របតាមច្បាប់នៃប្រទេសប្រភពដើម ។

   - មិនមានប្រភពមកពីបណ្តាក្រុមហ៊ុនប្រទេសប្រភពដើម ដែលត្រូវបានចោទប្រកាន់ថាមានការពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ ជាពិសេសការអនុវត្តអំពើពុករលួយ និងការបំពានសិទ្ធិមនុស្ស ។

   - ស្ថិតក្រោមការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានពេញលេញ យកចិត្តទុកដាក់ជាក់លាក់ដល់តំបន់ ដែលងាយរងគ្រោះផ្នែកបរិស្ថាន និងជីវភាពក្នុងតំបន់ ដោយយោងតាមការអនុវត្តប្រសើរបំផុតជាអន្តរជាតិ ។

   - ស្ថិតក្រោមការពិនិត្យពិច័យ តាមរយៈការធ្វើអធិការកិច្ចឯករាជ្យ ដើម្បីធ្វើឱ្យប្រាកដថាក្រុមហ៊ុនអនុវត្តតាមបណ្តាបទបញ្ញត្តិ ទាំងនេះ ។

6. ផ្សព្វផ្សាយជាសាធារណៈនូវលំអិតអំពីកិច្ចព្រមព្រៀងខ្សាច់ និងការបង់ប្រាក់ចំណាយដែលធ្វើឡើងរវាងបណ្តាភ្នាក់ងារនៃរដ្ឋាភិបាល ប្រទេសសិង្ហបុរី ជាមួយនឹងបណ្តាប្រទេសអធិបតេយ្យផ្សេងទៀត ។

## ម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជាគួរតែ :

*ជាបន្ទាន់ :*

1. តម្រូវឱ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍សម្រាប់វិស័យខ្សាច់ ដែលបានរៀបរាប់ខាងលើក្នុងកម្មវិធីកំណែទម្រង់ដែលបានព្រមព្រៀងបន្ទាប់ពី កិច្ចប្រជុំ CDCF នៅក្នុងខែ មិថុនា ឆ្នាំ 2010 ។

2. ធ្វើសមាហរណកម្ម និងសម្របសម្រួលរបៀបវារៈនៃជំនួយរបស់ម្ចាស់ជំនួយ សម្រាប់កំណែទម្រង់ក្នុងវិស័យឧស្សាហកម្មស្រង់ធនធាន ដោយផ្តោតទៅលើខ្សាច់ ។ ជាពិសេស ម្ចាស់ជំនួយត្រូវធ្វើឱ្យប្រាកដថា កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យកចិត្តទុក ដាក់លើវិស័យខ្សាច់ ដើម្បីធ្វើឱ្យប្រាកដថា សួយសារ ពន្ធដារ និងចំណូលផ្សេងទៀតដែលរកបានពីឧស្សាហកម្មបូម និងនាំចេញខ្សាច់ បាន ទៅដល់រតនាគាររបស់ប្រទេស ។

3. បង្កើតសមត្ថភាពបណ្តាភ្នាក់ងារ និងផ្នែកនៃរដ្ឋាភិបាលទាំងអស់ ដែលពាក់ព័ន្ធនឹងវិស័យខ្សាច់របស់ប្រទេសកម្ពុជា ដើម្បីធ្វើឱ្យប្រាកដថា សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ពួកគេត្រូវបានរៀបចំ ហើយពួកគេអាចបំពេញតួនាទីរបស់ពួកគេបាន ។

4. ម្ចាស់ជំនួយអន្តរជាតិដែលមានកម្មវិធីពាក់ព័ន្ធដោយផ្ទាល់ ឬប៉ះពាល់នឹងវិស័យខ្សាច់ (ដូចជាកម្មវិធី Natural Resource Management and Livelihoods Programme ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលអង់គ្លេស ញូវហ្សេលែនដ៏ និងដឺណាម៉ាក ជំនួយពីអង្គការ FAO ដល់ជីវភាពរស់នៅផ្អែកលើជលផល និងកម្មវិធីជម្រុញពាណិជ្ជកម្មតាមសមុទ្រ និងការសាងសង់កំពង់ផែដែលផ្តល់ មូលនិធិដោយរដ្ឋាភិបាលជប៉ុន[200]) ត្រូវចាត់វិធានការណ៍ដើម្បីធ្វើកំណែទម្រង់ដែលបានរៀបរាប់ខាងលើ ជាលក្ខខណ្ឌសំរាប់ការផ្តល់ជំនួយ នាពេលអនាគត ។

*អំឡុងឆ្នាំ 2010 :*

1. វិភាគសេដ្ឋកិច្ច-នយោបាយរួមគ្នារបស់គណៈកម្មការលើប្រទេសកម្ពុជា ។ ផ្អែកតាមលទ្ធផលរកឃើញ ម្ចាស់ជំនួយត្រូវប្រឹក្សារួមគ្នាជាមួយ សង្គមស៊ីវិល និងរដ្ឋាភិបាលដើម្បីបង្កើតសំណុំចំណុចប្រសើរៗជាក់លាក់ អាចវាស់វែងបាន និងមានគោលដៅរួមគ្នា ដើម្បីវាស់វែងការ រីក ចម្រើនក្នុងវិស័យខ្សាច់ វិស័យធនធានធម្មជាតិ និងវិស័យអភិបាលកិច្ចឱ្យបានកាន់តែទូលំទូលាយ ។

2. សម្របសម្រួលឧទ្ទេសនាមគំរូជំនួយអភិវឌ្ឍន៍ផ្អែកតាមលទ្ធផលនៅក្នុងប្រទេសកម្ពុជា ។ មូលដ្ឋាននៃការសម្របសម្រួលនេះ គួរតែជា ការព្រមព្រៀង "ជាប់កិច្ចសន្យា" រួមគ្នាថ្មីមួយរវាងម្ចាស់ជំនួយ និងរដ្ឋាភិបាលប្រទេសកម្ពុជា ។ ប្រាក់ជំនួយ គួរតែអាស្រ័យលើចំណុច ប្រសើរៗនៅកិច្ចប្រជុំជម្រុញអភិបាលកិច្ច ។

3. ទទួលស្គាល់ថា ជំនួយរបស់ម្ចាស់ជំនួយ គឺជាវិធីតែមួយគត់ដែលរដ្ឋាភិបាលម្ចាស់ជំនួយ អាចលើកទឹកចិត្តឱ្យមានការអភិវឌ្ឍន៍ ។ គោលនយោបាយរដ្ឋាភិបាលក្រៅពីភ្នាក់ងារអភិវឌ្ឍន៍ (ដូចជា ពាណិជ្ជកម្ម បញ្ហាស្ថានកុងស៊ុល និងបទបញ្ញត្តិហិរញ្ញវត្ថុ) ដើរតួនាទីយ៉ាង សំខាន់ ។ គោលនយោបាយបែបនេះ គួរតែត្រូវបានទទួលស្គាល់ និងបង្ហាញឱ្យច្បាស់លាស់ ដើម្បីផ្តល់នូវការទំនាក់ទំនងគ្នានៅក្នុង គោលនយោបាយអភិវឌ្ឍន៍របស់ម្ចាស់ជំនួយ ។ ឧទាហរណ៍ រដ្ឋាភិបាលម្ចាស់ជំនួយត្រូវតម្រូវឱ្យបណ្តាក្រុមហ៊ុនរុករករបស់ពួកគេ ផ្សព្វផ្សាយ លំអិតពីការបង់ប្រាក់ចំណាយរបស់ពួកគេទៅឱ្យរដ្ឋាភិបាលប្រភពដើម ត្រូវបដិសេធផ្តល់វីសាឱ្យមន្ត្រីក្រៅប្រទេសដែលមានភស្តុតាង ច្បាស់លាស់ថាមានអំពើពុករលួយ

(ដូចដែលសហរដ្ឋអាមេរិកអនុវត្តនាពេលបច្ចុប្បន្ន) សម្រាប់អំពើពុករលួយពាក់ព័ន្ធនឹងធនធាន ធម្មជាតិ ហើយធ្វើឱ្យប្រាកដថា ច្បាប់ស្តីពីការប្រឆាំងការលាងប្រាក់របស់ពួកគេ ត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ធនាគារ ដែលពួកគេចេញគ្រប់គ្រង ក្នុងការសម្របសម្រួលអំពើពុករលួយ ដោយការទទួលយកប្រាក់ដែលទទួលបានពីអំពើពុករលួយ ។

## បណ្តាក្រុមហ៊ុនដែលប្រតិបត្តិការក្នុងវិស័យខ្សាច់របស់ប្រទេសកម្ពុជាគួរតែ ៖

1. ពិនិត្យឡើងវិញប្រតិបត្តិការ ដោយសហការជាមួយភ្នាក់ងាររដ្ឋាភិបាលរបស់ប្រទេសកម្ពុជា និងប្រទេសសិង្ហបុរីពាក់ព័ន្ធ ដើម្បីធ្វើឱ្យប្រាកដ ថាអនុវត្តតាមបញ្ញត្តិនៃច្បាប់ប្រទេសកម្ពុជា និងប្រទេសសិង្ហបុរី ជាពិសេស ៖

    • ស៊ើបអង្កេតការបារម្ភដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ និងចាត់វិធានការណ៍ដោះស្រាយបញ្ហាទាំងនេះជាបន្តបន្ទាប់ ។

    • ធ្វើឱ្យប្រាកដថា ផែនការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសេដ្ឋកិច្ចសង្គម ស្របជាមួយការអនុវត្តប្រសើរបំផុត ជាអន្តរជាតិ និងត្រូវបានអនុវត្ត ។

    • ផ្តល់សំណងដល់ប្រជាជនមូលដ្ឋានដែលរងផលប៉ះពាល់អវិជ្ជមានដោយសកម្មភាពបូមខ្សាច់ យោងតាមច្បាប់ជាតិប្រទេសកម្ពុជា និងការអនុវត្តប្រសើរបំផុតជាអន្តរជាតិ

2. ធ្វើឱ្យប្រាកដថាមានការបង្ហាញព័ត៌មានពេញលេញ និងជាបន្តបន្ទាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងខ្សាច់ជាទ្រព្យសម្បត្តិរួម នាពេលបច្ចុប្បន្ន និង នាពេលអនាគត ដោយរួមទាំងស្រទាប់រ៉ែផងដែរ ពាក់ព័ន្ធនឹងប្រតិបត្តិការ និងដៃគូណាមួយនៃសម្បទាន/អាជ្ញាប័ណ្ណនិមួយៗ ទំហំ និង ទីតាំងរបស់វា លំអិតអំពីការប្តេជ្ញាចិត្តណាមួយដែលបានធ្វើឡើង ដើម្បីទទួលបានមកវិញនូវសិទ្ធិ ចំនួនដែលបានបូមចេញ និងលក់ សួយសារ និងពន្ធដែលបានបង់ និងប្រាក់ចំណេញដែលទទួលបាន ។

# ENDNOTES


1 CIA, 'The World Factbook', តាមរយៈ https://www.cia.gov/library/publications/the-world-factbook/geos/sn.html (ចូលមើលលើកចុងក្រោយថ្ងៃទី ៧ ខែមេសា ឆ្នាំ 2010) ការិយាល័យជំរឿនប្រជាជនសហរដ្ឋអាមេរិក "ការប៉ាន់ស្មានប្រចាំឆ្នាំពីចំនួនប្រជាជនរស់នៅសហរដ្ឋអាមេរិក តាមតំបន់ តាមរដ្ឋ និងព័រតូរីកូ : ថ្ងៃទី 1 ខែមេសា ឆ្នាំ 2000 ដល់ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2009" http://www.census.gov/popest/states/tables/NST-EST2009-01.xls, (ចូលមើលលើកចុងក្រោយថ្ងៃទី ៧ ខែមេសា ឆ្នាំ 2010) ។

2 របាយការណ៍នេះអាចទទួលបានតាមរយៈ http://www.globalwitness.org/media_library_detail.php/713/en/country_for_sale ។

3 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ 'Tableau des Opérations Financières de l'Etat', ចំណូលមិនជាប់ពន្ធពីសម្បទានរុករករ៉ែឆ្នាំ 2006 ។

4 កិច្ចសំភាសន៍ជាមួយកម្មករបូមខ្សាច់ឆ្នាំ 2008 ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បើកផ្តល់អាជ្ញាប័ណ្ណខួងអណ្តូង និងគាស់យកថ្មឱ្យក្រុមហ៊ុន L.Y.P. Group Co Ltd ថ្ងៃទី 15 ខែ សីហា ឆ្នាំ 2008 ។

5 កិច្ចសំភាសន៍ជាមួយកម្មករបូមខ្សាច់ឆ្នាំ 2008 ។ រដ្ឋាភិបាលប្រទេសសិង្ហបុរី "សៀវភៅស្ថិតិប្រចាំឆ្នាំ" ឆ្នាំ 2008 ទំព័រ 17 http://www.singstat.gov.sg/pubn/reference/yos/statsT-prices.pdf (ចូលមើលលើកចុងក្រោយថ្ងៃទី 2 ខែធ្នូ ឆ្នាំ 2008) ។

6 នេះបានកើនឡើងខ្ពស់បំផុតនៅក្នុងឆ្នាំ 2008 ជាមួយនឹងការសន្យាផ្តល់ជំនួយជិត 1 ពាន់លានដុល្លារអាមេរិក រាជរដ្ឋាភិបាលកម្ពុជា "កម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍" http://www.cdc-crdb.gov.kh/cdc/Donor_Development_Cooperation_Programs/Australia/High_Level_Consultation_2009/APPR_en.pdf (ចូលមើលលើក ចុងក្រោយថ្ងៃទី 7 ខែមេសា ឆ្នាំ 2010) ។ Heng Raksmey "ប្រទេសកម្ពុជាបានទទួលជំនួយជិត 1 ពាន់លានដុល្លារអាមេរិក" ស្ថានីយវិទ្យុ VOA Khmer ថ្ងៃទី 5 ខែ ធ្នូ ឆ្នាំ 2008 ។

7 តារាងដែលកត់ត្រាចំណុចនេះ ត្រូវបានផ្តល់ជូននៅទំព័រ 56 និង 57 នៃឯកសារប្រទេសជាតិលក់ និងអាចទទួលបានតាមរយៈ http://www.globalwitness.org/media_library_detail.php/859/en/global_witness_submission_to_the_european_commisso ។

8 Bethany Lindsay និង Phorn Bopha "ការបូមខ្សាច់ស្រូបការគាំទ្ររបស់គ្លូបលវីតណេស" សារព័ត៌មាន Cambodia Weekly ថ្ងៃទ 9 ដល់ថ្ងៃទី 15 ខែ ឧសភា ឆ្នាំ 2009 ។ Vong Sokheng "ហ៊ុន សែន អំពាវនាវម្តងទៀតឱ្យហាមការនាំចេញខ្សាច់ ការសិក្សាពីផលប៉ះពាល់" សារព័ត៌មាន Phnom Penh Post ថ្ងៃទី 2 ខែ កក្កដា ឆ្នាំ 2009 ។

9 កិច្ចសំភាសន៍ជាមួយបណ្តាប្រភពឧស្សាហកម្មឆ្នាំ 2009 ។

10 សេចក្តីយោងពេញលេញពីចំណុចនេះ ត្រូវបានផ្តល់ជូនក្នុងផ្នែកពាក់ព័ន្ធខាងក្រោម ។

11 ក្រសួងធនធានទឹក និងឧតុនិយម ការយល់ព្រមជាគោលការណ៍ឱ្យក្រុមហ៊ុន L.Y.P. Group CO Ltd ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2009 ។

12 ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បើកផ្តល់អាជ្ញាប័ណ្ណខួងអណ្តូង និងគាស់យកថ្មឱ្យក្រុមហ៊ុន L.Y.P. Group Co Ltd ថ្ងៃទី 15 ខែ សីហា ឆ្នាំ 2008 ។

13 ក្រសួងធនធានទឹក និងឧតុនិយម ការយល់ព្រមជាគោលការណ៍ឱ្យក្រុមហ៊ុន L.Y.P. Group CO Ltd ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2009 ។ កិច្ចសំភាសន៍ជាមួយ ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួង ធនធានទឹក និងឧតុនិយមនៅស្ថានីយទូរទស្សន៍ Cambodian Television Network ខែ តុលា ឆ្នាំ 2009 ។

14 កិច្ចសម្ភាសន៍ជាមួយតំណាងរបស់អាជ្ញាធរខេត្តកោះកុង ថ្ងៃទី 20 ខែ វិច្ឆិកា ឆ្នាំ 2009 ។

15 កិច្ចសម្ភាសន៍ជាមួយកម្មករបូមខ្សាច់ឆ្នាំ 2009 ។

16 រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ 2009 សេចក្តីសម្រេចពាក់ព័ន្ធនឹងការកម្រិតលើការធ្វើអាជីវកម្មខ្សាច់ ថ្ងៃទី 9 ខែ ឧសភា ឆ្នាំ 2009 (លេខ 4 ស.ស.រ) សំណៅបកប្រែក្រៅផ្លូវការ ។ អត្ថបទនេះ និងការវិភាគខ្លឹមសារនៃសេចក្តីសម្រេចស្តីពីការធ្វើអាជីវកម្មខ្សាច់ខាងក្រោមនេះ ផ្អែកទៅលើសំណៅបកប្រែពីភាសាខ្មែរទៅភាសាអង់គ្លេសក្រៅផ្លូវការ ។

17 កិច្ចសំភាសន៍ជាមួយប្រភពឧស្សាហកម្មឆ្នាំ 2009 ។ គេហទំព័ររាជរដ្ឋាភិបាលកម្ពុជា "វិនិយោគក្នុងប្រទេសកម្ពុជា" http://www.investincambodia.com/minerals.htm (ចូលមើលលើកចុងក្រោយថ្ងៃទី 13 ខែមិនា ឆ្នាំ 2009) របាយការណ៍ស្តីពីការជឿជាក់លើក្រុមហ៊ុន L.Y.P. Group Co Ltd បានមកពីក្រុមហ៊ុន Commercial Intelligence S.E. Asia PTE Ltd ថ្ងៃទី 29 ខែ មករា ឆ្នាំ 2010 ។ Sebastian Strangio និង Vong Sokheng "ការរុករករ៉ែខ្សាច់ជ្រៀតចូលសមុទ្រខេត្តកោះកុង" សារព័ត៌មាន Phnom Penh Post ថ្ងៃទី 10 ខែ មីនា ឆ្នាំ 2009 ។

18 ការស្រាវជ្រាវរបស់ក្រុមហ៊ុន Winton Enterprises Limited លើការចុះឈ្មោះក្រុមហ៊ុន ICRIS CSC រដ្ឋាភិបាលតំបន់រដ្ឋបាលពិសេសហុងកុង ថ្ងៃទី 8 ខែ មករា ឆ្នាំ 2010 ។

19 ការស្រាវជ្រាវពីព័ត៌មានប្រជាជនស្តីពីឯកសារ ពិបថិលេ របស់អាជ្ញាធរចេញបទបញ្ញត្តិគណនេយ្យ និងក្រុមហ៊ុនប្រទេសសិង្ហបុរី ថ្ងៃទី 20 ខែ មករា ឆ្នាំ 2010 ។ លំអិតពីការចុះឈ្មោះរបស់ក្រុមហ៊ុន Camb Resources PTE Ltd លើគេហទំព័ររបស់អាជ្ញាធរសាងសង់ និងសំណង់ប្រទេសសិង្ហបុរី : http://dir.bca.gov.sg/bca/CompanyDetail.asp?CoType=All&ID=200820696K (ចូលមើលលើកចុងក្រោយថ្ងៃទី 13 ខែមិនា ឆ្នាំ 2010) ។

20 http://www.bca.gov.sg/AboutUs/about_bca.html (ចូលមើលលើកចុងក្រោយថ្ងៃទី 21 ខែមេសា ឆ្នាំ 2010) និង http://dir.bca.gov.sg/bca/overview.htm (ចូលមើលលើកចុងក្រោយថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2010) ។

21 អាជ្ញាធរសាងសង់ និងសំណង់ ខែ មិថុនា ឆ្នាំ 2009 តម្រូវការក្នុងការចុះឈ្មោះសម្រាប់ Supply Workheads អាចទទួលបានតាមរយៈ http://www.bca.gov.sg/ContractorsRegistry/others/Registration_SY.pdf (ចូលមើលលើកចុងក្រោយថ្ងៃទី 22 ខែមីនា ឆ្នាំ 2010) ។

22 កិច្ចសំភាសន៍ជាមួយបណ្តាប្រភពឧស្សាហកម្មឆ្នាំ 2008 និង 2009 ។

23 គេហទំព័ររបស់ JTC និង ទី តាមរយៈ http://app.mti.gov.sg/default.asp?id=100 (ចូលមើលលើកចុងក្រោយថ្ងៃទី 22 ខែមីនា ឆ្នាំ 2010) ។ កិច្ចសម្ភាសន៍ជាមួយ ប្រភពឧស្សាហកម្មឆ្នាំ 2009 ។

24 អ៊ីម៉ែលទៅកាន់គ្លូបលវីតណេសដែលបានទទួលពីក្រសួងអភិវឌ្ឍន៍ជាតិនៃរដ្ឋាភិបាលប្រទេសសិង្ហបុរីថ្ងៃទី 21 ខែ មេសា ឆ្នាំ 2010 ។

25 លំអិតពីការចុះឈ្មោះរបស់ក្រុមហ៊ុន Riverton Group PTE Ltd លើគេហទំព័ររបស់អាជ្ញាធរសាងសង់ និងសំណង់ប្រទេសសិង្ហបុរី : http://dir.bca.gov.sg/bca/CompanyDetail.asp?CoType=All&ID=200604751C (ចូលមើលលើកចុងក្រោយថ្ងៃទី 7 ខែមេសា ឆ្នាំ 2010) ។ ព័ត៌មានក្រុមហ៊ុនរបស់ក្រុមហ៊ុន Riverton Group PTE Ltd លើឯកសារ Bizfile របស់អាជ្ញាធរចេញបទបញ្ញត្តិគណនេយ្យ និងក្រុមហ៊ុនប្រទេសសិង្ហបុរី ថ្ងៃទី 8 ខែ មករា ឆ្នាំ 2010 ។

26 រូបថតថតដោយគ្លូបលវីតណេសនៅក្នុងឆ្នាំ 2009 ។

27 ការឆ្លើយឆ្លងអ៊ីម៉ែលជាមួយតំណាងក្រុមហ៊ុនឆ្នាំ 2010 ។ ប័ណ្ណទទួលប្រាក់ចំណាយដោយក្រុមហ៊ុន Ta Chang Selindo Cambodia Co Ltd ថ្ងៃទី 10 ខែ វិច្ឆិកា ឆ្នាំ 2009 ។ របាយការណ៍តេស្តិ៍គុណភាពខ្សាច់របស់ Setsco លើខ្សាច់ស្ទឹងតាតៃប្រទេសកម្ពុជា ថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2009 ។ អាសយដ្ឋានចុះបញ្ជីរបស់ក្រុមហ៊ុន Da Chang Construction Décor Co Ltd ក្នុងសៀវភៅលឿង (yellow pages) របស់ប្រទេសកម្ពុជា http://www.yellowpages-cambodia.com/construction/construction-contractors-consultants-and-management/da-chang-construction-decor-co-ltd-19345.html (ចូលមើលលើកចុងក្រោយថ្ងៃទី 13 ខែមីនា ឆ្នាំ 2010) ។ ព័ត៌មានក្រុមហ៊ុនរបស់ក្រុមហ៊ុន Selindo Global (S) PTE Ltd លើឯកសារ Bizfile របស់អាជ្ញាធរចេញបទបញ្ញត្តិគណនេយ្យ និងក្រុមហ៊ុនប្រទេសសិង្ហបុរី ថ្ងៃទី 6 ខែ កុម្ភៈ ឆ្នាំ 2010 ។

28 ការឆ្លើយឆ្លងអ៊ីម៉ែលជាមួយតំណាងក្រុមហ៊ុនឆ្នាំ 2010 ។ ព័ត៌មានក្រុមហ៊ុនរបស់ក្រុមហ៊ុន Song and Song Resources PTE Ltd លើឯកសារ Bizfile របស់អាជ្ញាធរចេញបទបញ្ញត្តិគណនេយ្យ និងក្រុមហ៊ុនប្រទេសសិង្ហបុរី ថ្ងៃទី 4 ខែ មីនា ឆ្នាំ 2010 ។ លំអិតពីការចុះឈ្មោះរបស់ក្រុមហ៊ុន Song and Song Resources PTE Ltd លើគេហទំព័ររបស់ អាជ្ញាធរសាងសង់ និងសំណង់ប្រទេសសិង្ហបុរី : http://dir.bca.gov.sg/bca/CompanyDetail.asp?CoType=All&ID=200710432N (ចូលមើលលើកចុងក្រោយថ្ងៃទី 13 ខែមីនា ឆ្នាំ 2010) ។

29 ការឆ្លើយឆ្លងអ៊ីម៉ែលជាមួយតំណាងក្រុមហ៊ុនឆ្នាំ 2010 ។ ព័ត៌មានក្រុមហ៊ុនរបស់ក្រុមហ៊ុន Song and Song Resources PTE Ltd លើឯកសារ Bizfile របស់អាជ្ញាធរចេញបទបញ្ញត្តិគណនេយ្យ និងក្រុមហ៊ុនប្រទេសសិង្ហបុរី ថ្ងៃទី 4 ខែ មីនា ឆ្នាំ 2010 ។ លំអិតពីការចុះឈ្មោះរបស់ក្រុមហ៊ុន Song and Song Resources PTE Ltd លើគេហទំព័ររបស់ អាជ្ញាធរសាងសង់ និងសំណង់ប្រទេសសិង្ហបុរី : http://dir.bca.gov.sg/bca/CompanyDetail.asp?CoType=All&ID=200710432N (ចូលមើលលើកចុងក្រោយថ្ងៃទី 13 ខែមីនា ឆ្នាំ 2010) ។

30 តួលេខបានទទួលដោយការបូកបន្ថែមទឹកប្រាក់នាំចេញសរុបនៅក្នុងឯកសារខាងក្រោម : ការចុះបញ្ជីទំនិញ ថ្ងៃទី 15 ខែ វិច្ឆិកា ឆ្នាំ 2009 រវាងក្រុមហ៊ុន L.Y.P. Group និង ក្រុមហ៊ុន Teleek Management PTE Ltd ចំនួន 3,200MT ។ ការចុះបញ្ជីទំនិញ ថ្ងៃទី 17 ខែ វិច្ឆិកា ឆ្នាំ 2009 រវាងក្រុមហ៊ុន L.Y.P. Group និង ក្រុមហ៊ុន Wan Qi PTE Ltd ចំនួន 3,200MT ។ វិក្កយប័ត្រ Bill of Lading ថ្ងៃទី 21 ខែ វិច្ឆិកា ឆ្នាំ 2009 រវាងក្រុមហ៊ុន L.Y.P Group និងក្រុមហ៊ុន Wan Qi PTE Ltd ចំនួន 8,036MT ។ វិក្កយប័ត្រ Bill of Lading ថ្ងៃទី 22 Ex vicäika qñaM 2009 រវាងក្រុមហ៊ុន L.Y.P Group និងក្រុមហ៊ុន Wan Qi PTE Ltd ចំនួន 6,600MT ។ និងវិក្កយប័ត្រ Bill of Lading ថ្ងៃទី 17 ខែ វិច្ឆិកា ឆ្នាំ 2009 រវាងក្រុមហ៊ុន L.Y.P Group និងក្រុមហ៊ុន Jui Zhou Shipping Ltd ចំនួន 56,200MT ។

31 ព័ត៌មានក្រុមហ៊ុនរបស់ក្រុមហ៊ុន Teelek Resource Management PTE Ltd លើឯកសារ Bizfile របស់អាជ្ញាធរចេញបទបញ្ញត្តិគណនេយ្យ និងក្រុមហ៊ុនប្រទេសសិង្ហបុរី ថ្ងៃទី 14 ខែ មីនា ឆ្នាំ 2010 ។ មិនមានក្រុមហ៊ុនផ្សេងទៀតក្នុងប្រទេសសិង្ហបុរីដែលមានឈ្មោះដូចគ្នានេះទេ ។

32 លំអិតពីការចុះឈ្មោះរបស់ក្រុមហ៊ុន Wan Qi PTE Ltd លើគេហទំព័ររបស់អាជ្ញាធរសាងសង់ និងសំណង់ប្រទេសសិង្ហបុរី : http://dir.bca.gov.sg/bca/CompanyDetail.asp?CoType=All&ID=200711368E (ចូលមើលលើកចុងក្រោយថ្ងៃទី 13 ខែមីនា ឆ្នាំ 2010) ។

33 ការចុះបញ្ជីទំនិញ រវាងក្រុមហ៊ុន L.Y.P. Group និង ក្រុមហ៊ុន Wan Qi PTE Ltd ថ្ងៃទី 17 ខែ វិច្ឆិកា ឆ្នាំ 2009 ។

34 រូបថតថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ។

35 សកម្មភាពរបស់នាវាដែលបានរត់នៅលើប្រព័ន្ធទិន្នន័យរបស់ Lloyds List Intelligence Database (ចូលមើលលើកចុងក្រោយ ខែកុម្ភៈ ឆ្នាំ 2010) ។

36 រូបថតថតនៅក្នុងខែ វិច្ឆិកា ឆ្នាំ 2009 ។

37 សកម្មភាពរបស់នាវាដែលបានរត់នៅលើប្រព័ន្ធទិន្នន័យរបស់ Lloyds List Intelligence Database (ចូលមើលលើកចុងក្រោយ ខែកុម្ភៈ ឆ្នាំ 2010) ។

38 ប័ណ្ណទទួលប្រាក់ចំណាយដោយក្រុមហ៊ុន Ta Chang Selindo Cambodia Co Ltd ថ្ងៃទី 10 ខែ វិច្ឆិកា ឆ្នាំ 2009 ។ ការឆ្លើយឆ្លងរវាងគ្លូបលវីតណេស និងក្រុមហ៊ុនក្នុងឆ្នាំ 2009 និង 2010 ។

39 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល "ប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃចុះឈ្មោះ ការប្តូរថ្មីទម្រង់បែបបទពាក្យសុំ (ថ្លៃចេញវិញ្ញាបនប័ត្រ) ការផ្ទេរ អាជ្ញាប័ណ្ណធនធានរ៉ែ ការជួលដីប្រចាំឆ្នាំនៅក្នុងតំបន់សម្បទានសម្រាប់ការរុករករ៉ែ និង/ឬការរុករក និងស្ទួយសារលើធនធានរ៉ែ" ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ 2009 ។

40 តាមការកត់ត្រាក្នុងរបាយការណ៍ចំនួន 18 ដោយគ្លូបលវីតណេសស្តីពី អភិបាលកិច្ចបរាជ័យរបស់ប្រទេសកម្ពុជាលើធនធានធម្មជាតិរបស់ខ្លួនចាប់តាំងពីឆ្នាំ ១៩៩៥ អាចទទួលយកបានតាម http://www.globalwitness.org/media_library.php ។

